KONRAD
ADENAUER
STIFTUNG

# បច្ចុប្បន្នភាពការទូត

## តើជាល្បែងមហាអំណាចមួយទៀតឬ ?
## យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកនិងអាស៊ីអាគ្នេយ៍

លេខ៣ | ខែកក្កដា ឆ្នាំ២០២១



បណ្តុំទស្សនៈនិងអត្ថបទខ្លីៗ តាមវិស័យ
ស្តីពីទំនាក់ទំនងអន្តរជាតិ ដែលចេញផ្សាយពីរដងក្នុងមួយឆ្នាំ

**ក្រុមការងារត្រួតពិនិត្យនិងកែសម្រួលៈ**
ឯ.ឧ បណ្ឌិត គិន ភា
បណ្ឌិត ឈិត ប៊ុនថង
លោក ធន ឆាយពិសិដ្ឋ
បណ្ឌិត មាឃ បូរ៉ា
លោក លឹម ឆាយ
លោក ស៊ិន ពីងហុង

**ត្រួតពិនិត្យដោយ**
ពេជ្រ ចារ៉ាឌីន
Maurizio PACIELLO

**រចនាប្លង់អត្ថបទនិងក្រាហ្វិចដោយ**
សំ បញ្ញា

**រចនាក្របដោយ**
កែវ ពិសិដ្ឋ

**ត្រួតពិនិត្យអត្ថបទដោយ**
Allison Jane SMITH

**សូមថ្លែងអំណរគុណដល់**
Jan BOCKHOLT
Tim HILDEBRANDT
Robert HÖR
លឹម ឆាយ
លី ស៊ូសាន់ដា
អ៊ុំ ឧត្តម
Salome SCHMID
និងអ្នកនិពន្ធអត្ថបទដទៃទៀតរបស់យើង។

© វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព និង មូលនិធិខុនរ៉ាដអាដិណៅអ៊ែរ ឆ្នាំ២០២១

## សេចក្តីបដិសេធ

អត្ថបទដែលបានចូលរួមវិភាគទានក្នុងទស្សនាវដ្តីនេះ មិនឆ្លុះបញ្ចាំងពីគំនិត និងទស្សនៈរបស់គណៈកម្មការនិពន្ធ និងមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ ឬវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាពទេ។ ដូច្នេះ សេចក្តីសន្និដ្ឋានដែលបានលើកឡើងនៅក្នុងអត្ថបទទាំងនេះ មិនឆ្លុះបញ្ចាំងទស្សនៈរបស់អង្គភាពណាមួយនោះទេ វាជាទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយអាចមានការកែសម្រួលឡើងវិញនៅពេលក្រោយ។

This work is licensed under the Creative Commons Attribution 4.0 International License. To view a copy of this license, visit http://creativecommons.org/licenses/by/4.0/ or send a letter to Creative Commons, PO Box 1866, Mountain View, CA 94042, USA.

**បច្ចុប្បន្នភាពការទូត** គឺជាបណ្តុំទស្សនៈនិងអត្ថបទខ្លីៗ តាមវិស័យ
ស្តីពីទំនាក់ទំនងអន្តរជាតិ**ដែលចេញផ្សាយពីរដងក្នុងមួយឆ្នាំ**ដោយ
បណ្ដាញអ្នកប្រាជ្ញនិងអ្នកជំនាញក្នុងតំបន់ដ៏ទូលំទូលាយ ដែល
គ្របដណ្ដប់ប្រធានបទដ៏សម្បូរបែប រួមមាន ទំនាក់ទំនងអន្តរជាតិ
កិច្ចការអនុតំបន់ នយោបាយការបរទេស សេដ្ឋកិច្ច និងពាណិជ្ជកម្ម
និងប្រធានបទផ្សេងៗ ទៀតជាច្រើន ។

ដោយមានការផ្តួចផ្តើមគំនិតរៀបចំដោយមូលនិធិខុនរ៉ាដ
អាដិនណៅអ៊ែរ (KAS) ប្រចាំប្រទេសកម្ពុជា និងវិទ្យាស្ថានខ្មែរ
សម្រាប់សហប្រតិបត្តិការនិងសន្តិភាព (CICP)
បច្ចុប្បន្នភាពការទូតនេះ មានបំណងបម្រើដល់សហគមន៍ការទូត
អ្នករៀបចំគោលនយោបាយ និងភាគីពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា
និងតំបន់ ដែលមានចំណាប់អារម្មណ៍លើការវិភាគនិងការពិភាក្សា
ដេញដោលពីទំនោរ ការប្រឈម និងបញ្ហានានាដែលកើតឡើងថ្មីៗ
បំផុត នៅក្នុងសង្វៀនសកលលោកដែលអាចរំខានដល់ការអភិវឌ្ឍ
ចម្បងនានានៅក្នុងប្រទេសកម្ពុជា និងគំរាមកំហែងសន្តិភាព តំបន់
និងស្ថិរភាពជាទូទៅ។

បច្ចុប្បន្នភាពការទូតនេះ ក៏មានបំណងធ្វើជាវេទិកាមួយសម្រាប់ការ
ផ្លាស់ប្តូរទស្សនវិស័យនិងការយល់ដឹងនានារបស់បញ្ញវន្ត ព្រមទាំង
សម្រាប់អ្នកប្រាជ្ញខ្មែរនានាដែលកំពុងលេចមុខឡើង ដើម្បីទទួល
បានការបោះពុម្ពផ្សាយនូវស្នាដៃស្រាវជ្រាវរបស់ពួកគាត់។

**អំពីវិទ្យាស្ថានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (IRIC)**

វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា ត្រូវបានបង្កើតនៅ
ឆ្នាំ២០០៥ ក្រោមក្របខណ្ឌនៃរាជបណ្ឌិត្យសភាកម្ពុជា។
វិទ្យាស្ថានមានបេសកកម្មសិក្សា ស្រាវជ្រាវ តាមដាន វិភាគ
និងផ្តល់យោបល់ឬជូនព័ត៌មាន រៀបចំវេទិកាវិទ្យាសាស្ត្រ និង
បោះពុម្ពផ្សាយ លើវិស័យទំនាក់ទំនងអន្តរជាតិ។ វិទ្យាស្ថានមាន
គោលបំណងរួមចំណែកលើកកម្ពស់កិត្យានុភាពនិងតួនាទីរបស់
កម្ពុជាលើឆាកអន្តរជាតិ និង ចូលរួមដោយស្មើមុខនិងស្មើសិទ្ធិក្នុង
កិច្ចការអន្តរជាតិនានា ទាំងក្នុងក្របខណ្ឌតំបន់និងពិភពលោក។
ក្នុងរយៈពេល១៦ឆ្នាំកន្លងមកនេះ វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ
នៃកម្ពុជាបានខិតខំបំពេញភារកិច្ចស្នូលរបស់ខ្លួនយ៉ាងយកចិត្ត
ទុកដាក់ស្របតាមចក្ខុវិស័យ គោលបំណង បេសកកម្ម និង
ភារកិច្ចរបស់ខ្លួន។ សមិទ្ធផលដែលវិទ្យាស្ថានសម្រេចបាន មាន
ដូចជា ការស្រាវជ្រាវលើប្រធានបទមួយចំនួនដែលមានលក្ខណៈ
បច្ចុប្បន្នភាព ហើយដែលភាគច្រើនជាការស្រាវជ្រាវបឋមនិងមាន
លក្ខណៈផ្ទៃក្នុង ការរៀបចំវេទិកាវិទ្យាសាស្ត្រនានាអំពីបញ្ហាតំបន់និង
អន្តរជាតិ និងការចេញផ្សាយទស្សនាវដ្តី ការបោះពុម្ពផ្សាយរបាយ-
ការណ៍ស្រាវជ្រាវ ការចងក្រងនិងបោះពុម្ពកម្រងអត្ថបទនៃវេទិកា
វិទ្យាសាស្ត្រ ដែលវិទ្យាស្ថានបានរៀបចំនាពេលកន្លងមក។
ជាមួយគ្នានេះដែរ ក្នុងក្របខណ្ឌវិទ្យាស្ថានផ្ទាល់ ក៏ដូចជាក្នុងក្រប-
ខណ្ឌរាជបណ្ឌិត្យសភាកម្ពុជាទាំងមូល ក្នុងឋានៈជាសេនាធិការ
វិទ្យាសាស្ត្ររបស់រាជរដ្ឋាភិបាល វិទ្យាស្ថានបានខិតខំប្រឹងប្រែង
អស់ពីសមត្ថភាពក្នុងការបំពេញបេសកកម្មរបស់ខ្លួនសំដៅរួម
ចំណែកផ្តល់ធាតុចូលជូនរាជរដ្ឋាភិបាលក្នុងការរៀបចំគោល
នយោបាយការបរទេស និងការអភិវឌ្ឍប្រកបដោយចីរភាព និងរួម
ចំណែកស្វែងរកដំណោះស្រាយសម្រាប់បញ្ហាប្រឈមនានានៅក្នុង
តំបន់។ ទន្ទឹមនឹងនេះដែរ វិទ្យាស្ថានក៏បានតាមដានយ៉ាង
យកចិត្តទុកដាក់ពីការវិវត្តនៃនយោបាយជាតិនិងអន្តរជាតិ ដើម្បី
វិភាគនិងផ្តល់យោបល់ជូនរាជរដ្ឋាភិបាល។ វិទ្យាស្ថានបានដើរ
តួនាទីជាមជ្ឈមណ្ឌលប្រមូលផ្តុំអ្នកស្រាវជ្រាវកិច្ចការអន្តរជាតិ
គោលនយោបាយការបរទេស និងការទូត។

www.iric.gov.kh

**អំពីវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព (CICP)**

វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព ត្រូវបានបង្កើត
ឡើងក្នុងឆ្នាំ១៩៩៣ គឺជាធនាគារខួរក្បាលផ្នែកគោលនយោបាយ
ការបរទេសដ៏ចំណាស់ជាងគេនៅប្រទេសកម្ពុជា និងជាវេទិកាឈាន
មុខគេរបស់ប្រទេសកម្ពុជាសម្រាប់កិច្ចសន្ទនាកិច្ចការបរទេស
Track 2។ វិទ្យាស្ថាននេះខិតខំជំរុញការស្រាវជ្រាវផ្អែកលើគោល
នយោបាយដែលអាចប្រើការបានដើម្បីដោះស្រាយបញ្ហាប្រឈមជា
ច្រើន និងដើម្បីលើកកម្ពស់ការពិភាក្សាដេញដោលប្រកបដោយ
គុណភាពលើបញ្ហាសំខាន់ៗ ដែលជាបញ្ហាសម្រាប់ប្រទេស
និងតំបន់។

នៅក្នុងដំណើរជិត៣០ឆ្នាំ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ
និងសន្តិភាព បានចូលរួមជាមួយអ្នកវិភាគ អ្នកប្រាជ្ញ និងអ្នកការទូត
មកពីទូទាំងសកលលោក ដើម្បីពិនិត្យបញ្ហាភូមិសាស្ត្រនយោបាយ
សន្តិសុខ សង្គម និងសេដ្ឋកិច្ច ដែលប៉ះពាល់ទាំងប្រទេសកម្ពុជា
ព្រមទាំងអាស៊ីអាគ្នេយ៍ទាំងមូល។ នៅក្នុងគេហទំព័ររបស់វិទ្យាស្ថាន
លោកអ្នកអាចស្វែងរកនូវសកម្មភាពជាច្រើនបែបច្រើនយ៉ាងដែល
វិទ្យាស្ថានបានធ្វើ ដែលរួមមាន របាយការណ៍លទ្ធផលនៃព្រឹត្តិការណ៍
ជាច្រើន ព្រមទាំងការបោះពុម្ពផ្សាយសំខាន់ទាំងពីររបស់យើង
គឺទស្សនាវដ្តីស្តីអំពីការសិក្សាមហាតំបន់មេគង្គ និងបច្ចុប្បន្នភាព
ការទូត។ យើងមានមោទនភាពយ៉ាងខ្លាំងពីកំណត់ត្រាការងាររបស់
យើង ជាស្ថាប័នស្រាវជ្រាវមួយ ព្រមទាំងរក្សាតំណែងជាធនាគារខួរ-
ក្បាលផ្នែកកិច្ចការបរទេសនៅក្នុងព្រះរាជាណាចក្រតែមួយគត់ដែល
បានជាប់ចំណាត់ថ្នាក់បីឆ្នាំជាប់ៗ គ្នាតាំងពីឆ្នាំ២០១៨ និងជាប់
លេខទី៣២ក្នុងចំណោមធនាគារខួរក្បាលកំពូលទាំង១០០ នៅក្នុង
អាស៊ីអាគ្នេយ៍និងប៉ាស៊ីហ្វិក ដែលកំណត់ដោយសន្ទស្សន៍ធនាគារ
ខួរក្បាលសកលលោករបស់សកលវិទ្យាល័យផេនស៊ីវ៉ានៀ។
ក្នុងនាមជាស្ថាប័នមួយ វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិង
សន្តិភាពមានមូលដ្ឋានផ្អែកលើបញ្ញត្តិសាមញ្ញចំនួនបី គឺសត្យានុម័ត
អព្យាក្រឹត និងឯករាជ្យ។ យើងចូលរួមដោយគ្មានលម្អៀង និង
ព្យាយាមលើកទឹកចិត្តឱ្យមានការស្រាវជ្រាវបែបវិទ្យាសាស្ត្រដោយ
ផ្តោតលើគោលនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងធ្វើ
ជាដៃគូយ៉ាងសកម្មជាមួយនឹងតួអង្គនានា ដើម្បីពង្រឹងសមត្ថភាព
ស្រាវជ្រាវនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដើម្បីគាំទ្រសន្តិសុខ
ការអភិវឌ្ឍ និងអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាផ្ទាល់
ក៏ដូចជាសមាហរណកម្មតំបន់។

www.cicp.org.kh

## អំពីមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ (KAS)

សេរីភាព យុត្តិធម៌ និងសាមគ្គីភាព គឺជាគោលការណ៍គ្រឹះដែលជាមូលដ្ឋាននៅក្នុងការងាររបស់មូលនិធិខុនរ៉ាដអាដិណៅអ៊ែរ (KAS)។ មូលនិធិខុនរ៉ាដអាដិណៅអ៊ែរ (KAS) គឺជាមូលនិធិនយោបាយមួយដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងគណបក្សសហភាពប្រជាធិបតេយ្យគ្រិស្តសាសនារបស់អាល្លឺម៉ង់ (CDU)។ ក្នុងនាមជាសហស្ថាបនិកនៃគណបក្សសហភាពប្រជាធិបតេយ្យគ្រិស្តសាសនារបស់អាល្លឺម៉ង់និងជាអធិការបតីទី១ របស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ លោក ខុនរ៉ាដ អាដិណៅអ៊ែរ ( ១៨៧៦-១៩៦៧ ) បានបង្រួបបង្រួមប្រពៃណីគ្រិស្តសាសនាបែបសង្គម បែបអភិរក្ស និងបែបសេរីនិយម។ ឈ្មោះរបស់គាត់មានន័យដូចគ្នានឹងការកសាងប្រជាធិបតេយ្យឡើងវិញរបស់អាល្លឺម៉ង់ ដែលជាគោលជំហរដ៏រឹងមាំចំពោះគោលនយោបាយការបរទេសជាមួយនឹងសហគមន៍អន្តរអាត្លង់ទិកប្រកបដោយគុណតម្លៃ និងចក្ខុវិស័យសម្រាប់ទ្វីបអ៊ឺរ៉ុបមួយដែលរួបរួមនិងការតម្រង់ឆ្ពោះទៅសេដ្ឋកិច្ចទីផ្សារសង្គម។ មរតកបញ្ញាញាណរបស់គាត់បានបន្តបម្រើទាំងគោលបំណងរបស់យើងទាំងជាកាតព្វកិច្ចរបស់យើងរហូតដល់សព្វថ្ងៃនេះ។ ក្នុងកិច្ចខំប្រឹងប្រែងក្នុងកិច្ចសហប្រតិបត្តិការនៅអ៊ឺរ៉ុបនិងអន្តរជាតិរបស់យើង ពួកយើងធ្វើការដើម្បីឱ្យប្រជាជនអាចរស់នៅដោយស្វ័យសម្រេចក្នុងជីវិតប្រកបដោយសេរីភាពនិងសេចក្តីថ្លៃថ្នូរ។ យើងរួមចំណែកគាំទ្រគុណតម្លៃនានាដើម្បីជួយឱ្យអាល្លឺម៉ង់សម្រេចបាននូវការទទួលខុសត្រូវកាន់តែកើនឡើងរបស់ខ្លួននៅទូទាំងពិភពលោក។

មូលនិធិខុនរ៉ាដអាដិណៅអ៊ែរ (KAS) បានបំពេញការងារនៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩៤ ដោយបានព្យាយាមគាំទ្រប្រជាជនកម្ពុជាក្នុងការបង្កើតកិច្ចសន្ទនា ការកសាងបណ្តាញ និងការលើកកម្ពស់គម្រោងវិទ្យាសាស្រ្តនានា។ ជាមួយមធ្យោបាយទាំងនោះ មូលនិធិធ្វើការឆ្ពោះទៅរកការបង្កើតបរិស្ថានមួយដែលអំណោយផលចំពោះការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។ កម្មវិធីទាំងអស់ត្រូវបានបង្កើតជាផែនការនិងអនុវត្តដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូកម្ពុជាទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

www.kas.de/en/web/kambodscha

# បុព្វកថា

ទស្សនាវដ្ដី «បច្ចុប្បន្នភាពការទូត» ជាភាសាអង់គ្លេសត្រូវបានរៀបចំបោះពុម្ពផ្សាយចំនួន៣លេខ រួចមកហើយ ក្រោមគំនិតផ្ដួចផ្ដើមដោយមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ (KAS) ប្រចាំប្រទេសកម្ពុជា និងវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព (CICP) ចាប់តាំងខែឧសភា ឆ្នាំ២០២០មក។ ទស្សនាវដ្ដី «បច្ចុប្បន្នភាពការទូត» ប្រមូលផ្ដុំទៅដោយអត្ថបទបែបវិចារណកថា បទវិភាគ ទស្សនវិស័យ និងបទសម្ភាសន៍ ដោយអ្នកជំនាញ អ្នកស្រាវជ្រាវ អ្នករៀបចំគោលនយោបាយ និងអ្នកការទូតខ្មែរនិងបរទេស។ នៅក្នុងទស្សនាវដ្ដី «បច្ចុប្បន្នភាពការទូត» លេខ១ បានគ្របដណ្ដប់លើប្រធានបទយ៉ាងសំខាន់ពាក់ព័ន្ធនឹងបញ្ហាប្រឈមចម្បងៗក្នុងទសវត្សរ៍ថ្មី និងដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនោះ, លេខ២ ផ្ដោតលើការត្រៀមខ្លួនរបស់អាស៊ានសម្រាប់អនាគតឌីជីថលនិងការសម្លឹងមើលទៅលើបញ្ហានានា ចាប់ពីបណ្ដាញ 5G និងសន្តិសុខជាតិ រហូតដល់ច្បាប់បរិស្ថាន និងយេនឌ័រ និងលេខ៣នេះ គ្របដណ្ដប់ទៅលើទំនាក់ទំនងអន្តរជាតិរហូតដល់កិច្ចការអនុតំបន់ពីនយោបាយការបរទេសរហូតដល់សេដ្ឋកិច្ចនិងពាណិជ្ជកម្ម ព្រមទាំងមានប្រធានបទផ្សេងទៀតផងដែរ។

អត្ថបទនានាដែលមានក្នុងទស្សនាវដ្ដី «បច្ចុប្បន្នភាពការទូត» ទាំងបីលេខនេះ ពិតជាមានខ្លឹមសារល្អ និងមានព័ត៌មានសម្បូរបែបពាក់ព័ន្ធនឹងការវិវត្តខាងនយោបាយ សន្តិសុខ សណ្ដាប់ធ្នាប់ សេដ្ឋកិច្ច និងសង្គមវប្បធម៌ក្នុងតំបន់និងពិភពលោក ជាពិសេស ពាក់ព័ន្ធនឹងតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក។ ទស្សនាវដ្ដីនេះពិតជាមានប្រយោជន៍ចំពោះសហគមន៍ការទូត អ្នករៀបចំគោលនយោបាយ អ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត និងភាគីពាក់ព័ន្ធដទៃទៀត ទាំងនៅក្នុងប្រទេសកម្ពុជា ទាំងនៅក្នុងតំបន់ ដែលមានចំណាប់អារម្មណ៍លើការវិភាគ និងការពិភាក្សាដេញដោលពីទំនោរ បញ្ហាប្រឈម និងបញ្ហានានាដែលកើតឡើងថ្មីៗបំផុត នៅក្នុងសង្វៀនសកលលោក ដែលអាចរំខានដល់ការអភិវឌ្ឍនានានៅក្នុងប្រទេសកម្ពុជា និងគំរាមកំហែងសន្តិភាពតំបន់និងស្ថិរភាពជាទូទៅ។

ប៉ុន្តែដោយសារអត្ថបទទាំងនោះត្រូវបានបោះពុម្ពផ្សាយជាភាសាអង់គ្លេស វាបានបង្កជាឧបសគ្គសម្រាប់អ្នកអានដែលជាជនជាតិខ្មែរមួយចំនួនដែលចំណេះដឹងភាសាអង់គ្លេសរបស់ពួកគេនៅមានកម្រិត ខណៈអត្ថបទទាំងនោះជាអត្ថបទជំនាញមានភាពស៊ីជម្រៅខ្លាំង ទាំងពាក្យពេចន៍ឃ្លាប្រយោគ និងទម្រង់វេយ្យាករណ៍។ ហេតុដូច្នេះហើយ ទើបវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជាបានផ្ដួចផ្ដើមគំនិតរៀបចំការបកប្រែទស្សនាវដ្ដី «បច្ចុប្បន្នភាពការទូត» លេខ៣នេះ និងលេខបន្តបន្ទាប់ទៀត ជាភាសាខ្មែរ ដើម្បីផ្ដល់ឱកាសដល់មន្ត្រីរាជការ សិស្ស និស្សិតដែលមិនចេះភាសាអង់គ្លេស អាចអានដើម្បីស្វែងយល់ពីខ្លឹមសារដ៏មានសារៈសំខាន់នៅក្នុងអត្ថបទនានានៃទស្សនាវដ្ដីនេះឱ្យបានទូលំទូលាយ។ គំនិតផ្ដួចផ្ដើមនេះត្រូវបានទទួលការគាំទ្រពីមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា និងវិទ្យាស្ថានខ្មែរ សម្រាប់សហប្រតិបត្តិការនិងសន្តិភាព។

ឆ្លៀតឱកាសនេះ វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា ដែលបានឧបត្ថម្ភសម្រាប់ការបកប្រែទស្សនាវដ្ដីលេខនេះជាភាសាខ្មែរ និងសូមកោតសរសើរដល់សហការីនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជាចំពោះកិច្ចខិតខំប្រឹងប្រែងនានាក្នុងការងារបកប្រែនេះ។ វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជាត្រៀមខ្លួនជានិច្ចក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា សម្រាប់គម្រោងរួមគ្នាដទៃទៀតនាពេលអនាគត៕

**ឯកឧត្តម បណ្ឌិត គិន ភា**
ប្រធានវិទ្យាស្ថានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (IRIC)

# មតិត្រឡប់ភ្លាម។

តើលោកអ្នកចូលចិត្តការចេញផ្សាយនេះដែរឬទេ ? នៅក្នុងមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ (KAS) វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព (CICP) និងវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (IRIC) យើងខ្ញុំចង់ធ្វើឱ្យកាន់តែល្អប្រសើរគ្រប់ពេលវេលា។ ដើម្បីធ្វើឱ្យល្អប្រសើរបន្ថែមទៀតលើការបោះពុម្ពផ្សាយនិងទម្រង់របស់យើងខ្ញុំនោះ យើងខ្ញុំសូមអញ្ជើញលោកអ្នកផ្តល់មតិត្រឡប់របស់លោកអ្នកមកឱ្យខាងយើងខ្ញុំ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះភាពស្មោះត្រង់ ហើយជាការណ៍ពិតយើងខ្ញុំនឹងរក្សាទិន្នន័យរបស់លោកអ្នកទាំងអស់ជាអនាមិកនិងគោរពតាមស្តង់ដារខ្ពស់បំផុតរបស់អឺរ៉ុប។ ស្ថិតនៅក្នុងកូដQR និងតំណដូចខាងក្រោមនេះ លោកអ្នកនឹងរកឃើញការណែនាំដ៏ឆាប់រហ័សមួយដើម្បីបំពេញទម្រង់មតិត្រឡប់។

ទម្រង់អាចចូលទៅបំពេញបានត្រង់នេះ៖

**សូមចុចនៅទីនេះ!**

សូមអរគុណ!

# ចូលរួមពាក់ព័ន្ធ

តើលោកអ្នកចង់រួមចំណែកចំពោះបច្ចុប្បន្នភាពការទូតលេខបន្ទាប់ ស្តីពីការទូតសេដ្ឋកិច្ច និងការចូលរួមបែបស្ថាបនាដែរឬទេ ? ឬលោកអ្នកមានគំនិតបន្ថែមទៀត ? សូមទាក់ទងមកកាន់យើងខ្ញុំដោយសេរី តាមរយៈអ៊ីមែល៖ Maurizio.Paciello@kas.de

សូមអរគុណសម្រាប់ការចំណាយពេលវេលារបស់លោកអ្នកនិងការធ្វើជាផ្នែកមួយនៃសហគមន៍របស់យើងខ្ញុំ។

**ពីក្រុមការងារ KAS, CICP និង IRIC របស់លោកអ្នក**

# មាតិកា


## I. សេចក្តីផ្តើម

ឥណ្ឌូប៉ាស៊ីហ្វិក : តើវាជាមូលហេតុនៃការប្រកួតប្រជែងផ្សេងមួយទៀតនៅក្នុងដែនថ្មីឬ? 8

## II. បទសម្ភាសន៍

**អាល្លឺម៉ង់ ឥណ្ឌូប៉ាស៊ីហ្វិក និងអាស៊ីអាគ្នេយ៍**
បទសម្ភាសន៍ជាមួយឯកឧត្តម Christian Berger ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំព្រះរាជាណាចក្រកម្ពុជា 10

## III. គំនិតសំខាន់

**ជប៉ុន កម្ពុជា និងឥណ្ឌូប៉ាស៊ីហ្វិកសេរី និងបើកចំហ**
ឯកឧត្តម Mikami Masahiro ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា 16

## IV. ទស្សនវិស័យ

១. **ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ : ទស្សនវិស័យកម្ពុជា**
បណ្ឌិត ជីនបូរាណ ច័ន្ទបូរី 22

២. **ចក្ខុវិស័យរបស់អាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក (AOIP) : ការពិភាក្សា ការឆ្លើយតប និងទិសដៅអនាគត**
ពេជ្រ ចារ៉ាឌីន 26

៣. **ការយល់ច្រឡំនៃការទប់ទល់និងយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិក : គោលនយោបាយសហរដ្ឋអាមេរិកឆ្ពោះទៅរកចិន**
បណ្ឌិត Bradley J. Murg 32

៤. **យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកសេរី និងបើកចំហ : លក្ខណៈនិងអនាគតរបស់វា - ទស្សនវិស័យចិន**
Zhang Zijie 36

៥. **ការទូតបែបស្ថាបនារបស់អូស្ត្រាលីក្នុងសម័យកាលនៃការប្រកួតប្រជែង**
សាស្ត្រាចារ្យ Caitlin Byrne 42

៦. **ការលាតត្រដាងជវភាពនៅក្នុងឥណ្ឌូប៉ាស៊ីហ្វិក**
បណ្ឌិត Vijay Sakuja 46

៧. **ទំនោររបស់អឺរ៉ុបចំពោះឥណ្ឌូប៉ាស៊ីហ្វិក**
Isabel Weininger 50

៨. **តំបន់ឥណ្ឌូប៉ាស៊ីហ្វិក : អាទិភាពមួយសម្រាប់ប្រទេសបារាំង**
Laurent Triponey 56

៩. **ឯករាជ្យភាពរូបនីយកម្មនិងប្រភពដើមនៃឥណ្ឌូប៉ាស៊ីហ្វិក**
*Maurizio Paciello* 60

## V. សេចក្តីសង្ខេប 68

# I. សេចក្តីផ្តើម

## ឥណ្ឌូប៉ាស៊ីហ្វិក : តើវាជាមូលហេតុនៃការប្រកួតប្រជែងផ្សេងមួយទៀតនៅក្នុងដែនថ្មីឬ ?




អស់រយៈពេលជាច្រើនទសវត្សរ៍ទៅហើយ ឥណ្ឌូប៉ាស៊ីហ្វិកបានក្លាយជាសមរភូមិយុទ្ធសាស្ត្រចម្បងរវាងសហរដ្ឋអាមេរិក និងចិន។ នៅក្នុងរូបភាព ប្រធានាធិបតី ដូណាល់ ដេត្រាំ បានធ្វើទស្សនកិច្ចនៅប្រទេសវៀតណាម កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៧។

យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកដែលដឹកនាំដោយសហរដ្ឋអាមេរិកត្រូវបានស្នើដោយលោកប្រធានាធិបតី ដូណាល់ ត្រាំ នៅក្នុងកិច្ចប្រជុំកំពូលអេប៉ិច ឆ្នាំ២០១៧ ក្នុងប្រទេសវៀតណាម ដែលជាផ្នែកមួយនៃដំណើរទស្សនកិច្ចរបស់គាត់ក្នុងអាស៊ី។

ការប៉ុនប៉ងរបស់ក្រុងវ៉ាស៊ីនតោន ដើម្បីការពារឥទ្ធិពលរបស់ខ្លួននៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកដ៏ធំទូលាយ នៅក្នុងបរិបទនៃការប្រកួតប្រជែងដ៏តឹងតែងកាន់តែខ្លាំងឡើងជាមួយចិន ក៏បានក្លាយជាប្រធានបទក្តៅគគុកមួយផងដែរចាប់តាំងពីពេលនោះមក។ យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកដែលដឹកនាំដោយសហរដ្ឋអាមេរិកមានប្រភពដើមមកពីយុទ្ធសាស្ត្រនៃកិច្ចសន្ទនាសន្តិសុខចតុភាគី ដែលជាសម្ព័ន្ធភាពយុទ្ធសាស្ត្រមួយ រួមមានសហរដ្ឋអាមេរិក ជប៉ុន ឥណ្ឌា និងអូស្ត្រាលី ហើយជាទូទៅគេជឿជាក់ថា ជាយន្តការមួយដើម្បី «ទប់ទល់» ការងើបឡើងរបស់ចិន។[1,2] ក្រុមអ្នកស្រាវជ្រាវចិនមិនបានជឿជាក់ថា យុទ្ធសាស្ត្រនេះ នឹងបង្កការគំរាមកំហែងធ្ងន់ធ្ងរ ក្នុងអនាគតដ៏ខ្លីទេ ហើយ អ្នកស្រាវជ្រាវខ្លះប្រមើលមើលថា ទស្សនទាននេះ គឺគ្រាន់ជាផ្នែកបន្ថែមនៃយុទ្ធសាស្ត្រ ធ្វើឱ្យមានតុល្យភាពឡើងវិញរបស់សហរដ្ឋអាមេរិកចំពោះតំបន់អាស៊ីតែប៉ុណ្ណោះ ដែលឥឡូវបានពង្រីកដើម្បីរួមបញ្ចូលតំបន់មហាសមុទ្រឥណ្ឌា និងប៉ាស៊ីហ្វិក។[3]

អូស្ត្រាលី ឥណ្ឌា ជប៉ុន និងបារាំង បានចេញផ្សាយនូវទស្សនទាននិងយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិករបស់ខ្លួនក្នុងប៉ុន្មានឆ្នាំថ្មីៗនេះដែរ។ ជប៉ុនមានយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ (FOIP) របស់ខ្លួន ដែលលោកនាយករដ្ឋមន្ត្រី អាបេ បានកំណត់ជាស្នូលនៃគោលនយោបាយអាស៊ីរបស់ប្រទេសជប៉ុន ដោយបង្ហាញពីទិដ្ឋភាពផ្សេងៗនៃសេរីភាពនាវាចរណ៍ នីតិរដ្ឋ សន្តិភាពនិងស្ថិរភាពតំបន់ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទីផ្សារ។ នាយករដ្ឋមន្ត្រីឥណ្ឌា ណារិនដ្រា ម៉ូឌី បានចេញគោលការណ៍ស្នូលចំនួន៦សម្រាប់យុទ្ធសាស្ត្ររបស់ឥណ្ឌាស្តីពីទស្សនទាន

1. Bhavan Jaipragas, “Why is the US calling Asia-Pacific the Indo-Pacific? Donald Trump to ‘clarify,’” South China Morning Post, Nov. 7, 2017, https://www.scmp.com/week-asia/politics/article/2118806/why-us-calling-asia-pacific-indo-pacific-trump-clarify.

2. Abhijit Singh, “The ‘Indo-Pacific’ has always been about containing the rise of China,” South China Morning Post, Nov. 28, 2017, https://www.scmp.com/comment/insight-opinion/article/2121907/indo-pacific-has-always-been-about-containing-rise-china.

3. Dingding Chen, “What China Thinks of the Indo-Pacific Strategy,” The Diplomat, Apr. 27, 2018, https://thediplomat.com/2018/05/what-china-thinks-of-the-indo-pacific-strategy/.

ឥណ្ឌូប៉ាស៊ីហ្វិក អំឡុងកិច្ចសន្ទនាសាំងហ្គ្រីឡា ឆ្នាំ២០១៨ នៅប្រទេសសិង្ហបុរី។ អូស្ត្រាលីបានរៀបចំឯកសារយោងចំនួន៧៤ ចំពោះឥណ្ឌូ-ប៉ាស៊ីហ្វិកនៅក្នុងឯកសារសគោលនយោបាយការបរទេសឆ្នាំ២០១៧ របស់ខ្លួន។

ទោះបីជាគ្មានទស្សនទានណាមួយក្នុងចំណោមទស្សនទានឥណ្ឌូប៉ាស៊ីហ្វិករបស់ប្រទេសទាំងបួន បានបង្ហាញច្បាស់លាស់ពីកត្តាប្រទេសចិនក៏ដោយ ប៉ុន្តែ បណ្ឌិត Tang Siew Mun ដែលជាអ្នកប្រាជ្ញអាស៊ានដ៏ល្បីល្បាញមួយរូបបានបញ្ចេញយោបល់ថា៖

> [...] ទស្សនទាន [ឥណ្ឌូប៉ាស៊ីហ្វិកទាំងបួន] បានបង្ហាញពីចក្ខុវិស័យមានជម្រើសមួយសម្រាប់សណ្តាប់ធ្នាប់តំបន់ដែលកំពុងតែលេចឡើង ដែលនឹងមិនវិលជុំវិញប្រទេសចិនទេ ដូច្នេះអាចការពារការលេចឡើងនៃអនុត្តរភាពរបស់ចិន។ អ្នកគាំទ្រទស្សនទាននេះ បានអះអាងយ៉ាងឆាប់រហ័សថា ពួកគេមិនមែនកំពុងព្យាយាមតាមដានភាពជឿនលឿនផ្នែកការទូត សេដ្ឋកិច្ច និងយុទ្ធសាស្ត្ររបស់ចិននៅក្នុងតំបន់ទេ។ ប៉ុន្តែជាការកំណត់ជំហរទស្សនទានរបស់ពួកគេថាជាការផ្តួចផ្តើមគំនិតប្រកបដោយបរិយាបន្ន និង «មិត្តភាពជាមួយចិន» គឺមិនសមាមាត្រជាមួយនឹងភាពចាំបាច់ខាងយុទ្ធសាស្ត្ររបស់ពួកគេក្នុងការពិនិត្យឥទ្ធិពលកំពុងរះឡើងរបស់ចិនទេ។[4]

នៅឆ្នាំ២០១៩ រដ្ឋមន្ត្រីការពារជាតិបារាំង បានបញ្ចេញគោលនយោបាយសន្តិសុខអាស៊ីប៉ាស៊ីហ្វិករបស់ខ្លួន ដោយហៅថា «បារាំង និងសន្តិសុខក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក»។ គោលនយោបាយនេះមានភាពខុសប្លែកខ្លាំងពីវិធីសាស្ត្ររបស់ភាគីទាំងបួន ប៉ុន្តែគោលនយោបាយនេះបង្ហាញពីចក្ខុវិស័យរបស់បារាំងសម្រាប់ឥណ្ឌូប៉ាស៊ីហ្វិក។

ផ្ទុយទៅវិញ អាស៊ានបានពន្យារពេលក្នុងការប្រកាសពីជំហររបស់ខ្លួនលើទស្សនទានណាមួយនៃទស្សនៈឥណ្ឌូប៉ាស៊ីហ្វិកទាំងបួនដំបូង ដើម្បីជៀសវាងហានិភ័យថា ទស្សនៈខ្លួនកំពុងប្រកាន់យកភាគីណាមួយ។ អាស៊ានបានបត់បែនជុំវិញទស្សនៈផ្សេងៗរបស់ឥណ្ឌូប៉ាស៊ីហ្វិក និងបានអភិវឌ្ឍចក្ខុវិស័យរបស់អាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក (ASEAN Outlook on the Indo-Pacific—AOIP ) ដែលជាវិធីសាស្ត្រមានតុល្យភាពការទូតដែលមិនគាំទ្រ និងមិនជំទាស់យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកផ្សេងៗទៀត។ ចក្ខុវិស័យរបស់អាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក (AOIP) ក៏អាចធ្វើឱ្យអាស៊ានដោះស្រាយជាមួយទិដ្ឋភាពយុទ្ធភូមិសាស្ត្រដែលមានការផ្លាស់ប្តូរឆាប់រហ័ស ធានាថាអាស៊ាននឹងមិននៅក្រៅសង្វៀន និងទាញយកសារៈសំខាន់ផ្នែកយុទ្ធសាស្ត្ររបស់ខ្លួនឡើងវិញក្នុងពេលមានការប្រកួតប្រជែងរបស់មហាអំណាច។

ព្រឹត្តិបត្របច្ចុប្បន្នភាពការទូត មានគោលបំណងបម្រើដល់សហគមន៍ការទូត អ្នករៀបចំគោលនយោបាយ និងភាគីពាក់ព័ន្ធនានា ដែលចាប់អារម្មណ៍លើទំនោរនិងទិដ្ឋភាពប្រឈមថ្មីៗនៅក្នុងសង្វៀនសកលលោក ដែលអាចរារាំងការអភិវឌ្ឍចម្បងនានា ក្នុងប្រទេសកម្ពុជា និងគំរាមកំហែងសន្តិភាពនិងស្ថិរភាពតំបន់ទាំងមូល។ ព្រឹត្តិបត្របច្ចុប្បន្នភាពការទូតនេះ ក៏មានបំណងធ្វើជាវេទិកាមួយសម្រាប់ការផ្លាស់ប្តូរទស្សនៈរបស់បញ្ញវន្តព្រមទាំងសម្រាប់អ្នកប្រាជ្ញខ្មែរនានាដែលកំពុងលេចមុខឡើង ដើម្បីទទួលបានការបោះពុម្ពផ្សាយនូវស្នាដៃស្រាវជ្រាវរបស់ពួកគាត់ផងដែរ។

ការចេញផ្សាយលើកទីបីនេះ ផ្តល់នូវកិច្ចពិភាក្សាដេញដោលប្រកបដោយការត្រិះរិះពិចារណានិងទស្សនៈគួរឱ្យចាប់អារម្មណ៍ស្តីពីទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកនានា។ យើងពិតជាមានមោទនភាពយ៉ាងខ្លាំងចំពោះការបោះពុម្ពផ្សាយនេះ ដោយសារតែវាមានសារៈសំខាន់កាន់តែខ្លាំងក្នុងការធ្វើជាវេទិកាបែបស្ថាបនាមួយសម្រាប់ឥស្សរជន ទាំង Track 1 និង Track 2 ដូចជា អ្នករៀបចំគោលនយោបាយ សហគមន៍ការទូត និងអ្នកសិក្សាស្រាវជ្រាវ ដើម្បីចូលរួមវិភាគចំពោះកិច្ចពិភាក្សានិងការវិភាគ។ យើងសង្ឃឹមថា ការចេញផ្សាយនេះនឹងជួយជំរុញកិច្ចពិភាក្សាឱ្យកាន់តែស៊ីជម្រៅនិងជាក់លាក់លើបញ្ហាប្រឈមនានានិងការតស៊ូផ្នែកគោលនយោបាយការបរទេសសំខាន់ៗ។ យើងសូមស្វាគមន៍ចំពោះកិច្ចពិភាក្សាដេញដោល ទស្សនៈដាស់គំនិត និងទស្សនទានទូលំទូលាយនានាថែមទៀត ដើម្បីបំពេញគោលបំណងនៃការបណ្តុះគំនិតជាក់ស្តែង និងច្បាស់លាស់របស់នៃបច្ចុប្បន្នភាពការទូត។

សូមអញ្ជើញអានដោយរីករាយ!




**ពេជ្រ ចាន់ឌីន**




**Maurizio Paciello**

---

4. Tang Siew Mun, “Asean found its voice with the Indo-Pacific concept. Now it has to use it or risk losing out,” South China Morning Post, June 24, 2019, https://www.scmp.com/week-asia/geopolitics/article/3015809/asean-found-its-voice-indo-pacific-concept-now-it-has-use-it.

# II. បទសម្ភាសន៍

## អាល្លឺម៉ង់នៅក្នុងឥណ្ឌូប៉ាស៊ីហ្វិក



© Mr. Christian Berger

### កិច្ចសម្ភាសន៍ជាមួយ ឯកឧត្តមឯកអគ្គរដ្ឋទូត Christian Berger

ឯកឧត្តមឯកអគ្គរដ្ឋទូត Christian Berger គឺជាឯកអគ្គរដ្ឋទូតរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំព្រះរាជាណាចក្រកម្ពុជា។ ឯកអគ្គរដ្ឋទូត Berger កើតនៅប្រទេសអេស្ប៉ាញក្នុងឆ្នាំ១៩៥៦។ បន្ទាប់ពីបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ Jesuite College ក្នុងទីក្រុង Bonn ឆ្នាំ១៩៧៤ ឯកឧត្តមបានចូលបម្រើកងទ័ព និងហាត់ការងារផ្នែកធនាគារ ហើយឯកឧត្តមបានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ចនៅសាកលវិទ្យាល័យ Cologne។ មុនចូលបម្រើការនៅក្នុងការិយាល័យការបរទេសអាល្លឺម៉ង់ក្នុងឆ្នាំ១៩៨៦ ឯកឧត្តមបានបម្រើការងារនៅធនាគារ Deutsch-Südamerikanische ក្នុងទីក្រុង Hamburg រយៈពេល២ឆ្នាំ។ បេសកកម្មក្នុងប្រទេសរបស់ឯកឧត្តមរួមមាន ២ឆ្នាំ នៅក្នុងការិយាល័យឯកជនរបស់រដ្ឋមន្ត្រី និង ៥ឆ្នាំ ជាជំនួយការផ្ទាល់សម្រាប់រដ្ឋលេខាធិការមួយរូបក្នុងចំណោមរដ្ឋលេខាធិការពីររូប។ ឯកឧត្តមបានបម្រើការងារជានាយកផ្នែកអាស៊ីអាគ្នេយ៍ និងទទួលខុសត្រូវអនុនាយកដ្ឋានពាណិជ្ជកម្មបរទេស។ បេសកកម្មក្រៅប្រទេសរបស់ឯកឧត្តមរួមមាននៅ ម៉ាឡេស៊ី និងព្រុចសែល (រដ្ឋ និងសហភាពអឺរ៉ុប)។ ក្នុងឆ្នាំ២០០០ ឯកឧត្តមទទួលបានការតែងតាំងជាឯកអគ្គរដ្ឋទូតប្រចាំប្រទេសឡាវ ជាមួយនឹងបេសកកម្មក្រោយមកទៀតប្រចាំប្រទេសអេក្វាទ័រ និងអ៊ីរ៉ាក់។ ពីឆ្នាំ ២០១៦ ដល់ ២០១៩ ឯកឧត្តមបម្រើការជាឯកអគ្គរដ្ឋទូតប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម។ ក្នុងខែកញ្ញា ឆ្នាំ២០១៩ ឯកឧត្តមទទួលបានការតែងតាំងជាឯកអគ្គរដ្ឋទូតប្រចាំព្រះរាជាណាចក្រកម្ពុជា។



### លោក Robert Hör

បច្ចុប្បន្ន Robert Hör គឺជាអ្នកគ្រប់គ្រងកម្មវិធីសម្រាប់ការផ្លាស់ប្តូរឌីជីថលនៅមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ។ ក្នុងនាមជាអ្នកគ្រប់គ្រងឌីជីថលនិងអ្នកវិទ្យាសាស្រ្តនយោបាយតាមរយៈការបណ្តុះបណ្តាល លោកទទួលបន្ទុកកម្មវិធីបណ្តុះបណ្តាលជាច្រើន, ការអភិវឌ្ឍផលិតផល គម្រោងស្រាវជ្រាវនិងទម្រង់ កិច្ចសន្ទនានានារវាងភាគីពាក់ព័ន្ធកម្ពុជា ព្រមទាំងជាអ្នកជំនាញក្នុងតំបន់និងអាល្លឺម៉ង់។ ការស្រាវជ្រាវរបស់លោកផ្តោតលើ ការអភិវឌ្ឍឌីជីថល ការចាប់ផ្តើមអាជីវកម្ម និងការអភិវឌ្ឍស្ថាប័ន។

នៅថ្ងៃទី២៧ ខែមេសា ឯកឧត្តម Christian Berger ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញអង្គុយសំណេះសំណាលជាមួយលោក Robert Hör នាយកកម្មវិធីមូលនិធិខុនរ៉ាដអាដិណៅអ៊ែរប្រចាំកម្ពុជា ដើម្បីពិភាក្សាពីគោលការណ៍ណែនាំគោលនយោបាយដែលបានអនុម័តថ្មីៗ របស់អាល្លឺម៉ង់ សម្រាប់ឥណ្ឌូប៉ាស៊ីហ្វិក និងឥទ្ធិពលរបស់គោលការណ៍ណែនាំគោលនយោបាយលើតំបន់អាស៊ីអាគ្នេយ៍។ បទសម្ភាសន៍នេះត្រូវបានរៀបចំដោយលោក Maurizio Paciello នាយកកម្មវិធីមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ ។

**លោក Robert Hör :** តើមានមូលហេតុអ្វីខ្លះនៅពីក្រោយការបង្កើត «គោលការណ៍ណែនាំគោលនយោបាយសម្រាប់ឥណ្ឌូប៉ាស៊ីហ្វិក» របស់អាល្លឺម៉ង់ ?

**ឯកអគ្គរដ្ឋទូត Berger :** ជាកិច្ចចាប់ផ្តើម ខ្ញុំគិតថា មានប្រយោជន៍សម្រាប់ការអត្ថាធិប្បាយឱ្យច្បាស់លាស់មួយចំនួន៖

អាល្លឺម៉ង់មិនមែនជាមហាអំណាចមួយដែលចូលរួមនៅក្នុងអ្វីដែលហៅថា «ជាល្បែងមហាអំណាចថ្មី» នោះទេ។ គោលនយោបាយការបរទេសរបស់អាល្លឺម៉ង់គឺជាលទ្ធផលចេញពីប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ។ មេរៀនប្រវត្តិសាស្ត្រនិងភូមិសាស្ត្របានធ្វើឱ្យប្រទេសអាល្លឺម៉ង់កប់យ៉ាងជ្រៅក្នុងភាពជាដៃគូអន្តរអាត្លង់ទិក និងសហភាពអឺរ៉ុប។

ហេតុនេះការយល់ដឹងស៊ីជម្រៅអំពីការគ្រប់គ្រងវិបត្តិ និងសហភាពអឺរ៉ុបនៅក្នុងបរិបទអឺរ៉ុប ក៏ដូចជាការរក្សាទំនាក់ទំនងអន្តរអាត្លង់ទិកប្រកបដោយផ្លែផ្កា បានគ្របដណ្តប់លើរបៀបវារៈគោលនយោបាយការបរទេសអាល្លឺម៉ង់ជាយូរមកហើយ ហើយក៏នឹងបន្តធ្វើបែបនេះតទៅទៀត។

ប៉ុន្តែ ដោយជាប្រទេសមានទំហំមធ្យម ដែលផលិតផលក្នុងស្រុកសរុបពឹងផ្អែកខ្លាំងលើការនាំចេញ អាល្លឺម៉ង់មិនអាចធ្វើមិនដឹងមិនឮពីការអភិវឌ្ឍនានានៅក្នុងតំបន់ផ្សេងទៀតរបស់ពិភពលោកទេ ជាពិសេសប្រទេសនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកជាមួយនឹងសក្តានុពល និងបញ្ហាទាំងអស់របស់តំបន់នោះ។

គោលការណ៍ណែនាំស្តីពីឥណ្ឌូប៉ាស៊ីហ្វិកគឺជាការប៉ុនប៉ងដើម្បីទាញសន្និដ្ឋានឱ្យបានត្រឹមត្រូវលើសារៈសំខាន់ ដែលបានកើនឡើងយ៉ាងខ្លាំងសម្បើមនៃតំបន់ឥណ្ឌូប៉ាស៊ីហ្វិក  ទាំងផ្នែកសេដ្ឋកិច្ច នយោបាយ សង្គម និងវប្បធម៌។

**លោក Hör :** អាល្លឺម៉ង់មានទស្សនទានគោលនយោបាយការបរទេសថ្នាក់តំបន់មួយចំនួនកាលពីអតីតកាល។ តើគោលការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិកនេះខុសប្លែកពីទស្សនទានពីមុនៗ ដែរឬទេ ?

**ឯ.ឧ. Berger :** បាទ ពិតប្រាកដណាស់។ វិធីសាស្ត្រមានភាពស៊ីជម្រៅកាន់តែខ្លាំងឡើង។

គោលការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិកចាប់ផ្តើមដោយកំណត់ពីផលប្រយោជន៍ និងគោលការណ៍នានាដែលធ្វើលើសពីទស្សនទានកាលពីមុន។  គោលការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិក ងាកចេញពីវិធីសាស្ត្រប្រពៃណីដែលភាគច្រើនពិពណ៌នាពីរចនាសម្ព័ន្ធ តួអង្គ និងភារកិច្ចដែលមានស្រាប់។ ផ្ទុយទៅវិញ គោលកាណ៍ណែនាំនេះរៀបចំគំនិតផ្តួចផ្តើមនៃគោលនយោបាយការបរទេសជាក់លាក់ច្រើនជាង ២០ច្បាប់ រួមទាំងបំបែកគំនិតផ្តួចផ្តើមទាំងនោះជាគោលដៅរង និងវិស័យគោលនយោបាយដែលបានកំណត់ច្បាស់លាស់។

សូមអនុញ្ញាតឱ្យខ្ញុំដកស្រង់សម្តីលោករដ្ឋមន្ត្រីការបរទេសសហព័ន្ធ Heiko Mass ថា៖ «សេចក្តីសង្ឃឹមរបស់ខ្ញុំគឺថា វានឹងជំរុញកិច្ចពិភាក្សាក្នុងសង្វៀននយោបាយ សង្គម និងផ្នែកស្រាវជ្រាវ និងបង្កើតការផ្លាស់ប្តូរកម្រិតខ្ពស់ជាមួយដៃគូរបស់យើងនៅក្នុងតំបន់»។ គោលបំណងជំរុញកិច្ចពិភាក្សានិងឆន្ទៈដើម្បីធ្វើសមាហរណកម្មតួអង្គមិនមែនជារដ្ឋទៅក្នុងការរៀបចំស្នូលទំនាក់ទំនងរបស់យើងជាមួយតំបន់ ព្រមទាំងធ្វើឱ្យមានភាពរីកចម្រើនជាក់លាក់ផងដែរ នៅពេលប្រៀបធៀបគោលការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិកជាមួយទស្សនទានតំបន់ពីមុនៗ។




ឯកឧត្តម ឯកអគ្គរដ្ឋទូត Berger៖ «អាល្លឺម៉ង់តែងតែទទួលស្គាល់គុណតម្លៃដ៏ធំសម្បើមរបស់អាស៊ានក្នុងបរិបទឥណ្ឌូប៉ាស៊ីហ្វិក»។ នៅក្នុងរូបថត ឯកឧត្តម ឯកអគ្គរដ្ឋទូត Berger កំពុងធ្វើទស្សនកិច្ចគម្រោងអភិរក្សរបស់អាជ្ញាធរអប្សរាដែលផ្តល់មូលនិធិដោយអាល្លឺម៉ង់នៅក្នុងបរិវេណប្រាសាទអង្គរវត្ត។

ជាក់ស្តែងវិធីសាស្ត្រនេះកាន់តែលំបាកក្នុងការគ្រប់គ្រង។ ប្រសិនអ្នកកំណត់ផលប្រយោជន៍និងគោលការណ៍ហើយ អ្នកអាចរងការជំទាស់។ ប្រសិនអ្នកកំណត់គំនិតផ្តួចផ្តើមអ្នកក៏ត្រូវកំណត់ចំណុចគោល។ ប្រសិនអ្នកមានបំណងពាក់ព័ន្ធនឹងតួអង្គច្រើន ការសម្រេចចិត្តនិងការអនុវត្តក៏កាន់តែស្មុគស្មាញ ហើយប្រសិនអ្នកចូលប្រឡូកក្នុងវិស័យគោលនយោបាយដូចជាការពង្រឹងសន្តិភាព សន្តិសុខនិងស្ថិរភាព អ្នកគឺធ្វើលើសពីវិធីសាស្ត្របែបប្រពៃណីរបស់អាល្លឺម៉ង់ទាក់ទិនទៅនឹងស្នូលទំនាក់ទំនងហើយ។ ជាថ្មីម្តងទៀត ខ្ញុំសូមដកស្រង់សម្តីរដ្ឋមន្ត្រីការបរទេសសហព័ន្ធ Heiko Mass៖ «អាល្លឺម៉ង់ត្រូវបង្ហាញពីក្តីកង្វល់លើបញ្ហាសន្តិសុខដែលកើតមានរបស់ដៃគូយូរអង្វែងរបស់ខ្លួនឱ្យកាន់តែខ្លាំងឡើង ត្រូវមានការចូលរួមនៅក្នុងការរិះរកការឆ្លើយតប និងធ្វើឱ្យមានការចូលរួមចំណែកជាក់ស្តែងដូចជាការចែករំលែកបទពិសោធនិងជំនាញ ជាមួយការត្រួតពិនិត្យការនាំចេញសព្វាវុធប្រកបដោយទំនួលខុសត្រូវដែលត្រូវយកមកគិតគូរផងដែរពីគុណភាពទំនាក់ទំនងជាយុទ្ធសាស្ត្រជាមួយប្រទេសក្នុងតំបន់ ជាមួយគំនិតផ្តួចផ្តើមក្នុងវិស័យនៃការត្រួតពិនិត្យសព្វាវុធ និងការចូលរួមផងដែរនៅក្នុងសមយុទ្ធនិងវិធានការសន្តិសុខរួមនានាដើម្បីការពារសណ្តាប់ធ្នាប់ផ្អែកលើច្បាប់នៅពេលអនុវត្តដំណោះស្រាយរបស់អង្គការសហប្រជាជាតិ»។

**លោក Hör :** តើមានការជំពាក់ទាក់ទងជាក់ស្តែងអ្វីខ្លះ នៃគោល-ការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិកសម្រាប់អាស៊ាន និងតំបន់អាស៊ីអាគ្នេយ៍ ?

**ឯ.ឧ. Berger :** អាល្លឺម៉ង់តែងតែទទួលស្គាល់ពីគុណតម្លៃដ៏ធំសម្បើមរបស់អាស៊ាននៅក្នុងបរិបទឥណ្ឌូប៉ាស៊ីហ្វិក។ ដូច្នេះវាមិនមានអ្វីភ្ញាក់ផ្អើលទេ ដែលការចូលរួមទល់មុខគ្នាជាមួយអាស៊ានស្ថិតនៅលើគេក្នុងបញ្ជីគំនិតផ្តួចផ្តើមរបស់យើង។ ការពង្រីកកិច្ចសហ-ប្រតិបត្តិការជាមួយស្ថាប័នអាស៊ាននិងការបន្តការគាំទ្រលេខាធិការដ្ឋានអាស៊ាន ដែលជាការលើកកម្រិតដែលអាចធ្វើទៅបាននៃភាពជាដៃគូអភិវឌ្ឍន៍ ទៅជាភាពជាដៃគូកិច្ចសន្ទនា ពីឋានៈអ្នកសង្កេតការណ៍នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក (ADMM+) គឺស្ថិតក្នុងចំណោមលក្ខណៈទ្វេភាគីនានា។ ប៉ុន្តែដើម្បីពង្រឹងតួនាទីរបស់សហភាពអឺរ៉ុបក្នុងនាមជាដៃគូមួយរបស់អាស៊ាន ការធ្វើឱ្យប្រសើរឡើងនៃទំនាក់ទំនងសហភាពអឺរ៉ុប-អាស៊ានទៅរកភាពជាដៃគូយុទ្ធសាស្ត្រ គឺជារឿងចម្បង។ ឥឡូវអ្នកអាចនិយាយថាមានគំនិតផ្តួចផ្តើមមួយដែលអ្នកបានផ្តល់រួចហើយ។ ហើយវាជារឿងពិតពាក់ព័ន្ធនឹងគោលការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិក ការសម្រេចចិត្តលើកកម្ពស់ទៅរកភាពជាដៃគូយុទ្ធសាស្ត្រ គឺជាសមិទ្ធផលដ៏ធំជាងគេក្នុងការធ្វើជាប្រធានសហភាពអឺរ៉ុបរបស់អាល្លឺម៉ង់ដែលបានបញ្ចប់ថ្មីៗនេះ។ ប៉ុន្តែ ឥឡូវភារកិច្ចពិតប្រាកដមកដល់ហើយ របៀបប្រើប្រាស់ក្របខណ្ឌថ្មីនេះឱ្យបានល្អបំផុត!




© Flickr/ASEAN Secretariat

ឯកឧត្តម ឯកអគ្គរដ្ឋទូត **Berger :** «ប្រហែលជា 'ការបង្កាត់ពូជ' គឺជាវិធីដ៏ល្អជាងគេដើម្បីពិពណ៌នាពីកិច្ចខំប្រឹងប្រែងទ្វេភាគីអាល្លឺម៉ង់ និងសហភាពអឺរ៉ុបនៅក្នុងវិស័យនេះ [ឥណ្ឌូប៉ាស៊ីហ្វិកនិងអាស៊ាន]»។ នៅក្នុងរូបភាព  តំណាងនានាមកពីសហភាពអឺរ៉ុបនិងអាស៊ានជួបប្រជុំអនឡាញសម្រាប់ការប្រកាសដាក់ឱ្យដំណើរការ «សៀវភៅខៀវសហភាពអឺរ៉ុប-អាស៊ានឆ្នាំ២០២១ : ដៃគូយុទ្ធសាស្ត្រ» កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២១។

**លោក Hör :** ឯកឧត្តមបានមានប្រសាសន៍ពីតួនាទីរបស់អាល្លឺម៉ង់ជាប្រធានសហភាពអឺរ៉ុប ដែលបានបញ្ចប់ថ្មីៗនេះ។ តើគោលការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិកស្របគ្នាជាមួយនឹងគោលនយោបាយសហ-ភាពអឺរ៉ុបយ៉ាងដូចម្តេច ទាក់ទិននឹងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកនិយាយជារួម និងអាស៊ាននិយាយដោយឡែកនោះ ?

**ឯ.ឧ. Berger :** ប្រហែលជា «ការបង្កាត់ពូជ» គឺជាវិធីដ៏ល្អជាងគេដើម្បីពិពណ៌នាពីកិច្ចខំប្រឹងប្រែងទ្វេភាគីអាល្លឺម៉ង់និងសហភាពអឺរ៉ុបនៅក្នុងវិស័យនេះ។ ទាក់ទិននឹងតំបន់ជាទូទៅលោក Josep Borell បានមានប្រសាសន៍នាពេលថ្មីៗនេះថា៖ «សហភាពអឺរ៉ុបត្រូវការវិធីសាស្ត្រជាយុទ្ធសាស្ត្រមួយសម្រាប់ឥណ្ឌូប៉ាស៊ីហ្វិក»។ ដោយឡែក

សម្រាប់អាស៊ានវិញសម្រង់សម្ដីពីរអាចបង្ហាញពីគំនិតប្រហាក់ប្រហែលគ្នាប៉ុនណារវាងទីក្រុងបែរឡាំងនិងព្រុចសែលៈ

ក្នុងឱកាសនៃការសម្រេចចិត្តភាពជាដៃគូយុទ្ធសាស្ត្ររដ្ឋមន្ត្រី Mass បានប្រកាសថា៖ «ភាពជាដៃគូយុទ្ធសាស្ត្រតំណាងឱ្យជំនឿរួមគ្នារបស់យើងក្នុងពហុភាគីនិយម គ្មានប្រទេសណាមួយគួរត្រូវបង្ខំឱ្យសម្រេចចិត្តរវាងប៉ូលទាំងពីរនោះទេ។ ភាពជាដៃគូយុទ្ធសាស្ត្រនេះក៏តំណាងឱ្យការតស៊ូមតិរួមគ្នាសម្រាប់ផលប្រយោជន៍រួមគ្នារបស់សហភាពអឺរ៉ុបនិងអាស៊ាន» ហើយសម្រាប់លោក Josep Borell វិញបាននិយាយថា៖ «ភាពជាដៃគូរបស់យើងលែងជាភាពល្អប្រណិតហើយ ប៉ុន្តែជាភាពចាំបាច់វិញ»។

**លោក Hör :** ឯកឧត្តមមិនបានលើកឡើងអំពីប្រទេសចិនទេ? តើចិន ចូលចុះនឹងគោលការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិកដោយរបៀបណាទៅ?

**ឯ.ឧ. Berger :** រដ្ឋាភិបាលអាល្លឺម៉ង់មិនមើលឃើញការទប់ទល់ឬការបំបែកជាជម្រើសដែលអាចប្រើការបាននោះទេ។ ហើយប្រទេសចិនមានការជាប់ពាក់ព័ន្ធធំជាងគេជាមួយសេដ្ឋកិច្ចអាល្លឺម៉ង់។ ប៉ុន្តែវាជាភារកិច្ចលំបាកមួយដែលចិនត្រូវតែជឿជាក់ថា វាជាផលប្រយោជន៍របស់ខ្លួនផ្ទាល់ដើម្បីដើរតាមគោលដៅស្របច្បាប់របស់ខ្លួនក្នុងក្របខណ្ឌពហុភាគី រួមមានការចូលរួមចំណែកជាក់ស្ដែងក្នុងការអភិវឌ្ឍសណ្ដាប់ធ្នាប់ផ្អែកលើច្បាប់បន្ថែមទៀតដែលអាចទទួលយកបានចំពោះភាគីផ្សេងៗទៀត។

**លោក Hör :** តើភូមាចូលចុះនឹងទំនាក់ទំនងសហភាពអឺរ៉ុប-អាស៊ានយ៉ាងដូចម្ដេចដែរ?

**ឯ.ឧ. Berger :** សហភាពអឺរ៉ុបនិងសមាជិករបស់ខ្លួនតែងតែបានទទួលស្គាល់និងគោរពគុណតម្លៃបន្ថែម របស់មជ្ឈភាពអាស៊ាន។ ដោយសារហេតុនេះកិច្ចខំប្រឹងប្រែងដ៏ខ្លាំងក្លាបច្ចុប្បន្នដែលអាស៊ាននិងរដ្ឋសមាជិករបស់ខ្លួនបានធ្វើ សហភាពអឺរ៉ុបក៏បានស្វាគមន៍និងគាំទ្រផងដែរ។ មានការផ្លាស់ប្ដូរផ្ទៃក្នុងយ៉ាងខ្លាំងក្លារវាងតួអង្គសហភាពអឺរ៉ុបនិងអាស៊ាន។ នៅពេលដំណាលគ្នានេះសហភាពអឺរ៉ុបបានចៀសវាងក្នុងការទទួលយកទម្រង់ណាមួយដែលខ្លាំងពីខាងក្រៅផងដែរ។

**លោក Hör :** ហេតុអ្វីបានជាអាល្លឺម៉ង់សង្កត់ខ្លាំងលើរចនាសម្ព័ន្ធពហុភាគី និងសណ្ដាប់ធ្នាប់អន្តរជាតិផ្អែកលើច្បាប់?

**ឯ.ឧ. Berger :** យ៉ាងហោចណាស់មានហេតុផលពីរសម្រាប់រឿងនេះ ហេតុផលទីមួយគឺ រចនាសម្ព័ន្ធ ពហុភាគីដែលរឹងមាំជាធម្មតាផ្ដល់នូវស្ថិរភាពខ្លាំងជាងចំពោះប្រព័ន្ធអន្តរជាតិ។ ហេតុផលមួយផ្សេងទៀតគឺថា នៅសតវត្សរ៍ទី២១ មានបញ្ហាច្រើនណាស់ឆ្លងព្រំដែនប្រទេស ដូច្នេះបញ្ហាទាំងនេះមិនអាចដោះស្រាយបានក្នុងក្របខណ្ឌគោលនយោបាយថ្នាក់ជាតិបានទេ។ សូមយករឿងអស្ថិរភាពកាន់តែខ្លាំងឡើងនៃផ្លូវទឹកនៅក្នុងប្រព័ន្ធទន្លេមេគង្គជាឧទាហរណ៍ចុះ។ អស្ថិរភាពនេះមិនត្រឹមតែដោយសារមានការស្តុកទឹកនៃទំនប់នៅផ្នែកខាងលើប៉ុណ្ណោះទេ។ ចំណែកទឹករបស់ប្រទេសចិននៅក្នុងតំបន់ស្តុកទឹកមានចំនួនតិចជាង២០%។ អស្ថិរភាពភាគច្រើនគឺដោយ សារការកាប់បំផ្លាញព្រៃឈើនៅតំបន់ខាងក្រោមអាងទន្លេ។ ប្រសិនគម្របព្រៃឈើក្នុងប្រទេសថៃ ឡាវ កម្ពុជា និងផ្នែកមួយចំនួននៃវៀតណាមភាគខាងត្បូងនៅដូចកាលពី២៥ឆ្នាំមុនវិញនោះ ព្រៃឈើនឹងដើរតួដូចជាអេប៉ុងនៅក្នុងរដូវវស្សាដែលស្តុកទឹកនិងបញ្ចេញទឹកវិញសន្សឹម ៗ។ ឥឡូវយើងមានមូលហេតុអ្វីដែលមានការកាត់ព្រៃឈើទាំងនេះនិងមូលហេតុអ្វីដែលបានសាងសង់ទំនប់ឡើងហើយ។ ប៉ុន្តែតើវាសមហេតុផលទេដើម្បីអភិវឌ្ឍទស្សនទានប្រមូលផលព្រៃឈើរយៈពេលវែងដើម្បីដោះដូរការកាប់ឈើតាមបែបប្រពៃណី ដោយទាំងអាជីវកម្មធំៗ និងដោយទាំងការអនុវត្តកាប់ និងដុតតាមបែបប្រពៃណីនោះ? ហើយតើយើងមិនមានថាមពលកកើតឡើងវិញដែលធ្វើឱ្យទំនប់សម្រាប់អគ្គិសនីក្លាយជាឥតប្រយោជន៍វិញទេឬ? រាជរដ្ឋាភិបាលកម្ពុជាហាក់ដូចជាគិតបែបនេះហើយ ទើបបានបោះបង់ចោលគម្រោងថាមពលវារីអគ្គិសនីសម្បូរ/ស្ទឹងត្រែង។

នៅពេលដំណាលគ្នា ប្រទេសកម្ពុជាតែឯងនឹងមិនមានលទ្ធភាពដើម្បីបញ្ច្រាសទំនោរអវិជ្ជមានដោយការអនុវត្តវិធានការថ្នាក់ជាតិសុទ្ធសាធនោះទេ។ អ្វីដែលត្រូវការជាចាំបាច់គឺថាប្រទេសនៅជាប់ទន្លេទាំងឡាយត្រូវកំណត់ផលប្រយោជន៍រួមនិងផ្ដល់ទំនុកចិត្តដល់ស្ថាប័នមួយដូចជាគណៈកម្មាធិការទន្លេមេគង្គ ដើម្បីអភិវឌ្ឍ និងអនុវត្តគោលនយោបាយរួមរយៈពេលវែងមួយដែលគ្មានប្រទេសណាប្រកាន់ជំហរជិះសេះលែងដៃនោះឡើយ។ គណៈកម្មាធិការទន្លេមេគង្គក៏មានសមាជិកមិនស្ថិតនៅក្នុងតំបន់ដែរ។ ហេតុអ្វីមិនទៅចូលទៅរកប្រទេសទាំងនោះតាមប្រព័ន្ធ ដូចជាអាល្លឺម៉ង់ ដើម្បីរៀនពីរបៀបត្រូវធ្វើយ៉ាងម៉េចលើគោលនយោបាយព្រៃឈើនិងថាមពលកកើតឡើងវិញ ដែលជាការចូលរួមចំណែក ដើម្បីរក្សាស្ថិរភាពប្រព័ន្ធទន្លេមេគង្គ? ហេតុអ្វីបានជាខ្ញុំនិយាយលម្អិតពីរឿងនេះ? ដោយសារខ្ញុំយល់ឃើញថាវាមានប្រយោជន៍ច្រើនចំពោះអ្នកអាន ដើម្បីឆ្លុះបញ្ចាំងលើបញ្ហាជាក់ស្ដែងគ្រាន់ជាងដើម្បីអានពាក្យ សម្ដីល្បីៗស្ដីពីគុណតម្លៃពហុភាគីនិយម។

**លោក Hör :** មកដល់ពេលនេះ ឯកឧត្តមបានផ្ដោតលើរូបភាពធំជាង។ តើគោលការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិកមានឥទ្ធិពលលើទំនាក់ទំនងអាល្លឺម៉ង់ជាមួយកម្ពុជាឬទេ ហើយបើមានតើមានយ៉ាងដូចម្ដេចដែរ?

**ឯ.ឧ. Berger :** គោលការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិកមានគោលបំណងបញ្ចូលពហុភាគីជាមួយទ្វេភាគី គោលការណ៍ណែនាំនេះទទួលស្គាល់យ៉ាងច្បាស់លាស់ពីភាពពាក់ព័ន្ធនៃតួអង្គទាំងអស់ដោយមិនគិតពីទំហំរបស់ពួកគេទេ។ មិនត្រឹមតែប៉ុណ្ណោះទេស្ថានទូតទាំងឡាយនៅក្នុងតំបន់ក៏ត្រូវបានស្នើឱ្យធ្វើសំណើរលើរបៀបធ្វើយ៉ាងម៉េចឱ្យទំនាក់ទំនងទ្វេភាគីកាន់តែខ្លាំងឡើង។ នៅក្នុងករណីប្រទេសកម្ពុជាសម័យបច្ចុប្បន្ន យើងទាំងពីរមានមូលដ្ឋានរឹងមាំណាស់ និងមានសក្ដានុពលធ្វើជាមួយគ្នាជាច្រើន។

**លោក Hör :** តើឯកឧត្តមកំពុងសំដៅលើអ្វីដែរ?

**ឯ.ឧ. Berger :** មូលដ្ឋានដើម្បីកសាង គឺភាពជាដៃគូអភិវឌ្ឍន៍រយៈពេលវែង។ វាផ្ដោតលើវិស័យពាក់ព័ន្ធខ្លាំងចំនួនបី៖

វិស័យទីមួយគឺការកសាងធាតុនានានៃហេដ្ឋារចនាសម្ព័ន្ធសង្គមមួយដែលកាន់តែទំនើប។ ប្រព័ន្ធកំណត់អត្តសញ្ញាណជនក្រីក្រដើម្បី

កំណត់អត្តសញ្ញាណនិងគាំទ្រអ្នកដែលរងប៉ះពាល់បំផុតដោយវិបត្តិជំងឺកូវីដ១៩គឺពឹងផ្អែកលើជំនាញការអាល្លឺម៉ង់ ហើយលទ្ធផលរយៈពេលខ្លីដែលសមនឹងស្វាគមន៍បំផុតនៃកិច្ចសហប្រតិបត្តិការទ្វេភាគីគឺការតម្រង់បង្កើតគ្រោងការធានារ៉ាប់រងសង្គមពេញលេញមួយនៅក្នុងរយៈពេលវែង។

វិស័យក្នុងការចាត់សកម្មភាពទីពីរដែលនឹងក្លាយជារឿងពាក់ព័ន្ធកាន់តែខ្លាំងដើម្បីអូសទាញប្រទេសកម្ពុជាចេញពីឱនភាពសេដ្ឋកិច្ចដោយសារកូវីដនិងបើកច្រកថ្មីសម្រាប់ការលូតលាស់គឺជាកិច្ចសហប្រតិបត្តិការរបស់យើងដើម្បីអភិវឌ្ឍគោលនយោបាយនិងរចនាសម្ព័ន្ធនានាសម្រាប់វិស័យសេដ្ឋកិច្ចដែលទំនងទទួលជោគជ័យជាងគេ។




ក្រុមការងារមកពី GIZ កំពុងប្រើកម្មវិធី ដើម្បីចុះឈ្មោះបេក្ខជន និងគ្រួសាររបស់គាត់សម្រាប់ជំនួយបន្ទាន់ប្រចាំគ្រួសារ។ កម្មវិធីនេះប្រើប្រាស់ប្រព័ន្ធ និងមូលដ្ឋានទិន្នន័យដូចគ្នានឹងប្រព័ន្ធកំណត់អត្តសញ្ញាណជនក្រីក្រ ដើម្បីពង្រីកការគាំទ្រដល់ក្រុមងាយរងគ្រោះផ្សេងទៀត។

វិស័យទីបី នៃកិច្ចសហប្រតិបត្តិការគឺវិមជ្ឈការ ដែលអាល្លឺម៉ង់មានសំណើច្បាស់លាស់ពីរាជរដ្ឋាភិបាលនោះ កំពុងផ្តល់ជំនាញការសម្រាប់ការពង្រឹងសេវាកម្មនានារបស់រដ្ឋបាលថ្នាក់ស្រុក និងការធ្វើឱ្យប្រសើរឡើងនៃអន្តរកម្មរវាងប្រជាពលរដ្ឋ និងស្ថាប័នរដ្ឋបាលថ្នាក់ស្រុក។

កិច្ចសហប្រតិបត្តិការរយៈពេលវែងនៅក្នុងវិស័យទាំងបីនេះ គឺពិតជាមានគុណតម្លៃមហិមា។ លើសពីនេះទៀត កិច្ចសហប្រតិបត្តិការនេះផ្តល់ឱ្យយើងនូវជម្រើសទៅមុខបន្តទៀត។ ខ្ញុំបាននិយាយរួចហើយពីការប្រើប្រាស់រចនាសម្ព័ន្ធកំណត់អត្តសញ្ញាណជនក្រីក្រដោយជោគជ័យសម្រាប់ការរៀបចំនិងការគ្រប់គ្រងការចំណាយទៅឱ្យអ្នកដែលរងប៉ះពាល់បំផុតដោយវិបត្តិបច្ចុប្បន្ន។ ឧទាហរណ៍មួយផ្សេងទៀត៖ ការកសាងគម្រោងគោលនយោបាយសេដ្ឋកិច្ចតាមវិស័យដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយតួអង្គដែលមានចំណាប់អារម្មណ៍ផ្សេងទៀត ខ្ញុំបានផ្តួចផ្តើមគំនិតការអភិវឌ្ឍក្របខណ្ឌស្ថាប័នមួយដើម្បីគាំទ្រការពង្រីកផលិតផលកសិកម្មនិងកសិឧស្សាហកម្មទៅទីផ្សារអាល្លឺម៉ង់/សហភាពអឺរ៉ុប។

ទោះបីជាយ៉ាងណា ករណីដែលពិសេសជាងគេនៃវិធានការបំពេញបន្ថែមនោះគឺសំណើគម្រោង ដែលសហការីម្នាក់ក្នុងចំណោមសហការីស្ថានទូតជាច្រើនរបស់ខ្ញុំបានធ្វើ ដោយមានបំណងក្នុងការធ្វើឱ្យការងារប្រសើរឡើងថែមទៀតសម្រាប់មន្ត្រីនគរបាលក្នុងស្រុក និងអន្តរកម្មរបស់ពួកគាត់ជាមួយសាធារណជនក្នុងស្រុក។ កិច្ចសហប្រតិបត្តិការជាមួយកងកម្លាំងនគរបាល គឺជាវិស័យថ្មីមួយទាំងស្រុងនៃកិច្ចសហប្រតិបត្តិការទ្វេភាគី។ ប្រសិនគម្រោងដំណើរការទៅល្អ វាអាចក្លាយជាការបោះជំហានទៅមុខសម្រាប់គម្រោងជាច្រើនទៀត។

លក្ខណៈពិសេសថ្មីមួយរបស់គោលការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិកគឺជាភារកិច្ចច្បាស់លាស់ដែលបានប្រគល់ទៅឱ្យស្ថានទូតនានាដើម្បីពិនិត្យជម្រើសដែលអាចបត់បែនបានសម្រាប់វិស័យទាំងអស់នៃទំនាក់ទំនងរបស់យើង។ ពាក់ព័ន្ធនឹងវិស័យស្រាវជ្រាវវិញ ស្ថានទូតបានចាប់ផ្តើមប្រមូលចំណែកមិនទាន់ពេញលេញដែលមានស្រាប់ដើម្បីធ្វើឱ្យដំណើរការកិច្ចសហប្រតិបត្តិការស្រាវជ្រាវរបស់យើងជាទូទៅ និងបង្កើតរចនាសម្ព័ន្ធអតីតនិស្សិតជាពិសេសផងដែរ។ វិស័យមួយផ្សេងទៀតដែលខ្ញុំមើលឃើញថាមានសក្តានុពលខ្លាំងដែរ គឺកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌។ អាល្លឺម៉ង់បានរួមចំណែកយ៉ាងច្រើនក្រោសក្រៃលនិងអស់រយៈពេលជាយូរណាស់

មកហើយដែរចំពោះកិច្ចការអភិរក្សជាលក្ខណៈអន្តរជាតិលើប្រាសាទអង្គរ។ ពិតប្រាកដណាស់ ខ្ញុំមិនមែនជាអ្នកជំនាញអភិរក្សទេ។ ទោះបីជាយ៉ាងណាខ្ញុំគិតថា មានចន្លោះសម្រាប់ការធ្វើឱ្យប្រសើរឡើង តាមពីររបៀបយ៉ាងតិចៈ នៅពេលវិភាគគម្រោងរបស់អាល្លឺម៉ង់នោះ ការប៉ាន់ប្រមាណជាមូលដ្ឋានពាក់ព័ន្ធនឹងគ្រោងពេលវេលាហាក់បីដូចជាធ្វើឱ្យខ្ញុំមានមន្ទិល គឺពួកគេមិនប៉ាន់ប្រមាណគ្រប់គ្រាន់ពីការពិតដែលលក្ខខណ្ឌអាកាសធាតុនិងឥទ្ធិពលពីភ្ញៀវទេសចរជាអចិ ន្ត្រៃយ៍ តម្រូវកិច្ចការអភិរក្សឱ្យមានលក្ខណៈជាអចិន្ត្រៃយ៍ដោយមិនកម្រិតចំពោះតែអន្តរាគមន៍ជាក់លាក់នោះទេ។ ខ្ញុំបានបង្កើតកិច្ចពិភាក្សាបែបវិទ្យាសស្រ្តនិងបែបនយោបាយនៅក្នុងប្រទេសអាល្លឺម៉ង់ក្នុងគោលបំណងស្វែងរកវិធីសាស្រ្តថ្មីមួយដែលមានលក្ខណៈកាន់តែអចិន្ត្រៃយ៍ចំពោះកិច្ចការអភិរក្សរបស់អាល្លឺម៉ង់នៅអង្គរ។ វិធីទីពីរដើម្បីធ្វើឱ្យប្រសើរឡើងនូវទិន្នផលរបស់កិច្ចខំប្រឹងប្រែងអភិរក្ស គឺការបង្កើតអន្តរកម្មកាន់តែខ្លាំងរវាងក្រុមការងារថ្នាក់ជាតិដោយប្រើធនធានរបស់គ្នាទៅវិញទៅមក និងការសហការលើគម្រោងជាក់លាក់ច្រើនជាងការរៀបចំផែនការ និងធ្វើការផ្តាច់មុខក្នុងក្របខណ្ឌជាតិ។

**លោក Hör :** តើឯកឧត្តមមានការចក្ខុវិស័យផ្ទាល់ខ្លួនយ៉ាងណាដែរលើទំនាក់ទំនងទ្វេភាគី?

**ឯ.ឧ. Berger :** ជំងឺកូវីដបានពន្យឺតការអនុវត្តគម្រោងជាច្រើនដែលខ្ញុំបាននិយាយ ប៉ុន្តែជំងឺកូវីដមិនបានធ្វើឱ្យដួលរលំគម្រោងណាមួយទេ។ សម្រាប់ក្របខណ្ឌស្ថាប័ននៅក្នុងវិស័យកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ យើងបានអនុវត្តដោយជោគជ័យនូវកិច្ចពិគ្រោះយោបល់ជាមួយរដ្ឋាភិបាលកាលពីឆ្នាំមុន និងកិច្ចចរចាទ្វេភាគីក្នុងឆ្នាំនេះ ទោះបីជាជំងឺកូវីដបង្កភាពស្មុគស្មាញសម្រាប់ការផ្លាស់ប្តូរនានាពាក់ព័ន្ធនឹងពហុភាពនៃតួអង្គនានាក៏ដោយ។ ចំណែកឯកិច្ចសហប្រតិបត្តិការនយោបាយប្រកបដោយអំណះអំណាងជាក់លាក់ទៅនឹងគោលការណ៍ណែនាំឥណ្ឌូប៉ាស៊ីហ្វិក ខ្ញុំក៏បានផ្តល់យោបល់ទៅដល់ការិយាល័យការបរទេសសហព័ន្ធ ដើម្បីស្នើដល់មិត្តកម្ពុជារបស់យើងនូវក្របខណ្ឌសម្រាប់កិច្ចពិគ្រោះយោបល់ទ្វេភាគីមួយលើបញ្ហាគោលនយោបាយការបរទេស។ ខ្ញុំពិតជាសប្បាយចិត្តក្នុងការបង្ហាញថាការរៀបចំក្របខណ្ឌនេះគួរនឹងបញ្ចប់ឆាប់ៗនេះ ដែលវាជាជំហានដ៏សំខាន់មួយផ្សេងទៀត ក្នុងការពង្រីកនិងធ្វើឱ្យស៊ីជម្រៅទំនាក់ទំនងទ្វេភាគីរបស់យើង។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ឯកឧត្តមដែលយល់ព្រមឆ្លើយសំណួររបស់យើងខ្ញុំ។




ការផ្តោតអារម្មណ៍នៃកិច្ចសហប្រតិបត្តិការរវាងប្រទេសអាល្លឺម៉ង់និងកម្ពុជាក្នុងវិស័យវប្បធម៌ផ្តោតលើការអភិរក្សប្រាសាទនៅអង្គរ។ នៅក្នុងរូបភាព នាយកប្រចាំប្រទេសនៃ GIZ កម្ពុជាលោក Thomas Waldraff បានជួបសវនាការជាមួយអគ្គសវនកររនៃអាជ្ញាធរសវនកម្មជាតិ (NAA) នៃប្រទេសកម្ពុជាដើម្បីប្រគល់ការគ្រប់គ្រងគម្រោងនៃគម្រោង GIZ «គាំទ្រដល់ស្ថាប័នសវនកម្មជាន់ខ្ពស់អាស៊ាន»។

# III. គំនិតសំខាន់

## ជប៉ុន កម្ពុជា និងឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ

**ឯកឧត្តម Mikami Masahiro**
**ឯកអគ្គរាជទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**


© Mr. Mikami Masahiro

ឯកឧត្តម Mikami Masahiro បានបម្រើការងារជាឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជាចាប់តាំងពីឆ្នាំ២០១៩។

ពេលថ្មីៗនេះ ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ (FOIP) កំពុងត្រូវបានពិភាក្សា ជាញឹកញាប់នៅក្នុងបរិបទប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងសហរដ្ឋអាមេរិកនិងចិន។ ជាការណ៍ពិត មនុស្សជាច្រើនហាក់ដូចជាជឿថា ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ គឺជាការបង្កើតឡើងរបស់សហរដ្ឋអាមេរិកនាពេលថ្មីៗក្នុងការទប់ទល់ឥទ្ធិពលកាន់តែខ្លាំងឡើងរបស់ចិននៅក្នុងតំបន់។ ការណ៍ពិតនៃបញ្ហានេះគឺថា តាំងពីដើមខែសីហា ឆ្នាំ២០១៦ នៅពេលដែល នាយករដ្ឋមន្ត្រីជប៉ុន លោក ស៊ីនហ្សូ អាបេ បាននិយាយជាលើកដំបូងពីទស្សនទានឥណ្ឌូប៉ាស៊ី-ហ្វិកសេរីនិងបើកចំហនៅក្នុងសុន្ទរកថាគន្លឹះរបស់គាត់នៅក្នុងសន្និសីទអន្តរជាតិទីក្រុងតូក្យូស្តីពីការអភិវឌ្ឍអាហ្វ្រិកលើកទី៦ ក្នុងទីក្រុងណៃរ៉ូប៊ី ប្រទេសកេនយ៉ា។ លោកនាយករដ្ឋមន្ត្រី អាបេ បានថ្លែងថា «នៅពេលលោកអ្នកឆ្លងកាត់សមុទ្ររបស់អាស៊ីនិងមហាសមុទ្រឥណ្ឌា ហើយមកដល់ទីក្រុងណៃរ៉ូប៊ី នៅពេលនោះលោកអ្នកយល់យ៉ាងច្បាស់ថា អ្វីដែលតភ្ជាប់អាស៊ីនិងអាហ្វ្រិកគឺផ្លូវសមុទ្រ។ អ្វីដែលនឹងផ្តល់ស្ថិរភាពនិងវិបុលភាពទៅកាន់ពិភពលោក គឺគ្មានអ្វីសោះក្រៅពីភាពរស់រវើកដ៏ធំសម្បើមដែលនាំមកដោយការរួបរួមមហាសមុទ្រទាំងពីរនិងទ្វីបទាំងពីរដោយសេរីនិងបើកចំហ។ ជប៉ុនមានទំនួលខុសត្រូវក្នុងការបង្កើតចំណុចប្រសព្វរបស់មហាសមុទ្រប៉ាស៊ីហ្វិកនិងមហាសមុទ្រឥណ្ឌា ហើយទ្វីបអាស៊ីនិងទ្វីបអាហ្វ្រិកទៅជាកន្លែងមួយដែលឱ្យតម្លៃសេរីភាព នីតិរដ្ឋ និងសេដ្ឋកិច្ចទីផ្សារ រួចផុតពីការប្រើកម្លាំងឬការបង្ខិតបង្ខំ និងធ្វើឱ្យមានវិបុលភាព។ ជប៉ុនចង់ធ្វើការរួមគ្នាជាមួយលោកអ្នកក្នុងទ្វីបអាហ្វ្រិក ដើម្បីធ្វើឱ្យសមុទ្រដែលតភ្ជាប់ទ្វីបទាំងពីរទៅជា សមុទ្រប្រកបដោយសន្តិភាពដែលគ្រប់គ្រងដោយនីតិរដ្ឋ។ នោះគឺជាអ្វីដែលយើងប្រាថ្នាធ្វើជា មួយលោកអ្នក»។

## ចំណុចជាក់លាក់នៃ «យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ»

### ១. ការលើកកម្ពស់និងការបង្កើតនីតិរដ្ឋ សេរីភាពនាវាចរណ៍ ពាណិជ្ជកម្មសេរី។ល។

- សហប្រតិបត្តិការក្នុងចំណោមជប៉ុន ឥណ្ឌា អូស្ត្រាលី អាស៊ាន ប្រទេសនានានៅអឺរ៉ុបនិងមជ្ឈិមបូព៌ា។ល។
- ទំនាក់ទំនងជាយុទ្ធសាស្ត្រនៅក្នុងសង្វៀនអន្តរជាតិនិងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ល។

### ២. ការស្វែងរកវិបុលភាពសេដ្ឋកិច្ច

- ការធ្វើឱ្យប្រសើរឡើងនៃ«ការតភ្ជាប់»តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដូចជាកំពង់ផែនិងផ្លូវដែក
  - ការធ្វើឱ្យប្រសើរឡើងនៃ«ការតភ្ជាប់»ក្នុងអាស៊ាន(ច្រករបៀងសេដ្ឋកិច្ចខាងកើត-ខាងលិច ច្រករបៀងសេដ្ឋកិច្ចខាងត្បូង។ល។) នៅក្នុងអាស៊ីនិរតី (គម្រោងធ្វើឱ្យប្រសើរឡើងនៃការតភ្ជាប់ភាគឦសានក្នុងប្រទេសឥណ្ឌានិងតំបន់លូតលាស់ឧស្សាហកម្មឆកបេនហ្គាល់។ល។) និងអាស៊ីអាគ្នេយ៍ទៅកាន់អាហ្វ្រិកអាគ្នេយ៍តាមរយៈអាស៊ីនិរតីនិងមជ្ឈិមបូព៌ា(កំពង់ផែមុំបាសា។ល។)
  - ការពង្រឹងភាពជាដៃគូសេដ្ឋកិច្ច(រួមមានសន្ធិសញ្ញាវិនិយោគ)និងការធ្វើឱ្យប្រសើរឡើងនៃបរិយាកាសធុរកិច្ច។ល។

### ៣. ការប្តេជ្ញាចិត្តដើម្បីសន្តិភាពនិងស្ថិរភាព

- ជំនួយកសាងសមត្ថភាពដល់ប្រទេសតំបន់ឆ្នេររបស់ឥណ្ឌូប៉ាស៊ីហ្វិក (ការពង្រឹងសមត្ថភាពរឹតបន្តឹងច្បាប់សមុទ្រនិងសមត្ថភាពយល់ដឹងដែនសមុទ្រ ការអភិវឌ្ឍធនធានមនុស្ស។ល។)
- កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យជំនួយមនុស្សធម៌និងជំនួយគ្រោះមហន្តរាយ
- កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យប្រឆាំងចោរសមុទ្រ ប្រឆាំងភេរវកម្ម ការមិនរីកសាយភាយអាវុធ។ល។

ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ គឺជាចក្ខុវិស័យមួយដែលស្វែងរកបង្កើត សណ្តាប់ធ្នាប់មួយដែលសេរីនិងបើកចំហដោយផ្អែកលើនីតិរដ្ឋ នៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកដែលមានលក្ខណៈស៊ីជម្រៅ ប្រកបដោយបរិយាបន្ន និងមានតម្លាភាព ដោយភ្ជាប់សារៈសំខាន់ទៅនឹងមជ្ឈភាពនិងឯកភាពរបស់អាស៊ាន។ គោលបំណងរបស់ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ គឺដើម្បីនាំមកនូវស្ថិរភាពនិងវិបុលភាពដល់គ្រប់ប្រទេស ព្រមទាំងធានាសន្តិភាពនិងវិបុលភាពនៅក្នុងតំបន់និងក្រៅតំបន់។ ជប៉ុនបានធ្វើការងារនេះ ហើយក៏នឹងនៅតែបន្តធ្វើការងារនេះជាមួយប្រទេសណាមួយក៏បានដែលចែករំលែកឬគាំទ្រគំនិតនេះ។ ប្រភពដើមរបស់ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ អាចរកឃើញនៅក្នុងរដ្ឋបាលដំបូងរបស់លោកនាយករដ្ឋមន្ត្រី អាបេ។ នៅឆ្នាំ២០១៦ លោកនាយករដ្ឋមន្ត្រីបានឡើងថ្លែងសុន្ទរកថាដែលមានចំណងជើងថា «ចំណុចប្រសព្វនៃសមុទ្រទាំងពីរ» អំឡុងការធ្វើទស្សនកិច្ចជាផ្លូវការទៅកាន់ឥណ្ឌា។ ដូច្នេះ ដរាបណាប្រទេសជប៉ុននៅតែពាក់ព័ន្ធនោះ ទស្សនទានរបស់ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហកំពុងតែអភិវឌ្ឍជាសន្សឹមៗអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដោយឆ្លុះបញ្ចាំងពីសារៈសំខាន់កាន់តែខ្លាំងរបស់ប្រទេសឥណ្ឌានិងទ្វីបអាហ្វ្រិកចំពោះជប៉ុន។


© Port Autonome de Sihanoukville (PAS)

រូបភាពពីលើអាកាសនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ

សម្រាប់ប្រទេសជប៉ុន ចក្ខុវិស័យរបស់ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ មានសសរស្តម្ភចំនួនបី។ សសរស្តម្ភទីមួយក្នុងចំណោមទាំងបីគឺការលើកកម្ពស់គោលការណ៍គ្រឹះនៃសហគមន៍អន្តរជាតិដូចជានីតិរដ្ឋ សេរីភាពនាវាចរណ៍ និងពាណិជ្ជកម្មសេរី។

សសរស្តម្ភទីពីរគឺការស្វែងរកវិបុលភាពសេដ្ឋកិច្ចតាមរយៈការលើកកម្ពស់ការតភ្ជាប់។ ការធ្វើបែបនេះនឹងរាប់បញ្ចូលការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយគុណភាពនិងមានសង្គតិភាពជាមួយស្តង់ដារអន្តរជាតិ។

សសរស្តម្ភទីបីគឺការប្តេជ្ញាចិត្តចំពោះសន្តិភាពនិងស្ថិរភាពដែលនឹងអាចសម្រេចបានតាមរយៈគំនិតផ្តួចផ្តើមនានាដូចជាការកសាងសមត្ថភាពសម្រាប់ការពង្រឹងច្បាប់សមុទ្រ ការកាត់បន្ថយហានិភ័យមហន្តរាយ និងការមិនរីកសាយភាយអាវុធនុយក្លេអ៊ែរ។

ដោយសារទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ គឺជាទស្សនទានទូទៅនិងធំទូលាយមួយ ដោយត្រូវយកមកគិតពិចារណាពីទិដ្ឋភាពជាច្រើននោះ វាក៏មានវិធីជាច្រើនដើម្បីសង្កេតមើលទស្សនទាននេះដែរ។ ត្រង់ចំណុចនេះខ្ញុំចង់បង្ហាញពីចរិកលក្ខណៈជាច្រើនរបស់ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហដែលខ្ញុំគិតថាមានសារៈសំខាន់។

ទីមួយ វាពិតជាសំខាន់ណាស់ដើម្បីកត់សម្គាល់រឿងពីរចំណុចគឺ ទីមួយ ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហប្រមូលផ្តុំគំនិតនិងសកម្មភាពនានា និងទីពីរ សសរស្តម្ភទាំងបីមានជាប់ពាក់ព័ន្ធគ្នានិងពឹងផ្អែកលើគ្នាទាំងអស់។ បើនិយាយឱ្យចំទៅដើម្បីសម្រេចបាននូវឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហនេះ យើងត្រូវការទាំងគោលការណ៍និងសកម្មភាពជាក់ស្តែង។ នោះគឺជាមូលហេតុដែលជប៉ុនផ្សារភ្ជាប់សារៈសំខាន់ទៅនឹងគោលការណ៍មូលដ្ឋានគ្រឹះដូចជានីតិរដ្ឋ ការគោរពសិទ្ធិមនុស្ស និងពាណិជ្ជកម្មសេរី ខណៈពេលជាមួយគ្នានោះបានចូលរួមដោយផ្ទាល់ជាមួយគម្រោងជំនួយអភិវឌ្ឍន៍ផ្លូវការនិងការលើកកម្ពស់ពាណិជ្ជកម្មសេរីនិងការវិនិយោគឯកជននៅក្នុងតំបន់។

នៅក្នុងប្រទេសកម្ពុជា ដោយតែងតែគិតគូរពីមហាតំបន់មេគង្គ យើងកំពុងខិតខំធ្វើការយ៉ាងខ្លាំង ដើម្បីលើកកម្ពស់ការតភ្ជាប់និងកិច្ចសហប្រតិបត្តិការរដ្ឋ-ឯកជន។ ជាឧទាហរណ៍ ជប៉ុនបានសហការជាមួយប្រទេសកម្ពុជាដើម្បីអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងដែលតភ្ជាប់ទីក្រុងហូជីមិញ ភ្នំពេញ បាងកកនិងដាវ៉ៃក្នុងប្រទេសភូមា ហើយយើងក៏កំពុងគាំទ្រការអភិវឌ្ឍកំពង់ផែស្វយ័តទីក្រុងព្រះសីហនុផងដែរ។ ព្រមពេលជាមួយគ្នានេះដែរ កិច្ចប្រជុំវិស័យ រដ្ឋ-ឯកជន ជប៉ុន-កម្ពុជាដែលបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀងវិនិយោគជប៉ុន-កម្ពុជា ត្រូវបានរៀបចំធ្វើឡើងច្រើនជាង២០លើកមកហើយ ដើម្បីធ្វើឱ្យបរិយាកាសធុរកិច្ចប្រសើរឡើងនៅក្នុងប្រទេសកម្ពុជាដោយដោះស្រាយបញ្ហាជាក់លាក់នានាដែលប៉ះពាល់បរិយាកាសធុរកិច្ចនិងការវិនិយោគក្នុងប្រទេសកម្ពុជា។

ដោយស្ថិតក្នុងក្របខណ្ឌដែលខ្ញុំធ្វើជាសហប្រធានជាមួយឯកឧត្តម សុខ ចិន្តាសោភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាគមធុរកិច្ចជប៉ុនប្រចាំកម្ពុជា (JBAC) ស្ថានទូតជប៉ុនអង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានធ្វើការពិភាក្សាជាមួយក្រសួងនានារបស់កម្ពុជាពីបញ្ហាសំខាន់ៗ ដូចជាប្រព័ន្ធពន្ធនិងគយ បញ្ហាប្រាក់សោធននិវត្តន៍ តម្លៃអគ្គិសនី ការដឹកជញ្ជូននិងភស្តុភារ ព្រមទាំងការអភិវឌ្ឍធនធានមនុស្ស។ យើងខ្ញុំជឿជាក់ថា កិច្ចខិតខំប្រឹងប្រែងជាក់ស្តែងដែលបានអនុវត្តក្រោមគំនិតផ្តួចផ្តើមនេះនឹងប្រែក្លាយគំនិតទៅជាលទ្ធផលជាក់ស្តែង នាំមកនូវកម្លាំងរួមដែលនឹងទាក់ទាញការវិនិយោគបរទេសបន្ថែមទៀត និងផ្តល់ជាមូលដ្ឋានសម្រាប់វិបុលភាពនិងស្ថិរភាពសេដ្ឋកិច្ច មិនសម្រាប់តែប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់តំបន់ទាំងមូលផងដែរ។

ដោយជាប្រទេសមួយដែលជាប់ជើងឯកជាយូរមកហើយដោយមានសណ្តាប់ធ្នាប់អន្តរជាតិសេរីនិងបើកចំហនោះ ជប៉ុនតែងតែបានគាំទ្រគំនិតពាណិជ្ជកម្មសេរី។ តាមការណ៍ពិត ការលើកកម្ពស់ពាណិជ្ជកម្មសេរី គឺជាធាតុមួយក្នុងចំណោមធាតុចម្បងនានានៃសសរស្តម្ភទីមួយរបស់ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ។ នៅពេលរដ្ឋបាលសហរដ្ឋអាមេរិកក្រោមលោកប្រធានាធិបតីត្រាំ បានសម្រេចចិត្តដកថយចេញពីកិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) នៅខែមករា ឆ្នាំ២០១៧ ហើយវាជាកិច្ចព្រមព្រៀងមួយដែលជប៉ុនបានធ្វើការជាមួយប្រទេសចូលរួមជាច្រើនផ្សេងទៀតឆ្ពោះទៅរកការអនុម័តកិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិកលើកទី១១។ លើសពីនេះទៀត ជប៉ុនក៏បានខិតខំប្រឹងប្រែងជាមួយប្រទេសចូលរួមជាច្រើនផ្សេងទៀតដើម្បីសម្រេចបានកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) ដែលបានចុះហត្ថលេខាកាលពីខែវិច្ឆិកា ឆ្នាំ២០២០។ យើងសង្ឃឹមថាកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់នឹងរួមចំណែកក្នុងការលើកកម្ពស់ពាណិជ្ជកម្មសេរីនិងយុត្តិធម៌ និងបរិយាកាសវិនិយោគល្អប្រសើរមួយនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ ជាងនេះទៅទៀតវាជារឿងជាក់ស្តែងណាស់ដែលសណ្តាប់ធ្នាប់ដែនសមុទ្រសេរីនិងបើកចំហក៏មានសារៈសំខាន់ខ្លាំងផងដែរក្នុងការលើកកម្ពស់ពាណិជ្ជកម្មសេរី។

ទីពីរ ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហគឺជាទស្សនទានប្រកបដោយបរិយាបន្ន និងមានតម្លាភាព និងមិនមែនជាគោលនយោបាយទប់ទល់តម្រង់ទៅរកប្រទេសណាមួយជាក់លាក់នោះទេ រួមទាំងចិនផង។ ដរាបណាយើងមានវឌ្ឍនភាពល្អឆ្ពោះទៅរកគោលដៅរបស់ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ ប្រទេសណាមួយក៏ដោយក៏សមទទួលស្វាគមន៍បំផុតដើម្បីចូលរួមក្នុងកិច្ចខំប្រឹងប្រែងរួមរបស់យើង។ ដូច្នេះ ពាក់ព័ន្ធនឹងបញ្ហានេះប្រសិនគម្រោងនានាស្ថិតនៅក្រោមគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ (BRI) ដែលចូលរួមចំណែកទៅនឹងការសម្រេចបានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហដោយការលើកកម្ពស់ការតភ្ជាប់នៅក្នុងតំបន់ខណៈផ្តោតការយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះស្តង់ដារអន្តរជាតិដូចជាការបើកចំហ តម្លាភាព ប្រសិទ្ធភាពសេដ្ឋកិច្ច និងចីរភាពបំណុល គម្រោងទាំងនោះនឹងទទួលការស្វាគមន៍ផងដែរ។




© REUTERS/Eugene Hoshiko

លោក ស៊ីនហ្សូ អាបេ ដែលជានាយករដ្ឋមន្ត្រីជប៉ុននាពេលនោះ និងសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានចាប់ដៃគ្នាអំឡុងកិច្ចប្រជុំរបស់លោកទាំងពីរនៅការិយាល័យរបស់លោកអាបេ ក្នុងទីក្រុងតូក្យូ ប្រទេសជប៉ុន កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៨។

ទីបី ខ្ញុំចង់គូសបញ្ជាក់ពីសារៈសំខាន់របស់ច្បាប់អន្តរជាតិ ជាពិសេសច្បាប់សមុទ្រចំពោះការសម្រេចបាននូវឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ។ សន្និបាតអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រដែលទទួលការអនុម័តកាលពីឆ្នាំ១៩៨២ និងបានចូលជាធរមានក្នុងឆ្នាំ១៩៩៤ គឺជាគំរូច្បាប់ស៊ីជម្រៅមួយពាក់ព័ន្ធនឹងសមុទ្រ និងដែលជារឿយៗសំដៅថា ជា «រដ្ឋធម្មនុញ្ញមហាសមុទ្រ» ។ ច្បាប់នេះទទួលបានការធ្វើសច្ចាប័នដោយភាគីចំនួន១៦៨ បើទោះបីជាមានរដ្ឋមួយចំនួនដូចជាប្រទេសកម្ពុជាមិនទាន់បានផ្តល់សច្ចាប័ននៅឡើយផ្នែកសំខាន់ជាច្រើនរបស់ច្បាប់ ជាពិសេសពាក់ព័ន្ធនឹងប្រទេសដែលជាប់ពាក់ព័ន្ធនឹងសិទ្ធិទទួលបានដែនសមុទ្រដូចជាអធិបតេយ្យភាពសមុទ្រ តំបន់ជាប់គ្នា តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងខ្ពង់រាបបាតសមុទ្រ បានឆ្លុះបញ្ចាំងពីច្បាប់អន្តរជាតិតាមប្រពៃណី ដែលបានចងក្រងតាមផ្លូវច្បាប់សូម្បីតែមិនមែនជាភាគីរបស់សន្និបាត។ ជាការណ៍ពិតពីសម័យកាលមួយទៅសម័យកាលមួយ ការបកស្រាយច្បាប់បានបង្កវិវាទយ៉ាងក្តៅគគុកដោយរដ្ឋនានា។ ទោះបីយ៉ាងណានេះ មិនមែនមានន័យថា រដ្ឋនានាមានសេរីភាពក្នុងការបកស្រាយច្បាប់ដូចពួកគេចង់នោះទេ ដោយសារពួកគេត្រូវពន្យល់ពីការបកស្រាយរបស់ពួកគេឱ្យបានសមស្របនិងគោរពដំណើរការការទូត និងច្បាប់។ ការព្យាយាមផ្លាស់ប្តូរស្ថានភាពពីមុនជាឯកតោភាគីដោយការប្រើប្រាស់កម្លាំងនិងដោយមិនគោរពគំនិតអ្នកផ្សេងទៀត គួរត្រូវជំទាស់ដាច់ខាត។

ប្រទេសកម្ពុជាបានបង្ហាញការគាំទ្ររបស់ខ្លួនចំពោះទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ មុនប្រទេសផ្សេងទៀតជាច្រើន នៅពេលនាយករដ្ឋមន្ត្រី អាបេ បានលើកគំនិតផ្តួចផ្តើមនេះឡើងដល់នាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីខែសីហា ឆ្នាំ២០១៧។ មួយរយៈពេលខ្លីក្រោយមកទៀត សហរដ្ឋអាម៉េរិកបានអភិវឌ្ឍយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហរបស់ខ្លួនផ្ទាល់។ នៅខែវិច្ឆិកា ឆ្នាំ២០១៧ ក្នុងឱកាសកិច្ចប្រជុំមេដឹកនាំអេប៉ិចនៅក្នុងប្រទេសវៀតណាម លោក ដូណាល់ ត្រាំ ដែលជាប្រធានាធិបតីសហរដ្ឋអាម៉េរិកនាពេលនោះ បានមានប្រសាសន៍ពីយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ និងសារៈសំខាន់នៃយុទ្ធសាស្ត្រនេះ ដែលត្រូវបានឆ្លុះបញ្ចាំងបន្ថែមនៅក្នុងយុទ្ធសាស្ត្រសន្តិសុខជាតិសហរដ្ឋអាម៉េរិកនៅចុងឆ្នាំនោះ។

គោលនយោបាយសហរដ្ឋអាម៉េរិកនេះប្រហែលបានលើកឡើងពីការប្រុងប្រយ័ត្នលើផ្នែកនៃការរះឡើងរបស់អាស៊ាន ដូចដែលអាស៊ានបានធ្វើ ស្ថិតក្នុងពេលប្រកួតប្រជែងកាន់តែខ្លាំងរវាងសហរដ្ឋអាម៉េរិកនិងចិន និងបន្ទាប់ពីកម្ពុជាបានបង្ហាញការគាំទ្ររបស់ខ្លួនសម្រាប់ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហរបស់ជប៉ុននៅពាក់កណ្តាលឆ្នាំ២០១៧ និងមានការពិភាក្សាមួយចំនួនអំពីទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហបានកើតឡើងតាមក្រោយក្នុងចំណោមសមាជិកអាស៊ាន។ ទីបញ្ចប់នៅខែមិថុនា ឆ្នាំ២០១៩ អាស៊ានបានប្រកាសពីចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក (AOIP) ដែលបានចែករំលែកភាពរួមគ្នាជាច្រើនជាមួយនឹងទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ។ សមាជិកអាស៊ាននិងជប៉ុនបានអះអាងនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុនក្នុងខែវិច្ឆិកា ឆ្នាំ២០២០ ថា ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក និងទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហចែករំលែកគោលការណ៍មូលដ្ឋានគ្រឹះនិងពាក់ព័ន្ធគ្នាចំពោះការលើកកម្ពស់សន្តិភាពនិងសហប្រតិបត្តិការ។ នៅក្នុងកិច្ចប្រជុំកំពូលនោះដែរ សេចក្តីថ្លែងការណ៍រួមគ្នាលើកិច្ចសហប្រតិបត្តិការនៃចក្ខុវិស័យរបស់អាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកទទួលបានការអនុម័ត ហើយនេះគឺជាឯកសារដំបូងបំផុតដែលបានដោះដូរគ្នារវាងអាស៊ាន និងដៃគូខាងក្រៅលើគំនិតផ្តួចផ្តើមតម្រង់ឆ្ពោះឥណ្ឌូប៉ាស៊ីហ្វិក។ ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកបានដាក់ចេញនីតិរដ្ឋ ការបើកចំហ សេរីភាព តម្លាភាព និងបរិយាបន្នជាគោលការណ៍សកម្មភាពរបស់អាស៊ាន ហើយការចែករម្លែកគោលការណ៍មូលដ្ឋានគ្រឹះទាំងនេះគឺជាមូលដ្ឋាននៃកិច្ចសហប្រតិបត្តិការរវាងអាស៊ាន និងជប៉ុន។ សេចក្តីថ្លែងការណ៍រួមគ្នានេះបានផ្តោតសារៈ-សំខាន់លើតំបន់ឥណ្ឌូប៉ាស៊ីហ្វិកផ្អែកលើច្បាប់ ដែលសេរីនិងបើកចំហ និងក្តោបនូវគោលការណ៍ចម្បងៗនានា រួមមាន ឯកភាពនិងមជ្ឈភាពអាស៊ាន។ ជប៉ុននឹងបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការដ៏រឹងមាំលើបញ្ហាជាច្រើនដើម្បីសម្រេចបានគោលបំណងរួមរបស់ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហនិងចក្ខុវិស័យរបស់អាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក។

តាមពិតគឺមានមូលដ្ឋានជាក់ស្តែងរួចទៅហើយលើរឿងដែលត្រូវបន្តឈានទៅមុខនៃទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ និងចក្ខុវិស័យរបស់អាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក រវាងកម្ពុជានិងជប៉ុន និងរវាងជប៉ុនជាមួយសមាជិកអាស៊ានផ្សេងៗទៀត។ នៅឆ្នាំ២០២២ កម្ពុជានឹងធ្វើជាប្រធានប្រជុំអាស៊ាន។ មានស្ថានភាពប្រឈមមួយចំនួន ដូចជា វិបត្តិនៅភូមា ដែលនឹងបង្ហាញថា វាមិនមែនជាភារកិច្ចងាយស្រួលសម្រាប់ប្រទេសណាមួយទេ។ ថ្វីបើមានបញ្ហាបែបនេះក៏ដោយ ក៏ខ្ញុំសង្ឃឹមថា កម្ពុជានឹងប្រើបទពិសោធន៍ពីអតីតកាលរបស់ខ្លួន ដើម្បីចាត់ចែងស្ថានភាពលំបាកទាំងនេះនិងរក្សាឯកភាពនិងមជ្ឈភាពរបស់អាស៊ាន។ ជប៉ុនប្រាថ្នាធ្វើការជិតស្និទ្ធជាមួយកម្ពុជាដើម្បីសម្រេចបាននូវស្ថានភាពដែលល្អបំផុតសម្រាប់គ្រប់ៗគ្នា។

ឆ្នាំនេះ គឺជាខួបទី៣០នៃកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសរបស់ប្រទេសកម្ពុជា។ ជប៉ុនបានដើរតួនាទីដ៏សំខាន់និងសកម្មនៅក្នុងការសម្រេចបាននូវកិច្ចព្រមព្រៀងនេះ ព្រមទាំងនៅក្នុងការកសាងប្រទេសកម្ពុជាឡើងវិញបន្ទាប់ពីពេលនោះ។ លើសពីនេះទៀត នៅឆ្នាំ២០២៣ កម្ពុជានិងជប៉ុននឹងធ្វើការរំឭកខួបទី៧០ឆ្នាំនៃការបង្កើតទំនាក់ទំនងការទូតនិងអាស៊ាន ហើយជប៉ុនក៏នឹងប្រារព្វខួបទី៥០ឆ្នាំនៃមិត្តភាពនិងសហប្រតិបត្តិការអាស៊ាន-ជប៉ុនផងដែរ។ ដោយសារយើងត្រួសត្រាយផ្លូវសម្រាប់ការអភិវឌ្ឍបន្ថែមទៀត យើងចង់បន្តដើរទន្ទឹមគ្នាជាមួយកម្ពុជាក្នុងនាមជាមិត្តចាស់ដ៏មានតម្លៃម្នាក់។

*អត្ថបទនេះបង្ហាញនូវទស្សនៈផ្ទាល់ខ្លួនរបស់អ្នកនិពន្ធ និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់រដ្ឋាភិបាលជប៉ុន ឬក្រសួងការបរទេសជប៉ុនឡើយ។





© REUTERS/Athit Perawongmetha

អាស៊ីអាគ្នេយ៍និងអាស៊ានប្រកាន់ជំហរទទួលផលប្រយោជន៍ពីឥណ្ឌូប៉ាស៊ីហ្វិក ប៉ុន្តែសមាជិកមួយចំនួនមានការព្រួយបារម្ភថា មជ្ឈភាពនិងអព្យាក្រឹតភាពអាស៊ានអាចនឹងត្រូវសម្របសម្រួលនៅក្នុងដំណើរការនេះ។ នៅក្នុងរូបភាព នាយករដ្ឋមន្ត្រីកម្ពុជា សម្តេច ហ៊ុន សែន និងប្រមុខរដ្ឋនិងប្រមុខរដ្ឋាភិបាលផ្សេងៗទៀតនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៥ នៅទីក្រុងបាងកក កាលពីខែវិច្ឆិកា ឆ្នាំ២០១៩។

# IV. ទស្សនវិស័យ

## ១. ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ៖ ទស្សនវិស័យកម្ពុជា




### បណ្ឌិត ជីនបូរាណ ច័ន្ទបូរី[1]

បណ្ឌិត ជីនបូរាណ ច័ន្ទបូរី អគ្គនាយកក្រុមវិភាគ ស្រាវជ្រាវ និងព្យាករណ៍ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងជាទីប្រឹក្សាយុទ្ធសាស្ត្រនិងជាសមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានចក្ខុវិស័យអាស៊ី។ ទស្សនៈនៅក្នុងអត្ថបទនេះ ជាទស្សនៈផ្ទាល់ខ្លួនរបស់និពន្ធ មិនឆ្លុះបញ្ចាំងទស្សនៈនៃស្ថាប័នរបស់អ្នកនិពន្ធនោះទេ។


1. អត្ថបទនេះកែសម្រួលចេញពីបទបង្ហាញនៅក្នុងសិក្ខាសាលាអនឡាញស្តីពី «ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហនិងកិច្ចសហប្រតិបត្តិការពេលអនាគត» ដែលបានរៀបចំរួមគ្នាដោយវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា នៃរាជបណ្ឌិត្យសភាកម្ពុជា និងស្ថានទូតជប៉ុន នៅទីក្រុងភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១។

ពាក្យ «ឥណ្ឌូប៉ាស៊ីហ្វិក» បានកាន់តែលេចធ្លោរឡើងនៅក្នុងសទ្ធានុក្រមសន្តិសុខតំបន់និងសកលលោក។ វាជារឿងមិនអាចប្រកែកបាន ដែលថាបញ្ញត្តិនេះត្រូវបានទាញចេញជាដំបូងដោយការផ្លាស់ប្តូរអំណាចសកលលោកដែលជាលទ្ធផលមកពីការរះឡើងរបស់ចិននិងឥណ្ឌា ព្រមទាំងការសម្របសម្រួលយុទ្ធសាស្ត្ររបស់រដ្ឋផ្សេងៗទៀតចំពោះការផ្លាស់ប្តូរដ៏សំខាន់នេះ។ ការស្ថាបនាសង្គមនៃតំបន់បែបនេះមិនមែនជារឿងថ្មីទេ។ តំបន់ឆ្នេរសមុទ្រព័ទ្ធជុំវិញមហាសមុទ្រប៉ាស៊ីហ្វិកនិងតំបន់អាស៊ីប៉ាស៊ីហ្វិកក៏បានបង្កើតឡើងផងដែរ ដើម្បីធានាការត្រួតត្រារបស់សហរដ្ឋអាមេរិកអំឡុងសង្គ្រាមត្រជាក់ និងដើម្បីធានាការប្តេជ្ញាចិត្តជាបន្តរបស់ខ្លួនចំពោះអាស៊ីបន្ទាប់ពីសង្គ្រាម។

ប៉ុន្តែវាលំបាកក្នុងការកំណត់និយមន័យឱ្យច្បាស់លាស់ទៅលើបញ្ញត្តិនេះ ហើយវានៅតែជាចំណោទបញ្ហាថា តើតំបន់ «ឥណ្ឌូប៉ាស៊ីហ្វិក» ប្រកបដោយអត្ថន័យនោះពិតជាកើតមានឬអត់។ តាមពិតទៅ មានទស្សនទានខុសៗគ្នាជាច្រើនស្តីពីតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។

## អប្បបរមាភាគនៃវិសាលភាពខាងនិយាមនិងមុខងារ

តាមលក្ខណៈភូមិសាស្ត្រ មិនមានការមូលមតិគ្នាជាឯកច្ឆន្ទក្នុងចំណោមបញ្ញវន្តនានាទៅលើថាតើរដ្ឋណាខ្លះពិតជាផ្នែកជាក់លាក់របស់តំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ ដូច្នេះ សមាជិកភាពនិងព្រំដែនរបស់តំបន់នេះ ធ្វើឱ្យមានការជជែកតវ៉ាយ៉ាងខ្លាំងនិងជាប្រធានបទមួយដែលអាចបកស្រាយបានច្រើនយ៉ាង។ ដូច្នេះបើតាមទស្សនវិស័យខាងនិយាម អត្ថន័យនៃតំបន់និយមដើម្បីគាំទ្រតំបន់ឥណ្ឌូប៉ាស៊ីហ្វិកថ្មី គឺមិនមានទេ។ លើសពីនេះទៀត វាក៏គ្មានអត្ថន័យនៃមនសិការតំបន់ដែលមានអត្ថិភាពជាលក្ខណៈធម្មជាតិ ដែលនាំឱ្យមានអព្ភន្តរញ្ញាណនិយមនៃតំបន់ឥណ្ឌូប៉ាស៊ីហ្វិកឬក៏ទម្រង់ណាមួយនៃ «អារម្មណ៍ថាជារបស់យើង» (we-feeling) នោះទេ។[1]

ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការតាមមុខងារ ចំណងទាក់ទងខាងសេដ្ឋកិច្ចជាក់ស្តែងរវាងរដ្ឋនានានៅក្នុងមហាសមុទ្រឥណ្ឌានិងមហាសមុទ្រប៉ាស៊ីហ្វិក នៅមានភាពទន់ខ្សោយនៅឡើយ។ រដ្ឋជាប់ឆ្នេរមហាសមុទ្រឥណ្ឌា ភាគច្រើនមិនបានចូលរួមយ៉ាងសកម្មទេក្នុងសមាហរណកម្មសេដ្ឋកិច្ចដែលមានភាពល្អប្រសើរឡើងនៃតំបន់អាស៊ីប៉ាស៊ីហ្វិក។ បច្ចុប្បន្ននេះ នៅផ្នែកតំបន់មហាសមុទ្រឥណ្ឌានៃតំបន់ឥណ្ឌូប៉ាស៊ីហ្វិកគឺមានតែប្រទេសឥណ្ឌាមួយគត់។ បើនិយាយមួយបែបទៀត វាគឺជាការនាំឥណ្ឌាចូលទៅកាន់តំបន់ប៉ាស៊ីហ្វិក។ ប្រការនេះនាំឱ្យមានសំណួរគួរឱ្យចាប់អារម្មណ៍ជាច្រើន : ហេតុអ្វីបានយើងត្រូវការបង្កើតតំបន់ថ្មីមួយទាំងស្រុងនោះ ? ហេតុអ្វីយើងមិនគ្រាន់តែនាំឥណ្ឌាចូលក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ? លើសពីនេះទៀត ការសម្រេចចិត្តរបស់ឥណ្ឌាដកខ្លួនចេញពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) បានជំរុញឱ្យមានការចោទប្រកាន់ថាបញ្ញត្តិស្តីអំពីឥណ្ឌូប៉ាស៊ីហ្វិក ខ្វះខាតមូលដ្ឋានមុខងារច្បាស់លាស់មួយ។

## អតិបរិមាភាគលើការប្រកួតប្រជែងខាងរចនាសម្ព័ន្ធ

ការត្រឡប់មកវិញនៃបញ្ញត្តិឥណ្ឌូប៉ាស៊ីហ្វិក បានកើតឡើងនៅក្នុងបរិបទនៃការប្រកួតប្រជែងដែលកាន់តែស្រួចស្រាល់រវាងសហរដ្ឋ-អាមេរិក-ចិន បន្ទាប់ពីការព្យាយាមលើកទីមួយរបស់អតីតនាយក-រដ្ឋមន្ត្រីជប៉ុន លោក ស៊ីនហ្សូ អាបេ បានបរាជ័យនោះ។ ក្នុងពេញមួយអាណត្តិនៃប្រធានាធិបតីត្រាំ គេកត់សម្គាល់ឃើញថា សហ-រដ្ឋអាមេរិកមានអរិភាពខ្លាំងចំពោះចិន។ មហាអំណាចទាំងពីរត្រូវបានធ្វើឱ្យច្របូកច្របល់នៅក្នុងជម្លោះនិងការប្រឈមមុខដាក់គ្នាជាច្រើន ដោយចាប់ផ្តើមចេញពីសង្គ្រាមពាណិជ្ជកម្មនិងបច្ចេកវិទ្យារហូតដល់បញ្ហានានាពាក់ព័ន្ធនឹងទីក្រុងហុងកុងនិងស៊ីនជាំង ព្រមទាំងទម្រង់ស្តីអំពីការប្រយុទ្ធគ្នានៅក្នុងតំបន់ក្តៅមួយចំនួន រួមមានសមុទ្រចិនខាងត្បូងនិងច្រកសមុទ្រតៃវ៉ាន់។ សូម្បីតែការផ្ទុះរោគរាតត្បាតកូវីដ-១៩ ក៏ត្រូវបានគេធ្វើនយោបាយនីយកម្មសម្រាប់ហេតុផលខាងភូមិសាស្ត្រនយោបាយដែរ។ ហេតុដូចនេះហើយ ការចាប់ផ្តើមរបស់រដ្ឋបាលលោក ត្រាំ នូវគោលនយោបាយឥណ្ឌូ-ប៉ាស៊ីហ្វិកសេរីនិងបើកចំហ (FOIP) ក្នុងឆ្នាំ២០១៧ ក៏ត្រូវបានគេយល់ថា ជាការវាយលុកជាយុទ្ធសាស្ត្រប្រឆាំងចិន ក៏ដូចជាកិច្ចខំប្រឹងប្រែងមួយ ដើម្បីបង្កើតឱ្យមានកិច្ចសន្ទនាសន្តិសុខចតុភាគី (Quad)។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ អ្នករៀបចំគោលនយោបាយនិងប្រព័ន្ធផ្សព្វផ្សាយចិនបានព្រមានចំពោះការប៉ុនប៉ងដោយកិច្ចសន្ទនាសន្តិសុខចតុភាគី គឺដើម្បីឡោមព័ទ្ធចិន។ ដូច្នេះ ការទប់ទល់នេះបានក្លាយជាពាក្យនិយាយច្រំដែលមួយ ចំពោះការយល់ដឹងពីគោល-នយោបាយឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហរបស់រដ្ឋាភិបាលទីក្រុងប៉េកាំង។ រដ្ឋាភិបាលទីក្រុងម៉ូស្គូ បានចែករំលែកការយល់ដឹងស្រដៀងគ្នាមួយដែរ។ ដោយបានថ្លែងនៅក្នុងកិច្ចសន្ទនា Raisina នៅក្នុងទីក្រុងញូវដេលីកាលពីដើមឆ្នាំ២០២០ ដោយរដ្ឋមន្ត្រីការបរទេស Sergei Lavrov បាននិយាយយ៉ាងច្បាស់ថា ឥណ្ឌូប៉ាស៊ីហ្វិក មិនមានអ្វីសោះក្រៅពីជាការបង្កើតឡើងដើម្បីទប់ទល់ចិនតែប៉ុណ្ណោះ។[2]

ក្តីបារម្ភដែលថាគោលនយោបាយឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហអាចជាឧបករណ៍ភូមិសាស្ត្រនយោបាយថ្មីមួយដើម្បីទប់ទល់ចិននោះ បានទទួលការពង្រឹងបន្ថែមទៀតដោយវិធីសាស្ត្រគោល-នយោបាយការបរទេសថ្មីរបស់រដ្ឋបាលលោក បៃដិន ឆ្ពោះទៅរកតំបន់ ដោយមានការកោះប្រជុំថ្មីៗនេះនៃកិច្ចប្រជុំកំពូលក្រុមចតុភាគី (Quad) ជាលើកដំបូង ដែលជាកិច្ចសន្ទនាយុទ្ធសាស្ត្រជាមួយជប៉ុននិងកូរ៉េខាងត្បូង និងការធ្វើទស្សនកិច្ចរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិសហរដ្ឋអាមេរិក លោក Lloyd ទៅកាន់ឥណ្ឌា។ មហាអំណាចខាងក្រៅតំបន់ផ្សេងៗទៀត ដែលជាសម្ព័ន្ធមិត្តរបស់សហរដ្ឋអាមេរិករួមមាន ចក្រភពអង់គ្លេស អាល្លឺម៉ង់ បារាំង និងកាណាដា ក៏បានបង្កើនវត្តមានយោធានិងការទូតរបស់ពួកគេគួរឱ្យកត់សម្គាល់ផងដែរនៅក្នុងតំបន់នោះ។

1. Thomas S. Wilkins, "Australia and the Indo-Pacific Concept – Disambiguating the idea and the region form quadrilateral strategy," The Japan Institute of International Affairs, Policy Brief (19 July 2018).

2. The Ministry of Foreign Affairs of the Russian Federation, "Foreign Minister Sergey Lavrov's remarks and answers to questions at a plenary session of the Raisina Dialogue international conference, New Delhi, January 15, 2020", Sergey Lavrov, January 15 2020, https://www.mid.ru/en/foreign_policy/news/-/asset_publisher/cKNonkJE02Bw/content/id/3994885




ប្រធានាធិបតីសហរដ្ឋអាម៉េរិក ដូណាល់ ត្រាំ ជួបជាមួយប្រធានាធិបតីចិន ស៊ី ជិនពីង នៅពេលចាប់ផ្តើមកិច្ចប្រជុំទ្វេភាគីនៅកិច្ចប្រជុំកំពូលមេដឹកនាំ G២០ ក្នុងប្រទេសជប៉ុន កាលពីខែមិថុនា ឆ្នាំ២០១៩។

## អាស៊ាន និងកម្ពុជានៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកៈ មជ្ឈិមបដិបទា

ការអភិវឌ្ឍខាងលេ បានបង្កឱ្យអាស៊ានមានទ្វេគ្រោះខាងយុទ្ធសាស្ត្រ។ ជាក់ស្តែង តំបន់អាស៊ីអាគ្នេយ៍ គឺជាច្រកទ្វារដ៏សំខាន់មួយរវាងអាស៊ីប៉ាស៊ីហ្វិកនិងមហាសមុទ្រឥណ្ឌា ដូច្នេះ អាស៊ានទទួលផលប្រយោជន៍ពីឥណ្ឌូប៉ាស៊ីហ្វិក។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ពីដំបូង អាស៊ានមានក្តីបារម្ភថាគំនិតផ្តួចផ្តើមថ្មីនេះ អាចធ្វើឱ្យបាត់បង់តម្លៃក្នុងការរៀបចំក្រុមក្នុងតំបន់នឹងធ្វើឱ្យខូចមជ្ឈភាពរបស់ខ្លួន។ អ្វីដែលសំខាន់ជាងនេះទៀត សមាជិកអាស៊ានភាគច្រើនមិនចង់ប្រកាន់យកភាគីខាងណាទេចំពោះការបំបែកជាពីរនៃសណ្តាប់ធ្នាប់តំបន់ដែលកំពុងតែលេចឡើងរវាងសហរដ្ឋអាម៉េរិកនៅម្ខាងនិងចិននៅម្ខាងទៀត។

នៅក្នុងបរិបទនេះ អាស៊ានបានជ្រើសយកវិធីសាស្ត្របុរេសកម្មមួយដោយការអនុម័តចក្ខុវិស័យរបស់អាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក (AOIP) កាលពីខែមិថុនា ឆ្នាំ២០១៩។ អាស៊ានក៏បានធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូសន្ទនារបស់ខ្លួនដើម្បីលើកកម្ពស់ចក្ខុវិស័យរបស់ខ្លួនស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ជាពិសេស តាមរយៈសេចក្តីថ្លែងការណ៍រួមគ្នាមួយនៃកិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុនលើកទី២៣ស្តីពីកិច្ចសហប្រតិបត្តិការលើចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក កាលពីខែវិច្ឆិកា ឆ្នាំ២០២០។

ប្រទេសកម្ពុជាបានភ្ជាប់ខ្លួនជាមួយឥណ្ឌូប៉ាស៊ីហ្វិកក្រោមកាលៈទេសៈតែពីរគឺ ទីមួយ នាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាមេដឹកនាំអាស៊ានដំបូងគេដែលប្រកាសការគាំទ្រពេញទំហឹងចំពោះគោលនយោបាយឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហរបស់ប្រទេសជប៉ុន អំឡុងទស្សនកិច្ចផ្លូវការរបស់សម្តេចទៅកាន់ទីក្រុងតូក្យូ ក្នុងឆ្នាំ២០១៧, ទីពីរ ប្រទេសកម្ពុជាបានផ្តល់ការគាំទ្រចំពោះចក្ខុវិស័យរបស់អាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ជាពិសេស គោលការណ៍នានាទាក់ទិននឹងមជ្ឈភាព ភាពបើកចំហ បរិយាបន្នភាព និងការគោរពអធិបតេយ្យភាព។ ប្រការនេះពន្យល់យ៉ាងច្បាស់ពីឥរិយាបថប្រកបដោយការប្រុងប្រយ័ត្នរបស់ព្រះរាជាណាចក្រកម្ពុជាចំពោះទស្សនទាននិងសារៈសំខាន់ដែលកម្ពុជាមានចំពោះជប៉ុន និងអាស៊ាន។

## វិថីឆ្ពោះទៅមុខ

ជាមួយនឹងភាពមិនប្រាកដប្រជា ការព្រួយបារម្ភ និងការមិនទុកចិត្តលើឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ ប្រការចាំបាច់ជាបឋម ត្រូវធ្វើឱ្យប្រាកដថា គំនិតផ្តួចផ្តើមនេះពិតជាបើកចំហ មានបរិយាបន្ន និងការបំពេញបន្ថែមគ្នាទៅវិញទៅមក។ ជាក់ស្តែង គំនិតផ្តួចផ្តើមក្នុងតំបន់ណាមួយក៏ដោយមិនគួរមានបំណងពន្យុះឱ្យមានការប្រកួតប្រជែង ប៉ុន្តែត្រូវបំពេញបន្ថែមយន្តការដែលមានស្រាប់ដើម្បីនាំមកនូវស្ថិរភាព សន្តិសុខ សន្តិភាព និងវិបុលភាព។ ផ្ទុយទៅវិញ ការប៉ុនប៉ងណាមួយដើម្បីរក្សាវិធីសាស្ត្រជាឯកតោភាគីចំពោះសន្តិសុខតំបន់

នឹងធ្វើឱ្យមានអស្ថិរភាព ហើយវាក៏នឹងបង្កឱ្យមានអស្ថិរភាពផងដែរ បើមានការប៉ុនប៉ងទប់ ទល់ប្រទេសផ្សេងទៀតនៅក្នុងតំបន់។

ទីពីរ សហវិជ្ជមាននៃមហាអំណាច ជាពិសេស ចិន ឥណ្ឌា ជប៉ុន និងសហរដ្ឋអាមេរិក ប្រាកដជានឹងចូលរួមចំណែកដល់ការលើកកម្ពស់ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិក ព្រមទាំងសន្តិភាពនិងវិបុលភាពក្នុងតំបន់។ ប៉ុន្តែ រដ្ឋផ្សេងៗទៀតនិងស្ថាប័ននានាក្នុងតំបន់ត្រូវតែមានសិទ្ធិបញ្ចេញមតិដែរ។

ជាជាងការប្រកាន់យកភាគីណាមួយរវាងសហរដ្ឋអាមេរិក-ចិនដែលកំពុងប្រកួតប្រជែងគ្នា និងការបំបែកជាពីរនៃសណ្តាប់ធ្នាប់តំបន់ដែលកំពុងតែលេចឡើង មហាអំណាចផ្សេងទៀត រួមមានសហភាពអឺរ៉ុប និងមហាអំណាចអឺរ៉ុបនានាចាំបាច់ត្រូវធ្វើការជាមួយអាស៊ាន ដើម្បីលើកកម្ពស់សណ្តាប់ធ្នាប់តំបន់ឥណ្ឌូប៉ាស៊ីហ្វិកពហុប៉ូលនិងពហុទម្រង់។

និយាយម្យ៉ាងទៀត ការចូលរួមរបស់ពួកគេនៅក្នុងឥណ្ឌូប៉ាស៊ីហ្វិកមិនគួរបង្ខំឱ្យមានជម្រើសតែពីរសម្រាប់អាស៊ាននៅក្នុងការប្រកួតប្រជែងជាយុទ្ធសាស្ត្ររវាងសហរដ្ឋអាមេរិក-ចិនដែលមានលក្ខណៈកាន់ តែខ្លាំងនោះទេ។ វាក៏ជារឿងមានប្រយោជន៍សម្រាប់ពួកគេផងដែរ ដើម្បីចូលរួមជាមួយអាស៊ានជំរុញឱ្យប្រសើរឡើងនូវបរិយាបន្នភាព ការបំពេញបន្ថែមគ្នាទៅវិញទៅមក និងពហុភាគីនិយម ដើម្បីធានានូវសន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់។ នៅក្នុងការតភ្ជាប់នេះ ប្រសិនមិនមានវត្តមានស្ថាប័នឥណ្ឌូប៉ាស៊ីហ្វិកទេ អាស៊ានអាចផ្តល់វេទិកាដែលមានស្រាប់ រួមមាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា វេទិកាតំបន់អាស៊ាន និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក។

ជាចុងក្រោយ អន្តរទំនាក់ទំនងជាយុទ្ធសាស្ត្រនិងសេដ្ឋកិច្ចនៃតំបន់មហាសមុទ្រទាំងពីរ ត្រូវផ្លាស់ប្តូរជាផលប្រយោជន៍ទៅវិញទៅមក និងការលើកកម្ពស់ធនធានរួមគ្នាក្នុងតំបន់ ដែលរួមមាន៖ (ក)ការលើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចនិងការតភ្ជាប់ដោយការស្វែងរកនូវកម្លាំងរួម ប្រកបដោយសក្តានុពលជា មួយគម្រោងតភ្ជាប់ដែលមានស្រាប់ រួមមាន ផែនការមេនៃការតភ្ជាប់អាស៊ាន (MPAC) ឆ្នាំ២០២៥ (ខ)ការសម្របសម្រួលនៃការចែករំលែកបទពិសោធន៍ជំនាញការ និងនវានុវត្តន៍ដើម្បីឱ្យប្រទេសនានាក្នុងតំបន់ត្រៀមខ្លួនសម្រាប់បដិវត្តន៍ឧស្សាហកម្ម៤.0 និងដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (SDGs) ឆ្នាំ២០៣០ (គ)រួមគ្នាដោះស្រាយបញ្ហាប្រឈមក្នុងសកលលោក រួមមាន ការប្រឆាំងចោរសមុទ្រ និងជំនួយគ្រោះមហន្តរាយ បម្រែបម្រួលអាកាសធាតុ និងរោគរាតត្បាត និង(ឃ)ការលើកកម្ពស់ការទាក់ទងគ្នារវាងប្រជាជននិងប្រជាជន ទំនាក់ទំនងវប្បធម៌ និងកិច្ចសន្ទនាអន្តរជំនឿនៅក្នុងតំបន់ដ៏ធំទូលាយនេះ។



© REUTERS/Kham

ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក លើកកម្ពស់គោលការណ៍ស្តីពីភាពបើកចំហ បរិយាបន្នភាព តម្លាភាព ការគោរពច្បាប់អន្តរជាតិ និងមជ្ឈភាពអាស៊ាននៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ នៅក្នុងរូបភាព តំណាងនានារបស់អាស៊ានបង្ហាញនៅលើអេក្រង់នៅពេលពួកគេចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៧ នៅប្រទេសវៀតណាម ក្នុងឆ្នាំ២០២០។




© REUTERS/Athit Perawongmetha

អាស៊ានបានរៀបចំចក្ខុវិស័យផ្ទាល់របស់ខ្លួនដែលហៅថា «ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក (AOIP)»។ នៅក្នុងរូបភាព មេដឹកនាំអាស៊ានបានចាប់ដៃគ្នានៅលើវេទិកាក្នុងពិធីបើកកិច្ចប្រជុំកំពូលអាស៊ាន នៅប្រទេសថៃ ក្នុងឆ្នាំ២០១៩ នៅពេលដែលចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ត្រូវបានអនុម័តជាផ្លូវការ។

# ២. ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក (AOIP) : ការពិភាក្សា ការឆ្លើយតប និងទិសដៅអនាគត



## ពេជ្រ ចាវ៉ាឌីន

អ្នកនាង ពេជ្រ ចាវ៉ាឌីន គឺជានាយករងប្រតិបត្តិនៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព (CICP) និងជាអ្នកសម្របសម្រួលនៃមជ្ឈមណ្ឌលសកលសម្រាប់ការសិក្សាពីមេគង្គ ( មជ្ឈមណ្ឌល GCMS-កម្ពុជា ជាបណ្តាញធនាគារខួរក្បាល Track II ផ្លូវការមួយនៃកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ )។ អ្នកនាងក៏ជាទីប្រឹក្សានៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ (MFAIC) នៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

ប្រទេសបារាំង និងពេលថ្មីៗនេះ អាល្លឺម៉ង់ក៏បានបញ្ចេញការរៀបចំចក្ខុវិស័យរបស់ខ្លួន រៀងៗខ្លួនផងដែរ។ ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ត្រូវបានអនុម័តជាផ្លូវការអំឡុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៤ ដែលធ្វើឡើងក្នុងទីក្រុងបាងកក កាលពីខែមិថុនា ឆ្នាំ២០១៩។ ខណៈមានទស្សនៈខ្វែងគ្នាលើការកំណត់និយមន័យនៃពាក្យនេះ ឥឡូវ «ឥណ្ឌូប៉ាស៊ីហ្វិក» កំពុងមានការយល់ថាជាសូចនាករភូមិសាស្ត្រមួយសម្រាប់តំបន់ដែលមានអន្តរទំនាក់ទំនងនិងសមាហរណកម្មយ៉ាងជិតស្និទ្ធ ដែលលាតសន្ធឹងរវាងតំបន់អាស៊ីប៉ាស៊ីហ្វិកនិងមហាសមុទ្រឥណ្ឌា «ដោយមានអាស៊ានដើរតួនាទីជាស្នូលនិងជាយុទ្ធសាស្ត្រមួយ»។[1] ដូចដែលឯកសារចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក បានកត់ត្រាថា៖

> *វាជាផលប្រយោជន៍របស់អាស៊ាន ដើម្បីដឹកនាំការរៀបចំនិម្មាបនកម្មសេដ្ឋកិច្ចនិងសន្តិសុខនិងធានាថា ជវភាពបែបនេះនឹងបន្តនាំមកនូវសន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពសម្រាប់ប្រជាជននៅអាស៊ីអាគ្នេយ៍ ព្រមទាំងនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកនិងមហាសមុទ្រឥណ្ឌាដ៏ធំល្វឹងល្វើយឬឥណ្ឌូប៉ាស៊ីហ្វិក។*[2]

ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ជាឯកសារ «សម្រាប់បង្ការ» មួយ ដើម្បីធានាថា អាស៊ានមានក្របខណ្ឌរបស់ខ្លួនផ្ទាល់និងកំណត់ជំហរដ៏ច្បាស់លាស់មួយទៅលើឥណ្ឌូប៉ាស៊ីហ្វិកដែលឯករាជ្យពីមហាអំណាចនានា ប៉ុន្តែក៏អនុញ្ញាតឱ្យអង្គការតំបន់មួយនេះសិក្សាពីសណ្តាប់ធ្នាប់តំបន់ប្រកបដោយជវភាពនិងពង្រឹងដំណើរការកសាងសហគមន៍របស់អាស៊ាន និងមជ្ឈភាពអាស៊ាន។




© REUTERS/Athit Perawongmetha

នាយករដ្ឋមន្ត្រីថៃ ប្រាយុទ្ធ ចាន់អូចា ប្រធាននៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៤ បានថ្លែងនៅសន្និសីទសារព័ត៌មានមួយអំឡុងកិច្ចប្រជុំកំពូលនៅសណ្ឋាគារ Athenee ក្នុងទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៩។

## ការសម្លឹងឱ្យកៀកលើចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក : ការពិភាក្សានិងការឆ្លើយតប

គំនិតផ្តួចផ្តើមនេះបានកើតមានឡើងយូរណាស់មកហើយ ដោយមានប្រទេសឥណ្ឌូណេស៊ីជាអ្នកនាំមុខ និងបានមើលឃើញការគាំទ្រពីប្រទេសជាច្រើនរួមទាំងតួអង្គក្រៅតំបន់។ គំនិតនេះបានលេចឡើងក្នុងខែមករា ឆ្នាំ២០១៨ អំឡុងកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន ហើយការពិភាក្សាបានបន្តចាប់តាំងពីពេលនោះមក។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកប្រាជ្ញមួយចំនួនក្នុងតំបន់ ថែមទាំងបានតាមដានឃើញគំនិត

1. Melissa Conley Tyler, “The Indo-Pacific is the New Asia,” The Interpreter, The Lowry Institute, June 28, 2019, https://www.lowyinstitute.org/the-interpreter/indo-pacific-new-asia.
2. ASEAN, “ASEAN Outlook on the Indo-Pacific,” 2019, https://asean.org/storage/2019/06/ASEAN-Outlook-on-the-Indo-Pacific_FINAL_22062019.pdf.

ផ្តួចផ្តើមនេះមានតាំងពីឆ្នាំ២០១៣ នៅពេលឯកឧត្តមបណ្ឌិត Marty Natalegawa ដែលជារដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ីនាពេលនោះ បានស្នើឱ្យមានសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការឥណ្ឌូប៉ាស៊ីហ្វិក។[3]

យ៉ាងណាមិញ ទាំងចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ទាំងក្តីសង្ឃឹមក្រោយទៀត ដែលចង់បានឥណ្ឌូប៉ាស៊ីហ្វិកប្រកបដោយបរិយាបន្ន ជាមួយនឹងចក្ខុវិស័យឥណ្ឌូប៉ាស៊ីហ្វិកដឹកនាំដោយអាស៊ាន ត្រូវបានរៀបចំឡើងតាមរយៈវិធានការកសាងទុកចិត្តនិងភាពជឿជាក់។ ការអនុម័តចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក គឺមានសារៈសំខាន់យ៉ាងជាក់ស្តែងជាពិសេស បើពិចារណាពីក្តីបារម្ភដែលកាន់តែកើនឡើងពាក់ព័ន្ធនឹងសង្គ្រាមពាណិជ្ជកម្មសហរដ្ឋអាមេរិក-ចិន និងផលប៉ះពាល់របស់វាទៅលើសេដ្ឋកិច្ចរបស់ប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ជាច្រើន ព្រមទាំងសន្តិសុខនិងស្ថិរភាពក្នុងតំបន់ទាំងមូល ភាពតានតឹងអាចឈានទៅរក «សង្គ្រាមពហុមុខព្រួញ»។[4]

ការជំរុញឱ្យមាន «ទម្រង់ឯកភាពជាឯកច្ឆន្ទ» ផ្តល់សញ្ញាយ៉ាងច្បាស់ថា វាជាដំណើរដ៏លំបាកដើម្បីឱ្យសមាជិកអាស៊ានយល់ស្របរួមគ្នាទៅលើឯកសារចក្ខុវិស័យអាស៊ាន ដោយមានរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយបានលាបពណ៌សិង្ហបុរីថាជា «អ្នកធ្វើឱ្យខូចការ» និងបង្កក្តីបារម្ភពីសមភាគីឥណ្ឌូណេស៊ីថា ឯកសារចក្ខុវិស័យនេះអាចមិនបានចុះហត្ថលេខាតាមផែនការអំឡុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៤ទេ។[5]

សិង្ហបុរីក៏បានតបតថា ខ្លួនបានព្យាយាម «រៀបចំខ្លឹមសារឡើងវិញ» ក្នុងឯកសារព្រាងដោយបញ្ចូលឱជារសបន្ថែមនៃគោលការណ៍ស្នូលរបស់អាស៊ាន ដូចជា សេរីភាពនាវាចរណ៍និងការហោះហើរ។ សមាជិកបីផ្សេងទៀត មានកម្ពុជា ម៉ាឡេស៊ី និងហ្វីលីពីន ក៏បានព្យាយាមកែសម្រួលអត្ថបទមុនកិច្ចប្រជុំកំពូលផងដែរ។[6]

ចំពោះការពន្យារពេលក្នុងការឆ្លើយតបចំពោះទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកដទៃទៀត អាស៊ានត្រូវមានការប្រុងប្រយ័ត្ន ដើម្បីកុំឱ្យមើលឃើញថា ខ្លួនប្រឆាំងទៅនឹងនិន្នាការនេះ។ បើតាមទស្សនៈអាស៊ាន ទស្សនទានឥណ្ឌូប៉ាស៊ីហ្វិករបស់ក្រុមចតុភាគី ចំណុចគួរកត់សម្គាល់គឺបានផាត់ប្រទេសចិនចេញជាជាងការបញ្ចូលទីក្រុងប៉េកាំងទៅក្នុងក្របខណ្ឌតំបន់ដ៏ធំនេះ។[7]

ចំណងជើងដើមនៃចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ត្រូវបានរាយការណ៍ថា «ចក្ខុវិស័យឥណ្ឌូប៉ាស៊ីហ្វិកអាស៊ាន» ហើយអ្នកជំនាញក្នុងតំបន់មួយចំនួនសង្ស័យថា ការផ្លាស់ប្តូរចំណងជើងបង្ហាញថា រដ្ឋសមាជិកមួយចំនួនមានយោបល់ផ្ទុយគ្នាអំពីការក្តោបទស្សនៈក្នុងតំបន់ខ្លួនឯងនេះរួមគ្នា។ ចំណងជើងដំបូងក៏អាចបង្ហាញតម្រុយថា «ឥណ្ឌូប៉ាស៊ីហ្វិក» កំពុងបញ្ចូលទៅក្នុង «វប្បធម៌យុទ្ធសាស្ត្រ» របស់ អាស៊ាន។ យ៉ាងណាមិញ ចំណងជើងដែលបានជ្រើសរើសសម្រាប់ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក មានការមើលឃើញថា ដាក់ «ឥណ្ឌូប៉ាស៊ីហ្វិក» ក្នុងចម្ងាយសមស្របមួយនិងបានចាត់ទុកជា «អង្គខាងក្រៅ» ពីដែនអាស៊ានជំនួសវិញ។ ទោះបីជាការអនុម័តចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ពិតជាបង្ហាញពីការឯកភាពជាឯកច្ឆន្ទរបស់អាស៊ានក៏ដោយ ក៏សំណួរទាក់ទងគ្នាហូរហែលេចចេញមកនៅពេលរដ្ឋសមាជិកនឹងបញ្ចូលឯកសារជាផ្ទៃក្នុងកម្រិតខុសគ្នា ហើយអ្នកខ្លះមើលឃើញចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកថាជា «ការសរសេរទូទៅរបស់អាស៊ាន» ច្រើនជាង។[8]

ការបង្កើតគំនិតផ្តួចផ្តើមដែលធ្វើក្នុងតំបន់ខ្លួនឯង គឺជាវិធីសាស្ត្រការទូតមួយមានសុវត្ថិភាពជាងសម្រាប់អាស៊ាន ពេលកំពុងស្ថិតនៅក្នុងភាពតានតឹងកាន់តែខ្លាំងឡើងរវាងមហាអំណាចនោះ។ ដូច្នេះ ជំនួសឱ្យការធ្វើតាមគ្នា ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ដើរតួជាឯកសារចម្បងមួយនិងជាជំហរក្នុងតំបន់ប្រឆាំងនឹងវាំងននខាងក្រោយទស្សនទានមួយចំនួនស្តីពីឥណ្ឌូប៉ាស៊ីហ្វិកដែលផាត់ប្រទេសចិនចេញដោយចំហនោះ។ ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកបង្ហាញពីវិស័យសហប្រតិបត្តិការចម្បងចំនួនបួន រួមមាន សន្តិសុខដែនសមុទ្រ ការតភ្ជាប់ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិឆ្នាំ២០៣០ និងការអភិវឌ្ឍសេដ្ឋកិច្ច។

អាស៊ានចង់ឱ្យចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកដើរតួនាទីសំខាន់មួយនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកដ៏ធំទូលាយ ដោយការប្រើប្រាស់វេទិកាសន្ទនាដែលមានស្រាប់ រួមមាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) វេទិកាតំបន់អាស៊ាន (ARF) កិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានបូក (ADDM+) និងអាស៊ានបូកមួយ ដើម្បីបង្កើតក្របខណ្ឌមួយផ្អែកលើច្បាប់និងគោលការណ៍ស្នូលនៃការពង្រឹងមជ្ឈភាពអាស៊ាន បរិយាបន្នតម្លាភាព ភាពបើកចំហ និងការគោរពច្បាប់អន្តរជាតិ។ លើសពីនេះទៀត ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកមានបំណងពង្រីកវិសាលភាពនៃការចូលរួមរបស់ខ្លួនទៅកាន់ភាគីពាក់ព័ន្ធនៅខាងក្រៅផ្សេងទៀត និងដៃគូអភិវឌ្ឍទៅលើវិស័យសហប្រតិបត្តិការទាំងនោះផងដែរ។

## ទង់ជាតិរបស់រដ្ឋសមាជិកអាស៊ាន : អាស៊ានប្រកាន់ជំហរមួយលើ «ឥណ្ឌូប៉ាស៊ីហ្វិក»

ថ្វីបើមានវឌ្ឍនភាពវិជ្ជមានក៏ដោយ ក៏នៅមានបញ្ហាប្រឈមឥតឈប់ឈរនៅពេលខាងមុខដែរ សមាជិកអាស៊ានត្រូវការក្តោបយក

3. William Choong, “Indonesia, ASEAN and the Return of the Indo-Pacific Strategy,” Australian Institute for International Affairs, July 17, 2019, https://www.internationalaffairs.org.au/australianoutlook/indonesia-asean-return-indopacific-strategy/.

4. Dian Septiari, “ASEAN leaders adopt Indonesia-led Indo-Pacific outlook,” The Jakarta Post, June 23, 2019, https://www.thejakartapost.com/seasia/2019/06/23/asean-leaders-adopt-indonesia-led-indo-pacific-outlook.html.

5. Resty Woro Yuniar, “Indonesia reveals frustration with Singapore over delay in ASEAN adopting President Joko Widodo’s Indo-Pacific concept,” South China Morning Post, https://www.scmp.com/news/asia/southeast-asia/article/3014651/vision-impaired-singapore-deliberately-delaying-indonesian

6. Tang Siew Mun, “Asean found its voice with the Indo-Pacific concept. Now it has to use it or risk losing out,” South China Morning Post, June 24, 2019, https://www.scmp.com/week-asia/geopolitics/article/3015809/asean-found-its-voice-indopacific-concept-now-it-has-use-it.

7. Choong. “Indonesia, ASEAN and the Return.”

8. Hoang Thi Ha & Glenn Ong, “Revised Title ‘ASEAN Outlook on the Indo-Pacific’ Hints at Ambivalence,” ISEAS Yusof Ishak Institute, 2019, https://www.iseas.edu.sg/media/commentaries/revised-title-asean-outlook-on-the-indopacific-hints-at-ambivalence-by-hoang-thi-ha-and-glenn-ong/.




ប្រទេសជាសមាជិកអាស៊ានបង្កើតជាចំណុចសំខាន់នៃតំបន់ឥណ្ឌូប៉ាស៊ីហ្វិកដូចបានពិពណ៌នានៅក្នុងឥណ្ឌូប៉ាស៊ីហ្វិកសេរី និងបើកចំហ។

ការចូលរួមបែបបុរេសកម្មតាមរយៈ«កិច្ចសហប្រតិបត្តិការជាក់ស្តែង» អភិវឌ្ឍទិសដៅជាយុទ្ធសាស្ត្រនិងច្បាស់លាស់មួយដើម្បីជំរុញចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកឱ្យដំណើរការទៅមុខប្រកប ដោយប្រសិទ្ធភាព និងព្យាករព្រមទាំងត្រៀមខ្លួនសម្រាប់ ទិដ្ឋភាពយុទ្ធភូមិសាស្ត្រប្រកបដោយជវភាព។

## ទិសដៅអនាគត : តើយើងកំពុងឆ្ពោះទៅណា ?

ការអនុម័តចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក មានការ ទទួលស្វាគមន៍ដោយតួអង្គខាងក្រៅ អាស៊ាន ជាពិសេស តួអង្គ ដែលមានចក្ខុវិស័យឥណ្ឌូប៉ាស៊ីហ្វិករបស់ពួកគេរៀងៗខ្លួន ដែលបានអនុម័តមុនចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក។ ខណៈចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក អះអាងជាថ្មីពីគោលការណ៍របស់អាស៊ាននិងបំណងរបស់ខ្លួនដែលចង់បានសណ្តាប់ធ្នាប់តំបន់ដែលមានស្ថិរភាពនិងសន្តិភាព អ្នកវិភាគបានអះអាង ថា មិនមានអ្វីថ្មីច្រើនទេដែលបានបន្ថែមចូលសេចក្តីថ្លែងជាយុទ្ធសាស្ត្រតំបន់អាស៊ានដែលមានស្រាប់នោះទេ។[9]

បើទោះបីជាការណ៍ពិតដែលចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក អាចបន្ថយសម្ពាធរបស់រដ្ឋសមាជិកមួយចំនួនពីការប្រកាន់យកភាគីណាមួយ ឬគាំទ្រទស្សនៈនានាដែលមានស្រាប់ចំពោះមុខភាពតានតឹងកាន់តែខ្លាំងរវាងមហាអំណាចក៏ដោយ ក៏យន្តការនៃចក្ខុវិស័យ អាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកផ្ទាល់ ចាំបាច់ ត្រូវបានអភិវឌ្ឍសម្រាប់ គោលនយោបាយដែលត្រូវបានគេដឹងច្បាស់លាស់ទាំងផ្ទៃក្នុង អាស៊ាន ទាំងខាងក្រៅនៅក្នុងសង្វៀនអន្តរជាតិ។ លើសពីនេះទៀត អាស៊ានត្រូវដឹកនាំខ្លួនឯងដោយប្រុងប្រយ័ត្នក្នុងពេលមាននិម្មាបនកម្មសន្តិសុខតំបន់ដ៏ស្មុគស្មាញនិងផលប៉ះពាល់នៃទំនាក់ទំនង មហាអំណាចដែលប្រឈមមុខដាក់គ្នា។

ខណៈអ្នកសង្កេតការណ៍តែងតែទាញជម្លោះសហរដ្ឋអាម៉េរិក-ចិន ចូលក្នុងការបរិយាយពីចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ឯកសារនេះផ្ទាល់ ស្ទើរតែមិនបាននិយាយអំពីបញ្ហាប្រឈមខាង យុទ្ធសាស្ត្រដែលកំពុងប្រឈមក្នុងតំបន់នេះ ដោយទុកសង្គ្រាម ពាណិជ្ជកម្មសហរដ្ឋអាម៉េរិក-ចិននិងវិធីសាស្ត្ររបស់ អាស៊ាន ក្នុងការប្រឈមឥទ្ធិពលមិនផ្ទាល់របស់សង្គ្រាមនេះមួយអន្លើសិន។ ខុសពីឯកសារយុទ្ធសាស្ត្រស្តីអំពីទស្សនទានឥណ្ឌូប៉ាស៊ីហ្វិក ដទៃទៀត ដែលការគំរាមកំហែងសកលលោកនិងបញ្ហាប្រឈម នៃសន្តិសុខតំបន់ត្រូវបានរៀបរាប់យ៉ាងច្បាស់លាស់នោះ ចក្ខុវិស័យ អាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកគោរពតាមបទដ្ឋាន អាស៊ានដែល និយាយអំពីសណ្តាប់ធ្នាប់តំបន់ផ្អែកលើច្បាប់និងប្រកាន់ខ្ជាប់នូវកិច្ចសន្ទនាពិគ្រោះយោបល់និងកិច្ចសហប្រតិបត្តិការជាជាងការ ប្រឈមមុខដាក់គ្នា។

អ្នកជំនាញក្នុងតំបន់បានសង្កេតមើលថា តើ ទិដ្ឋភាព «សណ្តាប់ធ្នាប់ផ្អែកលើច្បាប់» និង «នីតិរដ្ឋ» មានលក្ខណៈគួរឱ្យចាប់អារម្មណ៍ ខ្លាំងយ៉ាងណា និងមានរហូតដល់កម្រិតមួយដែលអ្នកជំនាញមួយ ចំនួនថែមទាំងប៉ាន់ប្រមាណថាគោលបំណងគឺ បន្ទន់ជំហរចំពោះ ចិន។ អ្នកជំនាញមួយរូបបានចោទសួរ៖ «តើអាស៊ានផ្លាស់ប្តូរជំហរ ឆ្ពោះទៅរកសណ្តាប់ធ្នាប់ផ្អែកលើច្បាប់ដោយសារតែសម្ពាធរបស់ចិន ដើម្បីស្វែងរកដំណោះស្រាយនៅសមុទ្រចិនខាងត្បូង ឬក៏ចិនទទួល

9. Hoang Thi Ha & Glenn Ong, "Revised Title 'ASEAN Outlook.'"

យកការអនុវត្តរបស់អាស៊ានដោយសារការអនុវត្តនោះមិនធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់ខ្លួនឬ ?»[10]

ឧត្តមសេនីយ៍ Wei Fenghe រដ្ឋមន្ត្រីក្រសួងការពារជាតិចិន បានសរសើរជំហររបស់អាស៊ាននៅក្នុងកិច្ចសន្ទនាសាំងហ្គ្រីឡា (Shangri-La Dialogue) នាពេលថ្មីៗនេះ និងបានការពារពីគំនិតដែលថា គួរតែមានសណ្តាប់ធ្នាប់តំបន់ដែលជាជម្រើសមួយដើម្បីដោះស្រាយបញ្ហាក្នុងតំបន់តាមរយៈយន្តការតំបន់ជាមួយចរិតលក្ខណៈតំបន់ផ្ទាល់ និងបាននិយាយថា ច្បាប់អន្តរជាតិមិនមែនអាចប្រើការបានរហូតនោះទេ។ ទស្សនវិស័យនេះបានបង្កក្តីបារម្ភដែលវានឹងមានន័យថា ការផ្តាច់អាស៊ានចេញពីភាគីពាក់ព័ន្ធនៃឥណ្ឌូប៉ាស៊ីហ្វិកផ្សេងទៀត ដែលអ្នកវិភាគបានព្រមានថា វាមានន័យថាជាការប្រឈមដល់មជ្ឈភាពអាស៊ាននិងអនាគតរបស់សហគមន៍ឥណ្ឌូប៉ាស៊ីហ្វិក។[11]

បញ្ហាតានតឹងមួយផ្សេងទៀតទាក់ទិននឹងបរិបទដែនសមុទ្រ ដែលជាវិស័យមួយក្នុងចំណោមវិស័យ កិច្ចសហប្រតិបត្តិការចម្បងៗ របស់ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ដែលឥណ្ឌូប៉ាស៊ីហ្វិក គួរត្រូវបានយល់ថាជា «លំហសមុទ្រគ្មានព្រំដែន»។ ទោះបីយ៉ាងណាក៏ដោយ ក៏ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក បានជៀសវាងពីការប្រើពាក្យ «តំបន់ប្រតិបត្តិការយុទ្ធភូមិសាស្ត្រតែមួយ» ដែលបានព្រាងពីដំបូងដោយឥណ្ឌូណេស៊ី។ អាស៊ានបានព្យាយាមឈប់ប្រើប្រាស់ពាក្យដែលមានការបង្កប់អត្ថន័យយោធា ហើយដែលជាការបញ្ជាក់ច្បាស់ពីការប្រឈមមុខខាងយោធាឬសម្ព័ន្ធមិត្តយោធាណាមួយនៅក្នុងសង្វៀនឥណ្ឌូប៉ាស៊ីហ្វិកនោះ។[12]

ចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ពិតជាបង្ហាញពីការប្តេជ្ញាចិត្តនិងសាមគ្គីភាពដែលបានធ្វើជាថ្មីរបស់អាស៊ានក្នុងការបង្កើតនិម្មាបនកម្មតំបន់ប្រកបដោយជវភាព។ ទោះបីយ៉ាងណាក៏ដោយ ក៏អាស៊ានត្រូវគិតឡើងវិញពីផែនការល្បែងរបស់ខ្លួនដើម្បីជៀសវាងនូវវិធីសាស្ត្រមួយ «ដែលគ្មានអ្វីផ្លាស់ប្តូរសោះ»។[13]

ជាបឋម សមាជិកអាស៊ានត្រូវប្រកាន់យកការចូលរួមផ្នែកការទូតបែបបុរេសកម្មក្នុងគោលបំណងដើម្បីចាត់ចែងនិងដឹកនាំសណ្តាប់ធ្នាប់តំបន់ទាំងលើកិច្ចការក្នុងស្រុក ទាំងកិច្ចការក្នុងតំបន់។ សមាជិកអាស៊ានត្រូវទាញយកប្រយោជន៍ពីវេទិកានិងយន្តការអាស៊ានដែលមានស្រាប់ ដើម្បីឱ្យកាន់តែមានភាពបុរេសកម្ម ដែលការធ្វើដូច្នេះ នាំឱ្យអាស៊ានមិនគ្រាន់តែត្រូវបានមើលឃើញថាជា «ក្រុមដែលបានតែនិយាយ»។

អាស៊ានត្រូវតែធ្វើឱ្យមានភាពងាយស្រួលជាមួយនឹងកិច្ចពិភាក្សាបញ្ហាសន្តិសុខធំៗ ព្រោះថា ការពន្យារពីដំណើរការនៃកិច្ចពិភាក្សានឹងនាំឱ្យបាត់បង់តួនាទីនិងភាពប្រសិទ្ធភាពរបស់ខ្លួន។ ចំពោះកិច្ចការក្នុងតំបន់ សំណួរគឺថា តើរដ្ឋសមាជិកនីមួយៗ នឹងមានឆន្ទៈកម្រិតណាដើម្បីតម្កល់ផលប្រយោជន៍តំបន់ជាអាទិភាពនិងមានអារម្មណ៍រួមគ្នាទៅលើចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកដែលមាននោះ។ តើរដ្ឋសមាជិកអាចផ្លាស់ប្តូរយន្តការអាស៊ានកម្រិតណាពីវិធីសាស្ត្របច្ចុប្បន្ននៃ «កិច្ចសហប្រតិបត្តិការប្រតិបត្តិ» ដែលអ្វីទាំងឡាយត្រូវបានរៀបចំឱ្យដំណើរការ ទៅជា «កិច្ចសហប្រតិបត្តិការជាក់ស្តែង» ដែលសកម្មភាពជាក់ស្តែងត្រូវបានបញ្ជាក់ដើម្បីជំរុញកិច្ចសហប្រតិបត្តិការឈានទៅមុខ ?

ទីពីរ មានសំណួរត្រិះរិះមួយដែលត្រូវតែសួរពាក់ព័ន្ធនឹងប៉ារ៉ាម៉ែត្រភូមិសាស្ត្រ តើចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកគ្របដណ្តប់តំបន់ណា ? ទោះបីជាពាក្យ «ឥណ្ឌូប៉ាស៊ីហ្វិក» ផ្តល់មានការឯកភាពយ៉ាងទូលំទូលាយថា ជាតំបន់ដែលលាតសន្ធឹងពីអាស៊ីប៉ាស៊ីហ្វិកទៅកាន់មហាសមុទ្រឥណ្ឌាក៏ដោយ ក៏ទីតាំងជាក់ស្តែងព្រំដែននិងចម្ងាយ គឺមិនច្បាស់លាស់និងមិនបានកំណត់នៅក្នុងចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកនោះទេ។ ខណៈមានក្តីរំពឹងច្រើនលើពីចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកផ្ទាល់ដើម្បីឱ្យមានភាពច្បាស់លាស់ ដោយពិចារណាតាមបែបអាស៊ាន វាជាចំណុចគួរឱ្យកត់សម្គាល់សម្រាប់ពេលអនាគត។ អ្នកជំនាញក៏បានព្រមានផងដែរថា វានឹងពិបាកសហការជាមួយដៃគូដែលមានសក្តានុពលនាពេលអនាគត «ដោយមិនដឹងថាពួកគេគឺជានរណា» ទាំងដៃគូ ទាំងវិសាលភាពព្រំដែន។[14]

ជាចុងក្រោយ តើអាស៊ានបានត្រៀមខ្លួនសម្រាប់ដំណាក់កាលបន្ទាប់នៃទិដ្ឋភាពយុទ្ធភូមិសាស្ត្រ ភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ចដែរឬទេ ? ដូចឯកអគ្គរាជទូត ពូ សុធីរៈ នាយកប្រតិបត្តិវិទ្យាស្ថានខ្មែរសំរាប់សហប្រតិបត្តិការ និងសន្តិភាព បានបញ្ជាក់ថា៖

> *ខណៈចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិកកំណត់សាមគ្គីភាពសាជាថ្មីក្នុងចំណោមមេដឹកនាំអាស៊ានពេលមានការផ្លាស់ប្តូរភូមិសាស្ត្រនយោបាយយ៉ាងឆាប់រហ័សដែលបានលេចឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ចក្ខុវិស័យអាស៊ានមិនបានបំពេញជាគំនិតផ្តួចផ្តើម ប្រកបដោយអត្ថន័យ ដែលអាចរៀបចំឡើងវិញនូវនិម្មាបនកម្មសន្តិសុខនយោបាយតំបន់ដែលមានស្រាប់ ដើម្បីធានានូវស្ថាប័ននីយកម្មស៊ីជម្រៅរបស់មជ្ឈភាពអាស៊ានក្នុងចំណោមរដ្ឋជាសមាជិកទេ។*
>
> *ក្រៅពីគ្មានភាពជាអ្នកដឹកនាំរួមគ្នា អាស៊ានខ្វះនូវទិសដៅយុទ្ធសាស្ត្រច្បាស់លាស់មួយដើម្បីជួយរៀបចំសន្តិសុខនិងសេដ្ឋកិច្ចរបស់រដ្ឋជាសមាជិកនីមួយៗហួសពីតំបន់អាស៊ីអាគ្នេយ៍។ មានតែតាមរយៈភាពច្បាស់លាស់ជាយុទ្ធសាស្ត្រដែលមានភាពប្រសើរឡើង ដែលភ្ជាប់ជាមួយក្របខណ្ឌបញ្ញវន្តមានភាពស៊ីជម្រៅទេ ទើបអាស៊ាននឹងអាចធ្វើដំណើរដោយសុវត្ថិភាពទៅក្នុងដែនដែលមិនស្គាល់ច្បាស់នៃតំបន់ឥណ្ឌូប៉ាស៊ីហ្វិកដ៏ធំទូលាយនោះ។ ចំពោះមុខតថភាពទាំងនេះ អាស៊ានត្រូវគិតគូរឡើងវិញពីចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក។[15]*

**10.** Sophie Boisseau du Rocher, "Great Expectations: ASEAN and the Indo-Pacific Concept," The Diplomat, June 17, 2019, https://thediplomat.com/2019/06/great-expectations-asean-and-the-indo-pacific-concept/.

**11.** Ibid.

**12.** Hoang Thi Ha, "ASEAN Outlook on the Indo-Pacific: Old Wine in New Bottle?" ISEAS Perspective, 51, (2019), https://www.iseas.edu.sg/images/pdf/ ISEAS_Perspective_2019_51.pdf.

**13.** Tang Siew Mun, "Asean found its voice."

**14.** Ibid.

**15.** Pou Sothirak. "Rethinking 'ASEAN Outlook on the Indo-Pacific,'" Bangkok Post, July 20, 2019, https://www.bangkokpost.com/opinion/opinion/1715795/re-thinking-asean-outlook-on-indo-pacific.




អគ្គលេខាធិការអាស៊ាន លោក Lim Jock Hoi ថ្លែងសុន្ទរកថាអំឡុងពិធីសម្ពោធអគារលេខាធិការដ្ឋានអាស៊ានថ្មី ក្នុងទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៩។




សហរដ្ឋអាមេរិក អូស្ត្រាលី ឥណ្ឌា និងជប៉ុនបង្កើតជាប្រទេសនៃក្រុមចតុភាគី (Quad) ដែលជាញឹកញាប់សំដៅដល់ «ការចូលរួមទប់ទល់» ជាមួយចិនដោយអ្នកធ្វើអត្ថាធិប្បាយមួយចំនួន។

# ៣. ការយល់ច្រឡំនៃការទប់ទល់និងយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិក : គោលនយោបាយសហរដ្ឋអាមេរិកឆ្ពោះទៅរកចិន



**បណ្ឌិត Bradley J. Murg**

បណ្ឌិត Bradley J. Murg គឺជាទីប្រឹក្សាជាន់ខ្ពស់និងអ្នកស្រាវជ្រាវជាន់ខ្ពស់មួយរូបនៅវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការ និងសន្តិភាពបន្ថែមពីលើការតែងតាំងផ្នែកសិក្សាស្រាវជ្រាវផ្សេងៗ។ វិចារណកថារបស់លោកតែងតែលេចឡើងក្នុងសារព័ត៌មាន The Diplomat, The Asia Times, Nikkei, និង South China Morning Post។

សំណួរដែលសួរថាត្រូវស្វែងយល់ពីគោលនយោបាយអាម៉េរិកឆ្ពោះទៅរកចិនដោយរបៀបណា បានក្លាយជាប្រភពមួយនៃការខ្វែងគំនិតគ្នាយ៉ាងខ្លាំងនៅពេលពិភាក្សាពីអនាគតរបស់គោលនយោបាយឥណ្ឌូប៉ាស៊ីហ្វិក និងទំនាក់ទំនងសហរដ្ឋអាម៉េរិក-ចិន ដែលកំពុងមានការវិវត្ត។ ឥឡូវនេះវិធីសាស្រ្តរបស់រដ្ឋាភិបាលទីក្រុងវ៉ាស៊ីនតោននិងគោលនយោបាយឥណ្ឌូប៉ាស៊ីហ្វិក ជារឿយៗត្រូវបានគេសំដៅទៅដល់គោលនយោបាយនៃ «ការទប់ទល់» ដែលផ្ទុយទៅនឹងគោលនយោបាយជាច្រើនទសវត្សរ៍បែប«ការចូលរួម» នោះ។ អ្នកប្រាជ្ញនិងអ្នកវិភាគជាច្រើនបានប្រើប្រាស់បញ្ញត្តិកូនកាត់មួយដើម្បីកំណត់និយមន័យ ស្ថានភាពបច្ចុប្បន្ន ដោយបញ្ចូលពាក្យទាំងពីរនៅក្នុងទម្រង់នៃពាក្យបង្កើតថ្មីមួយ «ការទប់ទល់-ការចូលរួម» (con-gagement)។




រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាម៉េរិក Antony Blinken បានមានប្រសាសន៍ពេលជួបតទល់ជាមួយទីប្រឹក្សារដ្ឋនិងជារដ្ឋមន្ត្រីការបរទេសចិន លោក Wang Yi នៅក្នុងពិធីបើកកិច្ចពិភាក្សាសហរដ្ឋអាម៉េរិក-ចិន នៅសណ្ឋាគារ The Captain Cook ក្នុងទីក្រុងAnchorage រដ្ឋអាឡាស្កា សហរដ្ឋអាម៉េរិក កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១។

ការធ្វើបញ្ញត្តិនីយកម្មនៅក្នុងភូមិសាស្រ្តនយោបាយ មិនមែនគ្រាន់តែនៅក្នុងទ្រឹស្តីទំនាក់ទំនងអន្តរជាតិប៉ុណ្ណោះទេ ប៉ុន្តែ ក៏ត្រូវផ្តល់ភាពច្បាស់លាស់ពាក់ព័ន្ធនឹងគោលបំណងរបស់រដ្ឋមួយនិងសកម្មភាពដែលអាចមានរបស់រដ្ឋនៅពេលធ្វើការសម្រេចចិត្តសំខាន់ៗ។ លោក Evan Medeiros និងអ្នកនិពន្ធផ្សេងទៀតបានកត់សម្គាល់អំឡុងពេលរដ្ឋបាលរបស់លោកត្រាំថា គោលនយោបាយសហរដ្ឋអាម៉េរិកចំពោះមេដឹកនាំមួយចំនួនក្នុងអាស៊ាន «មើលទៅដូចជាការទប់ទល់» ដោយបានគូសបញ្ជាក់បន្ថែមពីសារៈសំខាន់នៃការបញ្ជាក់ឱ្យបានច្បាស់លាស់។[1]

ជាអកុសល បច្ចុប្បន្ន ពាក្យថាការទប់ទល់នេះជាទូទៅ នៅតែត្រូវបានយកទៅអនុវត្តខុសនិងប្រើមិនត្រឹមត្រូវនៅក្នុងលក្ខណៈសាមញ្ញនិងមិនពាក់ព័ន្ធប្រវត្តិសាស្រ្ត ហើយអាចថែមទាំងត្រូវបានប្រើប្រាស់ដោយមនុស្សមួយចំនួនជាប្រភេទអាវុធខាងពាក្យសម្តី ប្រឆាំងទាំងសហរដ្ឋអាម៉េរិកទាំង សមាជិកផ្សេងទៀតនៃសម្ព័ន្ធចតុភាគី Quad (អូស្រ្តាលី ឥណ្ឌា និងជប៉ុន) ហើយទីបញ្ចប់ ធ្វើឱ្យមានភាពតានតឹងកាន់តែខ្លាំងជាជាងការកាត់បន្ថយភាពតានតឹងទាំងនោះ។

កាលពីខែមេសា ជាការឆ្លើយតបចំពោះសំណួរមួយពាក់ព័ន្ធនឹងសកម្មភាពរបស់ចិនប្រឆាំងនឹងប្រជាជន Uighur របស់ខ្លួននោះ អ្នកនាំពាក្យមួយរូបរបស់ក្រសួងការបរទេសចិន គឺលោកស្រី Hua Chunying បានបញ្ជាក់ថា៖ «ពួកគេចង់បង្កើតអ្វីមួយដែលគេហៅ «បញ្ហានៅស៊ីនជាំង» ដើម្បីទប់ទល់ការអភិវឌ្ឍរបស់ចិននិងបំផ្លាញសន្តិសុខនិងស្ថិរភាពរបស់ចិន»។ លោកស្រីក៏បានបន្តថាថា សម័យកាលដែលការទប់ទល់ចិនថាអាចទៅរួចនោះគឺចប់ហើយ ដែលការនិយាយនេះគឺជាការថ្លែងបញ្ជិតបញ្ជៀងពីអត្ថិភាពនៃគោលនយោបាយទប់ទល់របស់សហរដ្ឋអាម៉េរិកប្រឆាំងចិននោះ។[2]

អ្វីដែលបញ្ជាក់កាន់តែច្បាស់ទៀតនោះ មន្ត្រីក្រសួងការបរទេសចិនដែលគេស្គាល់យ៉ាងច្បាស់ថាជា «អ្នកចម្បាំងចចក» គឺលោក Zhao Lijian ត្រូវបានសារព័ត៌មាន The Associated Press ដកស្រង់សម្តីនៅ ក្នុងខែមេសា ដោយនិយាយថា៖ «ការទប់ទល់និងការសង្កត់សង្កិនដោយ

1. Demetri Sevastapolu, "Trump gives glimpse of 'Indo-Pacific' strategy to counter China," The Financial Times, Nov. 11, 2017.

2. Remarks by Hua Chunying, Chinese Ministry of Foreign Affairs at press briefing in Beijing, March 31, 2021, accessed on May 1, 2021, http://kh.china-embassy.org/eng/fyrth_3/t1865988.htm.

សហរដ្ឋអាម៉េរិកមិនអាចបញ្ឈប់ សន្ទុះវឌ្ឍនភាពបច្ចេកវិទ្យា និងវិទ្យាសាស្ត្ររបស់ចិនបានទេ ប៉ុន្តែ វាគ្រាន់តែជាការពង្រឹងការប្តេជ្ញាចិត្តរបស់ចិន ហើយនឹងធ្វើនវានុវត្តន៍ដោយឯករាជ្យទៅវិញ»។[3] ការប្រើប្រាស់ពាក្យ «ទប់ទល់» និង «ការទប់ទល់» របស់រដ្ឋាភិបាលទីក្រុងប៉េកាំងបានក្លាយជាអត្ថបដិរូបជាទៀងទាត់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះដូចបានបរិយាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយនិងសេចក្តីថ្លែងការណ៍ផ្លូវការជាភាសាចិននានា។[4] វិធីសាស្ត្រប្រឆាំងនឹងការរះឡើងរបស់ចិន គឺហាក់បីដូចជាបានរៀបចំឡើងដើម្បីពង្រឹងបន្ថែមនិទានកថាដដែលៗរបស់រដ្ឋាភិបាលទីក្រុងប៉េកាំងស្តីពីភាពជាជនរងគ្រោះរបស់ចិន និង «សតវត្សរ៍នៃការប្រមាថមាក់ងាយ» ដែលគណបក្សកុម្មុយនីស្តចិនតែងតែផ្តោតលើរឿងទាំងនេះដើម្បីពង្រឹងធម្មានុរូបភាពរបស់ខ្លួន ដែលជាប្រធានបទមួយមានការពិភាក្សាជាច្រើននៅក្នុងទ្រឹស្តីសិក្សាស្រាវជ្រាវ។[5]

រដ្ឋាភិបាលទីក្រុងប៉េកាំងបន្តព្យាយាមប្រើវិធីពីរយ៉ាងគឺ វិធីទីមួយ រដ្ឋាភិបាលប៉េកាំងបង្ហាញខ្លួនឯងយ៉ាងសកម្មថា ជាជនរងគ្រោះទាំងប្រវត្តិសាស្ត្រ (ដែលវាជាការណ៍ពិតឥតសង្ស័យ ដោយអំណានជាមូលដ្ឋានពីប្រវត្តិសាស្ត្រចិនក្នុងសតវត្សរ៍ទី១៩និងដើមសតវត្សរ៍ទី២០ បានបង្ហាញយ៉ាងច្បាស់) ហើយនិងសម័យបច្ចុប្បន្ន (ដោយសារគោលនយោបាយទប់ទល់របស់សហរដ្ឋអាម៉េរិកដែលត្រូវបានចោទប្រកាន់ និងការវាយប្រហារចេញពីក្នុងចិត្តនិងជាទៀងទាត់របស់រដ្ឋាភិបាលប៉េកាំងប្រឆាំងរដ្ឋណាមួយដែលជំទាស់សំណើឬសកម្មភាពរបស់ខ្លួនក្នុងលក្ខណៈមួយដែលខ្លួនយល់ថា មិនអាចទទួលយកបាន តួយ៉ាង អូស្ត្រាលី កាណាដា ស៊ុយអែត ន័រវែស)។ ក្នុងវិធីម្យ៉ាងទៀត នៅពេលដំណាលគ្នា រដ្ឋាភិបាលប៉េកាំងបានពង្រាយឥទ្ធិពលយោធានិងសេដ្ឋកិច្ចពាសពេញតំបន់អាស៊ីអាគ្នេយ៍ និងពិពណ៌នាអនាគតរបស់ខ្លួនថា ជាមហាអំណាចត្រួតត្រានៅក្នុងតំបន់ដែលជៀសមិនផុត ដូចជា សកម្មភាពថ្មីៗនៅក្នុងសមុទ្រហ្វីលីពីនខាងលិច ដោយធ្វើឱ្យជារឿងចាំ បាច់សម្រាប់ការពង្រាយទ័ពឡើងវិញដែលសមាមាត្រទៅនឹងកងនាវាហ្វីលីពីននេះគឺជាករណីដែលបានបង្ហាញក្នុងសម័យបច្ចុប្បន្ន។

ក្នុងបរិបទនេះ និងការប្រើប្រាស់នៅគ្រប់ទីកន្លែងកាន់តែច្រើនឡើងរបស់ពាក្យនេះ តើការទប់ទល់ គឺជាការពិពណ៌នាមានសុពលភាពចំពោះគោលនយោបាយការបរទេសសហរដ្ឋអាម៉េរិកឆ្ពោះទៅរកចិននិយាយជារួមឬជាគោលនយោបាយឥណ្ឌូប៉ាស៊ីហ្វិកនិយាយដោយឡែកដែរឬទេ? ចម្លើយគឺសាមញ្ញ៖ អត់ទេ។ ស្ថិតក្រោមរដ្ឋបាលលោកត្រាំពីមុននិងរដ្ឋបាលលោកបៃដិនបច្ចុប្បន្ន រដ្ឋាភិបាលទីក្រុងវ៉ាស៊ីនតោនតែងតែសំដៅទៅចិនជា «ដៃគូប្រជែងយុទ្ធសាស្ត្រ»[6] ហើយទំនាក់ទំនងជាប្រភេទមួយនៃ «ការប្រកួតប្រជែងជាយុទ្ធសាស្ត្រ»។ ទោះបីយ៉ាងណាក៏ដោយ គេគួរទទួលស្គាល់ថា ការជជែកវែកញែកលើរឿងថាតើសហរដ្ឋអាម៉េរិកគួរផ្លាស់ប្តូរទៅកាន់គោលនយោបាយទប់ទល់ចិន កំពុងតែកើនឡើង។ ការណ៍ពិតដែលថាការជជែកវែកញែកនេះថែមទាំងកើតមាននៅក្នុងសហគមន៍គោលនយោបាយសហរដ្ឋអាម៉េរិក គឺជាភស្តុតាងដ៏រឹងមាំគួរឱ្យកត់សម្គាល់ ដែលកំណត់ក្របខណ្ឌគោលនយោបាយសហរដ្ឋអាម៉េរិកបច្ចុប្បន្នឆ្ពោះទៅរកចិន គឺជាគោលនយោបាយទប់ទល់ និងគឺជាលំហាត់មួយដែលយករទេះអូសសេះ ។[7]

ដើម្បីយល់អត្ថន័យឱ្យបានពេញលេញនូវមូលហេតុអ្វីដែលពាក្យ «ការទប់ទល់» គឺជាបញ្ញត្តិកម្មដែលមានកំហុស និងជាពាក្យដែលត្រូវបោះបង់ចោល វាជារឿងមានប្រយោជន៍ណាស់ដែលត្រូវសិក្សាស៊ីជម្រៅទៅក្នុងការបង្កើតនិងការប្រើប្រាស់ពាក្យនេះជាប្រវត្តិសាស្ត្រក្នុងសម័យសង្គ្រាមត្រជាក់។

ប្រសិនបើនរណាម្នាក់យល់ស្របថា សហរដ្ឋអាម៉េរិកនិងចិនជាប់ពាក់ព័ន្ធក្នុង «សង្គ្រាមត្រជាក់ថ្មី» មួយ ពោលគឺវាជាជម្លោះមួយដែលបង្កឱ្យមានមហន្តរាយយ៉ាងខ្លាំងពេលថ្មីៗនេះ នៅក្នុងការវិភាគគ្រប់ចំណុចដោយអតីតឧបការីរងរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាម៉េរិកសម្រាប់កិច្ចការតំបន់អាស៊ីបូព៌ានិងប៉ាស៊ីហ្វិក លោក Thomas J. Christensen នៅក្នុងទស្សនាវដ្តី កិច្ចការបរទេស[8] ពាក្យដែលបានប្រើសព្វថ្ងៃនៅក្នុងបរិបទភូមិសាស្ត្រនយោបាយផ្សេងៗ គ្នាជាច្រើននោះ គឺមិនអាចប្រើការបានទេ។ ខ្ញុំសូមនិយាយវែងឆ្ងាយដើម្បីជជែកតវ៉ាថា ចំពោះពេលអវត្តមានសង្គ្រាមត្រជាក់ថ្មីមួយ ដែលជាចំណុចមួយខ្ញុំយល់ស្របទាំងស្រុងជាមួយការវិភាគរបស់លោក Christensen ការប្រើពាក្យការទប់ទល់ជាបញ្ញត្តិមួយឬទម្រង់ពាក្យមួយពិតដែលនៅជាបញ្ហាចម្រូងចម្រាស់យ៉ាងជ្រាលជ្រៅនោះឡើយ។

ដោយបានគូសបញ្ជាក់ដំបូងនៅក្នុង «តេឡេក្រាមដ៏វែង» យ៉ាងល្បីល្បាញរបស់លោក George Kenna ដែលបានផ្ញើពីស្ថានទូតអាម៉េរិកក្នុងទីក្រុងមូស្គូនៅឆ្នាំ១៩៤៦ ការទប់ទល់បានក្លាយជាផ្នែកមួយនៃលទ្ធិទ្រូម៉ាន់ (Truman Doctrine) ក្នុងឆ្នាំ១៩៤៧ ដែលសហរដ្ឋអាម៉េរិកគាំទ្ររដ្ឋាភិបាលប្រជាធិបតេយ្យណាមួយ (តាមរយៈមធ្យោបាយយោធា សេដ្ឋកិច្ច និងនយោបាយផ្សេងៗ) ប្រឆាំងនឹងការគំរាមកំហែងពីខាងក្រៅឬខាងក្នុងនៃកងកម្លាំងផ្តាច់ការ ដែលគេយល់ជាទូទៅថា សហភាពសូវៀត។ ការទប់ទល់និងលទ្ធិទ្រូម៉ាន់ គឺពាក់ព័ន្ធគ្នាមិនអាចបំបែកបាន ពោលគឺការប្រើប្រាស់ពាក្យទីមួយដោយគ្មានការយល់គ្រប់គ្រាន់អំពីន័យនៃពាក្យទីពីរ គឺមានបញ្ហា (ដោយសារតែការដាក់កម្រិតនៃលំហ ការពិភាក្សាអំពីឯកសារក្រុមប្រឹក្សាសន្តិសុខជាតិ NSC-៦៨ ដែលជាសេចក្តីថ្លែងការណ៍បន្ថែម ដ៏សំខាន់មួយស្តីអំពីគោលនយោបាយទប់ទល់របស់សហរដ្ឋអាម៉េរិក ដែលមិនបានបញ្ចូលត្រង់នេះទេ)។

3. Associated Press, April 9, 2021, https://www.dailysabah.com/business/tech/china-criticizes-us-sanctions-expanding-to-cover-computer-makers.

4. A sampling of the use of the terms “contain” and “containment” includes: Liu Yangyang. “中美经贸摩擦的根子在美国对华遏制政策,” in the CCP theoretical journal Qiushi, May 21, 2019, http://www.qstheory.cn/llwx/2019-05/21/c_1124522098.htm. Dong Lei and Jiang Tao, in their piece “中国人民的态度, 美国政客能看懂吗?” from April 30, 2021 at Sina.com went far as to state: “首先, 这次民调结果真实表达了当前中国民众对美国的不满。从特朗普任内开始, 美国转变对华政策, 奉行对中国的全面遏制, 从外交、经济、科技和意识形态等领域不断出台各种打压行径, 并且一再干涉中国内政, 一心想要阻止中国的崛起.”

5. Wang Zheng, Never Forget National Humiliation: Historical Memory in Chinese Politics and Foreign Relations, (New York: Columbia University Press, 2012).

6. Jen Psaki, White House Press Briefing, April 9, 2021: https://www.whitehouse.gov/briefing-room/press-briefings/2021/04/09/press-briefing-by-press-secretary-jen-psaki-and-secretary-of-transportation-pete-buttigieg-april-9-2021/.

7. Hal Brands, “Why Containment Can Stop the China Threat,”and Jacob Heilbrunn “Does America Really Need to Contain China?” in The National Interest provide just two examples of this ongoing debate.

8. Thomas J. Christensen, “There Will Not Be a New Cold War: The Limits of U.S.-Chinese Competition,” Foreign Affairs, March 24, 2021, https://www.foreignaffairs.com/articles/united-states/2021-03-24/there-will-not-be-new-cold-war.


© Creative Commons

លោក George Kennan គឺជានិម្មាបនករដ៏សំខាន់ក្នុងការបញ្ចូលការទប់ទល់ទៅក្នុងលទ្ធិទ្រូម៉ាន់។

ភាពខុសប្លែករវាងការវិភាគរបស់ Kennan អំពីសហភាពសូវៀត និងចិនសម័យបច្ចុប្បន្ន ចាំបាច់ត្រូវកត់សម្គាល់នៅទីនេះ។ លោក Kennan បានរំពឹងទុកថា ចុងក្រោយ ប្រព័ន្ធសូវៀត នឹងដួលរលំក្រោមទម្ងន់នៃភាពក្មេងខ្ចីផ្នែកនយោបាយរបស់ខ្លួនផ្ទាល់ ដែលការសម្រេចបានការដួលរលំផ្ទៃក្នុងរបស់ប្រព័ន្ធសូវៀត គឺជាយុត្តិកម្មចុងក្រោយចំពោះការទប់ទល់រួមជាមួយនឹងលទ្ធិវាទទីនិយមរបស់សូវៀត។ ថ្វីបើការសម្រេចចិត្តរបស់លោក ស៊ី ជិនពីង បោះបង់ចោលប្រព័ន្ធដឹកនាំសមូហភាព និងគំរូផ្លាស់ប្ដូរការដឹកនាំដោយទៀងទាត់ដែលបានបង្កើតឡើងយ៉ាងឈ្លាសវៃដោយលោក តេង ស៊ាវពីង គ្មាននរណាម្នាក់កំពុងពិនិត្យឱ្យបានម៉ត់ចត់ពីការដួលរលំរបស់ចិនក្នុងអនាគតដែលមិនអាចទស្សន៍ទាយបាន ហើយវានឹងឃ្លាតឆ្ងាយយ៉ាងខ្លាំងផុតពីការគិតសមហេតុផលនិងភស្តុតាងដើម្បីអះអាងថាសហរដ្ឋអាម៉េរិកមានសមត្ថភាពក្នុងការធ្វើបែបនេះ។ ដោយសារហេតុនេះ ការទប់ទល់ដែលជាគោលនយោបាយមួយនោះ គឺឥតប្រយោជន៍ ដោយសារកម្មវត្ថុដំបូងគឺមិនអាចធ្វើទៅបាន។

អតីតរដ្ឋមន្ត្រីការបរទេស លោក Henry Kissinger ខ្លួនគាត់ផ្ទាល់ បានថ្លែងនាពេលថ្មីៗពីភាពខុសប្លែកគ្នារវាងសាធារណរដ្ឋសង្គមនិយមសហភាពសូវៀត (USSR) និងចិនដោយមានប្រសាសន៍ថា៖ «សហភាពសូវៀតមិនមានសមត្ថភាពខាងសេដ្ឋកិច្ចទេ។ សហភាពសូវៀតមានសមត្ថភាពខាងបច្ចេកវិទ្យាយោធា...សហភាពសូវៀតមិនមានសមត្ថភាពខាងបច្ចេកវិទ្យានិងអភិវឌ្ឍដូចចិន។ ចិនគឺជាមហាអំណាចខាងសេដ្ឋកិច្ចដ៏ធំមួយបន្ថែមពីលើមហាអំណាចខាងយោធាដ៏ខ្លាំងក្លានោះ»។[9]

ក្រោយមកទៀត លោក Kissinger បានពិភាក្សាពីការទប់ទល់ដោយបាននិយាយ ថា៖ «លទ្ធិទ្រូម៉ាន់ បានកត់សម្គាល់នូវចំណុចផ្លាស់ប្ដូរមួយដោយសារនៅពេលអាម៉េរិកបានបបួលធ្វើសង្គ្រាមលោកស្តាលីន ដែលជាប្រភេទមនុស្សប្រាកដនិយម បានយល់យ៉ាងច្បាស់ថា វានឹងក្លាយជាទីបញ្ចប់រហូត ហើយការចរចាលើសម្បទានទៅវិញទៅមកក៏នឹងមិនអាចទៅរួចដែរ។ ពេលនោះហើយ ជម្លោះអាចដោះស្រាយបានដោយការផ្លាស់ប្ដូរគោលបំណងរបស់សូវៀតដោយការដួលរលំប្រព័ន្ធសូវៀតឬទាំងពីរ»។[10] សូម្បីតែចំពោះអ្នកវិភាគដែលមានការសង្ស័យច្រើនបំផុតក៏ដោយ ក៏យល់ច្បាស់ថា គោលនយោបាយសហរដ្ឋអាម៉េរិក និងទស្សនៈរបស់រដ្ឋាភិបាលវ៉ាស៊ីនតោនចំពោះចិន វិធីសាស្ត្ររបស់រដ្ឋាភិបាលនិងទំនាក់ទំនងចិន-អាម៉េរិក ជាទូទៅ មិនបានឈានដល់ចំណុចនោះទេ សូម្បីតែកម្រិតតិចតួច។

ព្រមពេលជាមួយគ្នានេះដែរ លោក Kennan បានកត់សម្គាល់ពីសារៈសំខាន់នៃការទទួលស្គាល់ពីគោលដៅរបស់សូវៀតក្នុងការនាំចេញប្រព័ន្ធរបស់ខ្លួន។ ថ្វីបើមានទំនោរបែបសេរីធីនិយមជ្រាលជ្រៅឆ្ពោះទៅរកប្រព័ន្ធសកលលោក ក៏ចិនពិតជាមិនមែនរដ្ឋនាំសារតាមលំនាំសូវៀតដែលប៉ុនប៉ងនាំចេញនូវលទ្ធិផ្ដាច់ការនិយមបែបថ្មីរបស់ខ្លួន ហើយកំពុងមានការព្រួយបារម្ភកាន់តែខ្លាំងអំពីជាតិនិយមបែបជាតិពន្ធ (ethno-nationalism) ដូច្នេះ គេមិនអាចប្រដូចចិនទៅនឹងអតីតសហភាពសូវៀតនោះទេ។ លើសពីនេះទៀត ថ្វីបើមានគំរូនៃការអភិវឌ្ឍសេដ្ឋកិច្ចហៅថា «គំរូប្រទេសចិន» ដែលធ្លាប់បានកោតសរសើរពីមុនក៏ដោយ ក៏ប៉េកាំងមិនបានបង្ហាញនូវជម្រើសដាច់ខាតចំពោះរបបមូលធននិយមទីផ្សារសកល ដែលបានទាញមនុស្សរាប់រយលាននាក់ចេញពីភាពក្រីក្រចាប់តាំងពីការចាប់ផ្ដើមសម័យប្រើប្រព័ន្ធគ្រួតពិនិត្យតម្លៃលុយ Bretton Woods នៅចុងទសវត្សរ៍ឆ្នាំ១៩៤០។

ដោយគិតពីចំណុចទាំងនេះជារួម ការប្រើពាក្យការទប់ទល់ជាបញ្ញត្តិមួយដែលពិពណ៌នាពីគោលនយោបាយអាម៉េរិកឆ្ពោះទៅរកចិន គឺមិនត្រឹមត្រូវទេ។ ប៉ុន្តែ រឿងនេះក៏ប្រហែលលើកឡើងនូវចំណុចសំខាន់មួយផងដែរ។ សង្គ្រាមត្រជាក់បានបញ្ចប់៣០ឆ្នាំកន្លងផុតទៅហើយ ហើយពិភពលោកបានផ្លាស់ប្ដូរយ៉ាងខ្លាំងតាំងពីពេលនោះមក។ ជាទស្សនៈរបស់អ្នកនិពន្ធ វាដល់ពេលត្រូវអភិវឌ្ឍវាក្យសព្ទដែលច្បាស់លាស់ ទាន់ពេលវេលា និងពាក់ព័ន្ធច្រើនជាងមុនក្នុងអ្វីដែលត្រូវពិភាក្សាពីភូមិសាស្ត្រនយោបាយសម័យបច្ចុប្បន្ននិយាយជារួម និងយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកនិយាយដោយឡែក។៕

9. Henry Kissinger, quoted in "Kissinger warns of 'colossal' dangers in US-China tensions," Agence France Presse, April 20, 2021, https://www.france24.com/en/live-news/20210430-kissinger-warns-of-colossal-dangers-in-us-china-tensions.

10. Henry Kissinger, "Reflections on Containment," Foreign Affairs, 73, no. 3 (1994):118.




លោក Yang Jiechi នាយកការិយាល័យគណៈកម្មាធិការមជ្ឈិមការបរទេសប្រទេសចិន និងលោក Wang Yi សមាជិកក្រុមប្រឹក្សារដ្ឋនិងជារដ្ឋមន្ត្រីការបរទេសចិន បានអញ្ជើញមកដល់កិច្ចប្រជុំមួយក្នុងទីក្រុង Anchorage រដ្ឋអាឡាស្កា កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១។

# ៤. យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ៖ លក្ខណៈ និងអនាគត - ទស្សនវិស័យចិន



**Zhang Zijie**

បច្ចុប្បន្នលោក Zijie Zhang បម្រើការជាជំនួយការស្រាវជ្រាវ នៅសកលវិទ្យាល័យសិក្សាការបរទេស Tianjin។

យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ (FOIP) គឺជាកេរដំណែលមួយរបស់រដ្ឋបាលលោកត្រាំនៅក្នុងការប៉ុនប៉ងរារាំងការរះឡើងរបស់ចិន និងអានុភាពរបស់សហគមន៍យុទ្ធសាស្ត្ររបស់ចិន ដែលគេជឿថា រដ្ឋបាលលោកបៃដិននឹងទទួលយកមរតកយុទ្ធសាស្ត្រនេះក្នុងលក្ខណៈមួយ និងពង្រីកវាថែមទៀត។

## ប្រវត្តិរបស់ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ (FOIP)

ចាប់តាំងពីការបញ្ចប់សង្គ្រាមលោកលើកទី២ សហរដ្ឋអាម៉េរិកបានធ្វើជានិម្មាបនករនិងជាអ្នកដឹកនាំនៃសណ្ដាប់ធ្នាប់តំបន់ប៉ាស៊ីហ្វិកខាងលិច។ អំឡុងសង្គ្រាមត្រជាក់ សហរដ្ឋអាម៉េរិកបានបង្កើតប្រព័ន្ធនិម្មាបនកម្មសម្ព័ន្ធភាពក្នុងអាស៊ីខាងកើត (Hub-and-spoke system) ដែលជាសម្ព័ន្ធទ្វេភាគីមួយ ដើម្បីរារាំងការរីកសាយភាយនៃលទ្ធិកុម្មុយនីស្តនៅក្នុងតំបន់។ ទោះបីយ៉ាងណាក៏ដោយ ក៏អំណាចរបស់សហរដ្ឋអាម៉េរិកបានជាប់គាំងយ៉ាងខ្លាំងដោយសារវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៨ ដែលបានកាត់បន្ថយសមត្ថភាពរបស់សហរដ្ឋអាម៉េរិកដើម្បីកំណត់សណ្ដាប់ធ្នាប់តំបន់។ ខណៈពេលនោះដែរ ចិននិងឥណ្ឌាបានអាចទប់ទល់បានជាមួយវិបត្តិនេះ និងបានជួបនឹងកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ ដែលបានផ្ដល់ឱ្យប្រទេសទាំងពីរនូវការបញ្ចេញសម្ដីបានច្រើនលើសណ្ដាប់ធ្នាប់តំបន់។




USS Abraham Lincoln (CVN72) ដែលនាវាដឹកយន្តហោះ ដើរដោយថាមពលនុយក្លេអ៊ែរប្រភេទ Nimit និង USS Kearsarge (LHD 3) ដែលជានាវាចម្បាំងដែលអាចវាយប្រហារបានទាំងក្នុងទឹកនិងលើគោកប្រភេទឱម៉ាល់ បានបើកទន្ទឹមគ្នា នៅពេលក្រុមវាយប្រហារតាមនាវាដឹកយន្តហោះ Abraham Lincoln (ABECSG) និងក្រុមត្រៀមវាយប្រហារទាំងក្នុងទឹកនិងលើគោក Kearsarge (KSGARG) បានធ្វើប្រតិបត្តិការរួមគ្នានៅក្នុងតំបន់ប្រតិបត្តិការរបស់កងនាវាទី៥របស់សហរដ្ឋអាម៉េរិក ក្នុងសមុទ្រអារ៉ាប់ កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៩។

ជាពិសេស ឥទ្ធិពលផ្នែកសេដ្ឋកិច្ចដែលបានបង្ហាញដោយសំណើរបស់ទីក្រុងប៉េកាំងស្ដីអំពី គំនិតផ្ដួចផ្ដើមខ្សែក្រវាត់និងផ្លូវ (BRI) រួមផ្សំនឹងឥទ្ធិពលផ្នែកសន្តិសុខដែលបានបង្ហាញក្នុងការពារសិទ្ធិរបស់ចិននៅក្នុងសមុទ្រចិនខាងកើតនិងខាងត្បូង បានអង្រួនដល់ការត្រួតត្រារបស់សហរដ្ឋអាម៉េរិកនៅក្នុងតំបន់ប៉ាស៊ីហ្វិកខាងលិច ដែលបង្កការសង្ស័យចំពោះគោលបំណងរបស់ចិនចំពោះសហរដ្ឋអាម៉េរិក ជប៉ុន អូស្ត្រាលី និងប្រទេសផ្សេងៗទៀត។

តាមទស្សនវិស័យរបស់ប្រទេសទាំងនេះ ការទាមទារដែនដីរបស់ចិននៅក្នុងសមុទ្រចិនខាងត្បូងនិងខាងកើត ដោយមានមូលដ្ឋានជាច្រើនបានរៀបចំឡើងតាមរយៈកម្មវិធីហេដ្ឋារចនាសម្ព័ន្ធតាមបណ្ដោយដីគោកនិងច្រករបៀងសមុទ្រនៃគំនិតផ្ដួចផ្ដើមខ្សែក្រវាត់និងផ្លូវនោះ បានលាតត្រដាងពីមហិច្ឆតារបស់ចិនដើម្បីជំនួសកន្លែងនៃការត្រួតត្រារបស់សហរដ្ឋអាម៉េរិក ពង្រីកគំរូសេដ្ឋកិច្ចរបស់ខ្លួន និងរៀបចំសណ្ដាប់ធ្នាប់តំបន់ឡើងវិញ។

ជាមួយនឹងកំណើនសេដ្ឋកិច្ចរបស់ខ្លួន ឥណ្ឌាក៏បានបង្ហាញពីចំណាប់អារម្មណ៍នៅក្នុងកិច្ចការតំបន់ផងដែរ ប៉ុន្តែផ្ទុយពីចិន ការរះឡើងរបស់ឥណ្ឌា ជាទូទៅ គេមើលឃើញថា មានលក្ខណៈសន្តិភាព និងមិនគ្រោះថ្នាក់។

ការវិវត្តនៃគោលនយោបាយ «សម្លឹងទៅខាងកើត» ទៅជាគោល-នយោបាយ «ធ្វើសកម្មភាពនៅខាងកើត» របស់ឥណ្ឌា ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ដោយរដ្ឋបាលលោក ម៉ូឌី បង្ហាញពីការប្តេជ្ញាចិត្តរបស់ឥណ្ឌាដើម្បីធ្វើសមាហរណកម្មខ្លួនឯងបន្ថែមទៀតទៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ជាដៃគូស្មើមុខស្មើមាត់ចំពោះតួអង្គផ្សេងទៀតនៅក្នុងនិម្មាបនកម្មសន្តិសុខតំបន់នេះ។ រដ្ឋាភិបាលទីក្រុងញូវដេលីគឺមានគុណតម្លៃជាយុទ្ធសាស្ត្រដ៏អស្ចារ្យចំពោះសហរដ្ឋអាម៉េរិក ប្រសិនបើទំនាក់ទំនងរបស់ខ្លួនជាមួយរដ្ឋាភិបាលប៉េកាំងបានប្រែក្លាយជារកាំរកូសបន្ទាប់ពីមានជម្លោះព្រំដែនជាច្រើននិងការផ្ទុះជំងឺកូវីដ១៩នោះ។

ជាទូទៅ ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ គឺជាការឆ្លុះបញ្ចាំងមួយពីការផ្លាស់ប្តូរអំណាចនៅក្នុងតំបន់ដូចដែលនិយាយពីខាងដើម។ គោលនយោបាយនេះមើលប្រទេសចិនថាជាដៃគូប្រជែងចម្បងនៃសណ្តាប់ធ្នាប់តំបន់ដែលមានស្រាប់ ដែលបង្កើតឡើងដោយសហរដ្ឋអាម៉េរិក។ ទោះបីយ៉ាងណាក៏ដោយ ប្រសិនការធ្លាក់ចុះអំណាចសេដ្ឋកិច្ចរបស់ខ្លួនតាមលក្ខណៈប្រៀបធៀបនោះ សហរដ្ឋអាម៉េរិកមានសមត្ថភាពតិចក្នុងការប្រឈមមុខជាមួយចិនដោយខ្លួនឯងផ្ទាល់។

ដូច្នេះ ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ ទាញយកប្រយោជន៍ពីកម្លាំងរបស់ជប៉ុន អូស្ត្រាលី និងឥណ្ឌា ដើម្បីរក្សាតុល្យភាពអំណាចរបស់ចិន ហើយអាម៉េរិកព្យាយាមធ្វើឱ្យជឿនលឿនឡើងនូវប្រព័ន្ធនិម្មាបនកម្មសម្ព័ន្ធភាពក្នុងអាស៊ីខាងកើតទៅជាទម្រង់ពហុភាគីមួយ។ លើសពីនេះទៀត ជាមួយនឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាទំព្រស្រួចមួយនោះ ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហក៏ប៉ុនប៉ងទាក់ទាញដៃគូឱ្យបានច្រើន ជាពិសេសប្រទេសតំបន់អាស៊ានចូលទៅក្នុងបណ្តាញអន្តរតំបន់នេះ។

## សមាសភាគនៃឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ

ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ គឺជាគំនិតផ្តួចផ្តើមទ្វេបំណងមួយដែលចង្អុលផ្លូវសាខាសន្តិសុខអំណាចរឹងនិងសាខាអភិវឌ្ឍន៍អំណាចស្រទន់មួយ ដែលសាខាទាំងពីរបានគូសបញ្ជាក់នៅក្នុងកិច្ចសន្ទនាសន្តិសុខចតុភាគី (Quad) ដែលជាយន្តការពហុភាគីមួយរួម។

ការចាប់ផ្តើមនៃសហប្រតិបត្តិការកិច្ចសន្ទនាចតុភាគីនេះ អាចតាមដានត្រឡប់ទៅដល់កិច្ចសហប្រតិបត្តិការជំនួយគ្រោះមហន្តរាយក្នុងចំណោមសហរដ្ឋអាម៉េរិក ជប៉ុន ឥណ្ឌា និងអូស្ត្រាលី បន្ទាប់ពី រលកយក្សស៊ូណាមីក្នុងមហាសមុទ្រឥណ្ឌានៅឆ្នាំ២០០៤។ ក្រោយមកទៀត កិច្ចសហប្រតិបត្តិការចតុភាគីបានស្ងាត់ស្ងៀមដោយសារតែការផ្លាស់ប្តូរនយោបាយក្នុងស្រុករបស់អូស្ត្រាលី ជប៉ុន និងឥណ្ឌា។ រហូតដល់ឆ្នាំ២០១៧ នៅពេលរដ្ឋបាលលោកត្រាំបានបោះបង់ចោល «យុទ្ធសាស្ត្រជុំវិញទ្វីបអាស៊ី» របស់រដ្ឋបាលមុន ទើបក្រុមចតុភាគីបានរះឡើងវិញ។ បច្ចុប្បន្ន កិច្ចសន្ទនា ចតុភាគី ដើរតួនាទី ជាវេទិកាមុខងារចម្បងសម្រាប់ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ។

ទង់ជាតិរបស់សហរដ្ឋអាម៉េរិក ជប៉ុន ឥណ្ឌា និងអូស្ត្រាលី (Quad) ជាក្រុមមួយ

កិច្ចសន្ទនាចតុភាគីកំណត់អត្តសញ្ញាណតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ថាជាតំបន់ភូមិសាស្ត្រមួយរបស់ក្រុមខ្លួននិងមានបំណងក្នុងការបង្កើតសណ្តាប់ធ្នាប់តំបន់ដែលផ្អែកលើច្បាប់ ព្រមទាំងសេរីនិងបើកចំហ។ ថ្វីបើការពិតដែលសមាជិកកិច្ចសន្ទនាចតុភាគីមិនទាន់បានសម្រេចនូវកិច្ចព្រមព្រៀងដែលបានចងក្រងណាមួយក៏ដោយ ក៏សារៈសំខាន់របស់ក្រុមនេះដែលជាយន្តការពហុភាគី ត្រូវបានទទួលស្គាល់ដោយសមាជិកទាំងបួនរបស់ក្រុម។

រឿងនេះមានបង្ហាញយ៉ាងច្បាស់ដោយការកើនឡើងជាបន្តបន្ទាប់នៅក្នុងជួរគណៈប្រតិភូពីបុគ្គលិកយោធាឬការទូតជាន់ខ្ពស់រហូតដល់រដ្ឋមន្ត្រីការបរទេស និងមានរហូតដល់មេដឹកនាំសំខាន់ៗរបស់ប្រទេសទាំងបួន។ ស្ថិតនៅក្រោមក្របខណ្ឌចតុភាគី ប្រទេសទាំងបួនក៏បានបង្កើតសំណុំកិច្ចសន្ទនាត្រីភាគីផងដែរ ដែលមានបំណងចងក្រងយន្តការក្រុមចតុភាគីបន្ថែមទៀត។

គួរកត់សម្គាល់ថា កិច្ចសន្ទនាចតុភាគីបើកចំហសម្រាប់ការពង្រីកពេលអនាគត ហើយប្រទេសនានា ដូចជា កាណាដា បារាំង ចក្រភពអង់គ្លេស និងនូវ៉ែលសេឡង់ គឺស្ថិតនៅក្នុងបញ្ជីរង់ចាំ។ ដូចលោក Michael Pompeo ដែលជារដ្ឋមន្ត្រីការបរទេសសហរដ្ឋអាម៉េរិកនាពេលនោះបានផ្តល់យោបល់ថា កិច្ចសន្ទនាចតុភាគីមានបំណងអភិវឌ្ឍទៅជាក្របខណ្ឌសន្តិសុខតំបន់ជាលក្ខណៈធម្មតានិងជាលក្ខណៈស្ថាប័នមួយដោយផ្តោតលើ «ពហុភាគីនិយមផ្តោតលើលទ្ធផល»។ ក្នុងការអនុវត្តជាក់ស្តែង សមាជិកកិច្ចសន្ទនាចតុភាគីបានធ្វើកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិជាប្រចាំតាមរយៈការធ្វើសមយុទ្ធកងនាវា និងការចែករំលែកការស៊ើបការនិងភស្តុភារយោធា។ ជាឧទាហរណ៍ សមយុទ្ធកងនាវាត្រីភាគី ឥណ្ឌា-សហរដ្ឋអាម៉េរិក-ជប៉ុន ដែលហៅថា Malabar ក៏បានបញ្ចូលអូស្ត្រាលីដែរកាលពីឆ្នាំមុន។

បន្ថែមពីលើបញ្ហាពាក់ព័ន្ធនឹងសន្តិសុខ កិច្ចសន្ទនា ចតុភាគីក៏បានឈានចូលទៅរកវិស័យសេដ្ឋកិច្ចផងដែរ។ នៅក្នុងប៉ុន្មានឆ្នាំដំបូង ក្រុមនេះបានទទួលផ្លែផ្កាតិចតួចពាក់ព័ន្ធនឹងរឿងនេះ លើកលែងតែសេចក្តីថ្លែងការណ៍ជាគោលការណ៍បន្តិចបន្តួចដែលបញ្ជាក់សាជាថ្មីពីហានិភ័យនៃទម្រង់តម្រង់ រដ្ឋាភិបាលដែលឧបត្ថម្ភដោយចិនដើម្បីនាំប្រទេសម្ចាស់ផ្ទះចូលអន្ទាក់បំណុលអធិបតេយ្យភាព។ ផ្ទុយទៅវិញកិច្ចសន្ទនា ចតុភាគីបានប្តេជ្ញាចិត្តចំពោះគំរូដែលជាជម្រើសមួយមានស្តង់ដារនិងគុណភាពខ្ពស់ អភិបាលកិច្ចល្អ តម្លាភាព និងមិត្តភាពឆ្ពោះទៅវិស័យឯកជន។

អស់រយៈពេលយូរមកហើយ ការពិភាក្សារបស់កិច្ចសន្ទនា ចតុភាគីបានប្រែក្លាយកាន់តែមានមូលដ្ឋានច្បាស់លាស់និងមានគោលដៅ។ អំឡុងពេលកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ២០១៩ សាជីវកម្មវិនិយោគឯកជនក្រៅប្រទេសរបស់សហរដ្ឋអាម៉េរិក ធនាគារជប៉ុនសម្រាប់

សាជីវកម្មអន្តរជាតិ និងក្រសួងការបរទេសនិងពាណិជ្ជកម្មរបស់អូស្ត្រាលី បានប្រកាសដាក់ដំណើរការកម្មវិធី «បណ្តាញចំណុចពណ៌ខៀវ (Blue Dot Network)» ក្នុងកិច្ចខំប្រឹងប្រែងមួយដើម្បីបង្កើតប្រព័ន្ធវាយតម្លៃនិងការចេញវិញ្ញាបនបត្រដែលទទួលស្គាល់ជាសកលសម្រាប់ការវិនិយោគនានានៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។

នៅក្នុងកិច្ចប្រជុំតាមវីដេអូថ្មីបំផុតរបស់ខ្លួន មេដឹកនាំកិច្ចសន្ទនាចតុភាគី (Quad) បានពិភាក្សាពីលទ្ធភាពនៃការបង្វែរច្រវាក់ផ្គត់ផ្គង់ចេញពីប្រទេសចិន ដោយមានឥណ្ឌាជាមជ្ឈមណ្ឌលផលិតកម្មថ្មី។ កិច្ចខំប្រឹងប្រែងទាំងអស់នេះមានបំណងដើម្បីកាត់បន្ថយសមត្ថភាពរបស់ចិនក្នុងការ ដណ្តើមការត្រួតត្រា មិនត្រឹមតែភូមិសាស្ត្រនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបច្ចេកវិទ្យាទៀតផង។

ក្រៅពីយន្តការកិច្ចសន្ទនាចតុភាគី រដ្ឋាភិបាលសហរដ្ឋអាម៉េរិកក៏បានគាំទ្រគំនិតផ្តួចផ្តើមខាងយោធានិងសេដ្ឋកិច្ចជាច្រើនផងដែរដោយខ្លួនឯងផ្ទាល់។ កាលពីខែកក្កដា ឆ្នាំ២០១៨ លោក Pompeo បានប្រកាសគម្រោងមួយតម្លៃ ១១៣លានដុល្លារ ដើម្បីគាំទ្រសេដ្ឋកិច្ចឌីជីថល ថាមពល និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់ដែលជានិមិត្តរូបនៃការកក់លុយមួយចំពោះការប្តេជ្ញាចិត្តរបស់សហរដ្ឋអាម៉េរិកចំពោះវិបុលភាពរបស់ឥណ្ឌូប៉ាស៊ីហ្វិកនោះ។ នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៨ សភាសហរដ្ឋអាម៉េរិកបានអនុម័តច្បាប់ការប្រើប្រាស់ឱ្យល្អប្រសើរនៃការវិនិយោគនាំទៅរកការអភិវឌ្ឍដោយទទួលបានសំឡេងភាគច្រើនពីគណបក្សទាំងពីរ។

ច្បាប់នេះបង្កើតសាជីវកម្មហិរញ្ញវត្ថុអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋ-អាម៉េរិក ជាធនាគារអភិវឌ្ឍន៍មួយដែលជួយឱ្យសហរដ្ឋអាម៉េរិកចូលរួមកាន់តែប្រសើរឡើងជាមួយស្ថាប័នហិរញ្ញវត្ថុរបស់សមាជិកកិច្ចសន្ទនាចតុភាគី និងការវិនិយោគដោយផ្ទាល់ពីក្រៅប្រទេសដើម្បីផ្តល់មូលនិធិដល់គម្រោងអភិវឌ្ឍន៍ឯកជនក្រៅប្រទេសជាពិសេសប្រទេសក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។

ទាក់ទិននឹងជួរមុខផ្នែកយោធាវិញ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ទីបញ្ជាការតំបន់ ប៉ាស៊ីហ្វិករបស់សហរដ្ឋអាម៉េរិក ដែលជាទីបញ្ជាការកងប្រយុទ្ធដ៏ធំជាងគេនិងចំណាស់ជាងគេរបស់កងកម្លាំងប្រដាប់អាវុធសហរដ្ឋអាម៉េរិក បានដូរឈ្មោះឡើងវិញជាទីបញ្ជាការឥណ្ឌូប៉ាស៊ីហ្វិកសហរដ្ឋអាម៉េរិក (USINDOPACOM) ។ ការដូរឈ្មោះ USINDOPACOM បានធ្វើឡើងក្នុងកិច្ចខំប្រឹងប្រែងមួយដើម្បីបញ្ចូលមហាសមុទ្រឥណ្ឌាចូលក្នុងតំបន់ប្រតិបត្តិការសហរដ្ឋអាម៉េរិក ដែលជាការទទួលស្គាល់ពីសារៈសំខាន់របស់សមុទ្រខាងត្បូង។ ក្រៅពីនេះទៀត កងនាវាសហរដ្ឋអាម៉េរិកបានបង្កើនការល្បាតរបស់ខ្លួននៅក្នុងច្រកសមុទ្រតៃវ៉ាន់និងដែនទឹកជម្លោះនៃសមុទ្រចិនខាងត្បូង ដើម្បីបង្ហាញពីការមិនព្រមព្រៀងរបស់ខ្លួនពាក់ព័ន្ធនឹងការទាមទារដែនដីរបស់ចិនលើសមុទ្រទាំងនោះ។

## ទស្សនវិស័យ ចិនស្តីពី ឥណ្ឌូប៉ាស៊ីហ្វិកសេរី និងបើកចំហ

នៅក្នុងក្រសែភ្នែករបស់មន្ត្រីនិងអ្នកប្រាជ្ញចិន ពួកគេយល់ថា ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហគឺជាការទប់ទល់អំណាចភូមិសាស្ត្រនយោបាយ សេដ្ឋកិច្ច និងបច្ចេកវិទ្យាដែលកាន់ខ្លាំងឡើងរបស់ចិន។ រដ្ឋមន្ត្រីការបរទេសចិន លោក Wang Yi បានបញ្ជាក់ថា ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ ត្រូវបានកំណត់ឡើងដើម្បីកសាង «ក្រុមណាតូថ្មីមួយ» ដែលបំផ្លាញដល់សន្តិភាពនិងវិបុលភាពក្នុងអាស៊ីបូព៌ា។ ទោះបីបែបនេះក៏ដោយ ក៏អ្នកប្រាជ្ញចិននៅតែសង្ស័យពីភាពអាចកើតឡើងបានរបស់ ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ ដើម្បីទប់ទល់នឹងចិន ដោយសារគុណវិបត្តិឬផ្នែកអវិជ្ជមានតាំងពីកំណើតរបស់វា។




រដ្ឋមន្ត្រីការបរទេសចិន Wang Yi ត្រូវបានទទួលការស្វាគមន៍ដោយប្រធានាធិបតីឡាវ Bounnhang Vorachith មុនកិច្ចប្រជុំបន្ទាន់ រវាងអាស៊ាននិងចិនស្តីពីវីរុសកូរ៉ូណា នៅប្រទេសឡាវ ក្នុងឆ្នាំ២០២០។




លក្ខណៈពិសេសមួយរបស់គោលនយោបាយការបរទេសចិនគឺគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវដែលពង្រីកលើតំបន់ឥណ្ឌូប៉ាស៊ីហ្វិកនិងផ្លូវសូត្រចាស់។

ទីមួយ មានការជំទាស់ជាច្រើននៅក្នុងកិច្ចសន្ទនាចតុភាគីអំពីអាទិភាពនានានិងគោលបំណងខ្ពស់បំផុតរបស់ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ។ ក្នុងនាមជាប្រទេសមួយមានមហិច្ឆតាជាសកលឥណ្ឌាសប្បាយចិត្តទាញយកប្រយោជន៍ពីការប្រកួតប្រជែងរវាងសហរដ្ឋអាម៉េរិកនិងចិន ដើម្បីអភិវឌ្ឍជំហររបស់ខ្លួនផ្ទាល់ឱ្យមានភាពជឿនលឿននៅក្នុងពិភពលោក ប៉ុន្តែឥណ្ឌានឹងមិនអាចយល់ស្របជាមួយសម្ព័ន្ធមួយរបស់គោលនយោបាយពីមុនទេ។ បច្ចុប្បន្ន រដ្ឋាភិបាលទីក្រុងញូវដេលី វាយតម្លៃយ៉ាងប្រុងប្រយ័ត្នអំពីឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហដោយផ្តើមចេញពីទស្សនវិស័យសេដ្ឋកិច្ច ដោយឥណ្ឌាគូសបញ្ជាក់ពីមជ្ឈភាពអាស៊ាននិងជៀសវាងការនិយាយអំពីគំនិតផ្តួចផ្តើមណាមួយដែលមានបង្កប់អត្ថន័យពាក់ព័ន្ធនឹងសម្ព័ន្ធយោធា។

ខាងភាគីជប៉ុនវិញ រដ្ឋាភិបាលទីក្រុងតូក្យូភ្ជាប់ក្តីសង្ឃឹមរបស់ខ្លួនលើឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ ដើម្បីពង្រឹងជំហររបស់ខ្លួននៅក្នុងទិដ្ឋភាពភូមិសាស្ត្រនយោបាយដែលមានស្រាប់។ ស្នូលនៃសនិទានភាពនៃគោលនយោបាយរបស់ខ្លួន គឺបន្ថយឥទ្ធិពលដែលកំពុងកើនឡើងរបស់ចិនក្រោមស្រមោលរបស់សហរដ្ឋអាម៉េរិក ខណៈនៅបន្តទាញប្រយោជន៍ពីកំណើនសេដ្ឋកិច្ចរបស់គោលនយោបាយពីមុន។ សម្រាប់អូស្ត្រាលីដែលជាអ្នកគាំទ្ររឹងមាំបំផុតរបស់សហរដ្ឋអាម៉េរិកនៅក្នុងតំបន់នោះ ការជាប់ពាក់ព័ន្ធរបស់អូស្ត្រាលីនៅក្នុងឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ ភាគច្រើនជំរុញដោយសារក្តីបារម្ភពីការដាក់នៅដាច់ពីគេឯងនៅក្នុងតំបន់និងលែងទាក់ទងជាមួយបស្ចិមប្រទេសនានាដែលមានចិត្តដូចគ្នា។

ទីពីរ ចិនរក្សាចំណងសេដ្ឋកិច្ចយ៉ាងសកម្មជាមួយសមាជិកកិច្ចសន្ទនាចតុភាគី (Quad) រដ្ឋា-  ភិបាលទីក្រុងប៉េកាំងនៅតែជាដៃគូពាណិជ្ជកម្មដ៏ធំជាងគេមួយក្នុងចំណោមដៃគូពាណិជ្ជកម្មធំជាងគេផ្សេងទៀតសម្រាប់ជប៉ុន ឥណ្ឌា និងអូស្ត្រាលី។ នេះជាហេតុផលចម្បងដែលបង្ហាញថា ហេតុអ្វីបានជា ប្រទេសទាំងនេះស្ទាក់ស្ទើរក្នុងការប្រឈមមុខជាមួយចិនក្រោមការឧបត្ថម្ភរបស់សហរដ្ឋអាម៉េរិកនោះ។ ប្រទេសទាំងនេះត្រូវគណនាថា តើការផ្គាប់ចិត្តសហរដ្ឋអាម៉េរិកពាក់ព័ន្ធនឹងចិននោះ នឹងបម្រើផលប្រយោជន៍ជាតិរបស់ប្រទេសពួកគេបានល្អប្រសើរជាងការចាត់ចែងជម្លោះរបស់ពួកគេជាមួយចិនដោយខ្លួនឯងផ្ទាល់ឬយ៉ាងណា។ ដោយសារហេតុនេះ កិច្ចសន្ទនាចតុភាគី (Quad) នៅតែមានទំនោរទៅរកបញ្ហាសន្តិសុខមិនមែនប្រពៃណីនានា ដូចជា បម្រែបម្រួលអាកាសធាតុ និងវ៉ាក់សាំងកូវីដ-១៩ ដោយមានគោលបំណងបន្ស៊ាបឥទ្ធិពលចិនក្នុងវិធីមួយដែលបង្កហេតុតិចជាង។




ទីបី ផ្នែកចំនួនពីរនៃឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ មិនមានតុល្យភាពទេ។ គំនិតផ្តួចផ្តើមខាងសេដ្ឋកិច្ចភាគច្រើនមិនមានធនធានគ្រប់គ្រាន់។ ដោយគ្មានអ្វីផ្សេងសោះក្រៅពីការកក់លុយចំនួន ១១៣លានដុល្លារ ដែលលោក Pompeo បានសន្យានោះ វាមានន័យតិចតួចណាស់ចំពោះតម្រូវការ ហេដ្ឋារចនាសម្ព័ន្ធដ៏ធំសម្បើមរបស់តំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ ចំនួនលុយកក់នេះកាន់តែស្តួចស្តើងបើប្រៀបធៀបជាមួយតម្លៃ បួនទ្រីលានដុល្លារក្នុងការវិនិយោគនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ (BRI) វិញ (ត្រឹមឆ្នាំ២០២០)។ ដូច្នេះវាមិនពិបាកយល់ទេថា ហេតុអ្វីបានជាប្រទេសផ្សេងៗទៀតខ្វះទំនុកចិត្តដែលថាសហរដ្ឋអាម៉េរិកមានឆន្ទៈនិងសមត្ថភាពដើម្បីរក្សាការគាំទ្ររបស់ខ្លួនចំពោះឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហនោះ។

ចំណុចចុងក្រោយ ឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ មានសក្តានុ-ពលបង្កើតឱ្យមានការបែកបាក់ជាថ្មីនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកជាពិសេស តំបន់អាស៊ីអាគ្នេយ៍។ ការអះអាងរបស់រដ្ឋបាលលោកត្រាំបានធ្វើឱ្យរង្គោះរង្គើភាពមិនច្បាស់លាស់ជាយុទ្ធសាស្ត្ររបស់អាស៊ានដោយដាក់សម្ពាធលើសមាជិករបស់ខ្លួនឱ្យជ្រើសរើសរវាងចិននិងសហរដ្ឋអាម៉េរិក។ លើសពីនេះទៀត ការលេចឡើងនៃកិច្ចសន្ទនាចតុភាគី (Quad) ក៏បានគំរាមកំហែងមជ្ឈភាពអាស៊ាន ដោយសារសមាជិករបស់ខ្លួនមានទីតាំងស្ថិតនៅខាងក្រៅអាស៊ីអាគ្នេយ៍ ដែលបានបង្កការសង្ស័យលើតួនាទីរបស់អាស៊ានជាអ្នកចរចាមួយរវាងមហាអំណាចនានានៅពេលអនាគត។

សរុបមក រដ្ឋាភិបាលនិងក្រុមអ្នកស្រាវជ្រាវចិនបានដឹងពីការធ្វើឱ្យខូចប្រយោជន៍និងហានិភ័យរបស់នៃឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហ មិនត្រឹមតែចំពោះគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងស្ថិរភាពតំបន់ទៀតផង។ ថ្វីបើកត្តាអវិជ្ជមានទាំងអស់នោះ បង្កឡើងដោយឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហក៏ដោយ ក៏ប្រទេសចិននឹងបន្តការទូតបែបសហប្រតិបត្តិការរបស់ខ្លួន និងស្វែងរកកិច្ចសហប្រតិបត្តិការជាមួយភាគីទាំងអស់រួមទាំងសហរដ្ឋអាម៉េរិក និងសម្ព័ន្ធមិត្តកិច្ចសន្ទនាចតុភាគី (Quad) របស់សហរដ្ឋអាម៉េរិក ដើម្បីកសាងសណ្តាប់ធ្នាប់ថ្មីមួយប្រកបដោយចីរភាព បរិយាបន្ន និងយុត្តិធម៌៕




នាយករដ្ឋមន្ត្រីអូស្ត្រាលី លោក Scott Morrison ជាមួយអតីតប្រធានាធិបតីសហរដ្ឋអាម៉េរិកលោក ដូណាល់ ត្រាំ ក្នុងដំណើរទស្សនកិច្ចទៅកាន់សហរដ្ឋអាម៉េរិក

# ៥. ការទូតបែបស្ពាននាក្នុងសម័យកាលនៃការប្រកួតប្រជែង : ទស្សនទានអូស្ត្រាលី




## សាស្ត្រាចារ្យ Caitlin Byrne

សាស្ត្រាចារ្យ Caitlin Byrne គឺជានាយិកាវិទ្យាស្ថាន Griffith Asia ជាអ្នកស្រាវជ្រាវរបស់វិទ្យាស្ថានអូស្ត្រាលីសម្រាប់កិច្ចការអន្តរជាតិ (AIIA) និងជាអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសម្រាប់ការទូតសាធារណៈ (CPD) នៅសកលវិទ្យាល័យ Southern California។

ឯកសារសនៃគោលនយោបាយការបរទេសអូស្ត្រាលីឆ្នាំ២០១៧ បានកំណត់អូស្ត្រាលីជា «មហាអំណាច តំបន់មួយគិតពីផលប្រយោជន៍សកលលោក»។[1] ក្នុងលក្ខណៈបែបមហិច្ឆតា ឯកសារសបានឆ្លុះបញ្ចាំងពីគោលបំណងបច្ចុប្បន្នរបស់អូស្ត្រាលីក្នុងការចូលខ្លួនយ៉ាងសកម្មក្នុងវិស័យសំខាន់ៗដូចជា ការទូត ការពារជាតិ ពាណិជ្ជកម្ម និងវប្បធម៌ នៅក្នុងតំបន់ជិតខាងឥណ្ឌូប៉ាស៊ីហ្វិក[2] និងកាន់តែធំទូលាយជាងនេះនៅលើពិភពលោក។




ប្រធានសភាតំណាងរាស្ត្រអូស្ត្រាលី លោកស្រី Bronwyn Bishop ចាប់ដៃជាមួយប្រធានាធិបតីចិន ស៊ី ជីនពីង បន្ទាប់ពីការថ្លែងសុន្ទរកថារបស់លោកនៅក្នុងសភាតំណាងរាស្ត្រនៅឯវិមានសភា ក្នុងទីក្រុងកង់បេរ៉ា ប្រទេសអូស្ត្រាលី កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤។

ការផ្លាស់ប្តូរដែលបង្កផលប៉ះពាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រួមមានផលប៉ះពាល់នៃការប្រកួតប្រជែងជាយុទ្ធសាស្ត្ររបស់មហាអំណាច ឥទ្ធិពលកាន់តែខ្លាំងឡើងរបស់ចិននៅក្នុងតំបន់ និងផលប៉ះពាល់ដ៏មហន្តរាយនៃជំងឺកូវីដ-១៩ បានដាក់សម្ពាធទៅលើមហិច្ឆតាគោលនយោបាយការបរទេសរបស់អូស្ត្រាលី។ ក្រៅពីផលប៉ះពាល់ដ៏ធំធេងទៅលើផ្នែកសុខាភិបាលនិងសេដ្ឋកិច្ចរបស់អូស្ត្រាលី ជំងឺកូវីដ-១៩ បានធ្វើឱ្យកង្វល់ចាស់ៗមានឡើងវិញ  និងធ្វើឱ្យទម្រង់ថ្មីៗនៃគោលនយោបាយរយៈខ្លីលេចឡើងផងដែរ។ តម្រូវការផ្នែកការទូតរបស់អូស្ត្រាលីក៏ត្រូវបានផ្លាស់ប្តូរ។

ក្នុងនាមជាប្រទេសមួយដែលមិនមានសមត្ថភាព «អន្ទងឬប្រើកម្លាំងដើម្បីសម្រេចទិសដៅរបស់ខ្លួននៅលើពិភពលោក»[3]  អូស្ត្រាលីនៅតែជួបបញ្ហាក្នុងការលើកកម្ពស់ផលប្រយោជន៍និងគុណតម្លៃនានាតាមរយៈបណ្តាញ និងអន្តរកម្មការទូតដែលមាន។ អ្នកការទូតកំពូលរបស់អូស្ត្រាលី លោកស្រី Frances Adamson គាំទ្រទម្រង់មួយនៃ «ការទូតបែបស្ថាបនា» ជាមធ្យោបាយមួយដែលអូស្ត្រាលីគួរតម្រែតម្រង់ដោយប្រុងប្រយ័ត្នលើជវភាពជាយុទ្ធសាស្ត្រនៃការប្រកួតប្រជែងនិងការប្រឡងប្រណាំងនៅក្នុងឥណ្ឌូប៉ាស៊ីហ្វិក។

ការទូតបែបស្ថាបនារបស់លោកស្រី Adamson សង្កត់ធ្ងន់លើការផ្តោតក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិករបស់អូស្ត្រាលី។ ដោយឆ្លុះបញ្ចាំងពីចំណង់របស់អូស្ត្រាលីដើម្បី «បង្កើតលទ្ធផលដែលមានសារៈសំខាន់ចំពោះអនាគតរបស់ប្រទេសយើងនិងតំបន់របស់យើង»[4]  ទស្សនៈរបស់លោកស្រីស្តីពីការចូលរួមបែបស្ថាបនា បញ្ជាក់ពីគំនិតនៃអំណាចទន់ជាបទដ្ឋាន។ ទស្សនៈរៀបចំឡើងផ្អែកលើគំនិតនៃ «តថនិយមបែបស្ថាបនា» ជាពាក្យមួយ

1. Australian Government, “2017 Foreign Policy White Paper” (Canberra: Commonwealth of Australia, 2017), p. v.
2. The “Indo-Pacific” is described in the 2017 Foreign Policy White Paper as the geographic region “stretching from the eastern Indian Ocean to the Pacific Ocean connected by Southeast Asia, including India, Northeast Asia and the United States” (p.1).
3. Peter Varghese, “An Australian world view: A practitioner’s perspective,” Address to the Lowy Institute for International Affairs, August 20 2015.
4. Frances Adamson, Address to ANU National Security College 10th Anniversary Lecture Series, 25 November 15 2020.

ដែលអតីតនាយករដ្ឋមន្ត្រី Kevin Rudd បានប្រើដើម្បីពិពណ៌នាពីតម្រូវការឱ្យមាន «លក្ខណៈស្ថាបនានៅកន្លែងណាដែលពិបាក ប៉ុន្តែអាចធ្វើបានដើម្បីធ្វើការជាមួយគ្នាដូចធម្មតា»។[5]

ដោយសំដៅទៅលើសារៈសំខាន់នៃការគ្រប់គ្រងបដិមតិ វាច្បាស់ណាស់ថា ចិនអាចជាប្រធានវិស័យភាពចម្បងនៃការទូតបែបស្ថាបនា។ ដូចលោកស្រី Adamson បញ្ជាក់ «អ្វីដែលសំខាន់គឺថាមធ្យោបាយទំនាក់ទំនងត្រូវតែបើកចំហ។ ការខ្វែងគំនិតគ្នាត្រូវបានដោះស្រាយដោយប្រុងប្រយ័ត្ននិងដោយការគោរព ទន្ទឹមគ្នានឹងការផ្តោតលើមូលដ្ឋានគ្រឹះជាវិជ្ជមាននិងឱកាសនានាពេលអនាគត»។[6]

អស់រយៈពេល៥ឆ្នាំមកហើយ ទំនាក់ទំនងទ្វេភាគីរបស់អូស្ត្រាលីជាមួយក្រុមមហាអំណាចសកលលោកកាន់តែយ៉ាប់យឺនខ្លាំង ដែលជាទំនោរមួយដែលអ្នកខ្លះផ្តល់យល់ថា និន្នាការនេះអាចនឹងបន្តពេលអនាគតខាង មុខ។ ជំហរជាវោហារសាស្ត្ររបស់អូស្ត្រាលីលើបញ្ហាផ្សេងៗ រាប់ចាប់តាំងពីការជ្រៀតជ្រែករបស់បរទេសរហូតដល់ប្រភពដើមជំងឺកូវីដ-១៩ បានជួបនឹងកំហឹងរបស់អ្នកការទូតសង្គ្រាមចចករបស់ចិននិងអមដោយសំណុំនៃការដាក់ទណ្ឌកម្មសេដ្ឋកិច្ចដែលគេបានកំណត់ទុក។

វិសាលភាពនៅ «ការទូតបែបស្ថាបនា» នៅមានកម្រិតនៅក្នុងទំនាក់ទំនងទ្វេភាគីដែលបណ្តាញទំនាក់ទំនងផ្លូវការត្រូវបានបង្កក និងនៅចំណុចដែលគោលនយោបាយនៃភាគីទាំងពីរត្រូវបានកាត់បន្ថយទៅជាគំនិតផ្សេងៗនិងអត្ថបទដកស្រង់ចេញពីបទសម្ភាសន៍នានាដែលប្រព័ន្ធផ្សព្វផ្សាយសង្គមបានបន្លឺឡើងទៅតាមបញ្ហានីមួយៗនោះ។[7]

5. Paige Carfree, “Former PM Rudd warns Australia-China relationship must stay positive,” Griffith News, Sept. 9, 2019.

6. Frances Adamson, Remarks at Australia-China Reception, Ambassador’s Residence, Beijing, April 25 2019.

7. Paul Kelly, “Our China relationship needs help before it’s too late,” The Australian, September 16 2020.

ទោះបីយ៉ាងណា អ្វីដែលជាតថភាពគឺថា ចិននឹងបន្តធ្វើជាតួអង្គសំខាន់មួយក្នុងតំបន់និងជាដៃគូពាណិជ្ជកម្មដ៏សំខាន់មួយនៅក្នុងពេលអនាគតរបស់អូស្ត្រាលី។ របៀបដែលអូស្ត្រាលីកសាងឡើងវិញនិងធ្វើឱ្យទំនាក់ទំនងមាននិរន្តរភាពជាមួយចិនសម្រាប់រយៈពេលវែងនឹងក្លាយជាកត់សម្គាល់នូវភាពស្ទិតស្ទាញផ្នែកការទូតរបស់អូស្ត្រាលី។ វាមិនមានវិធីសាស្ត្រណាដែលត្រង់ផ្លូវនោះទេ ប៉ុន្តែគេត្រូវលើកទឹកចិត្តឱ្យមានទម្រង់នៃការចូលរួមបែបស្ថាបនាទាំងនៅក្នុងនិងក្រៅវិស័យផ្លូវការ។

បញ្ហាប្រឈមសម្រាប់ការទូតបែបស្ថាបនា គឺទៅហួសក្រៅពីប្រទេសចិនទៅទៀត ដែល «អនាគតនិងជោគវាសនារបស់ជនជាតិអូស្ត្រាលី[គឺ]តភ្ជាប់ទៅនឹងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកដោយមិនអាចផ្តាច់បាន»។[8] នៅក្នុង បរិបទនេះ វារាប់បញ្ចូលការចូលរួមយ៉ាងសកម្មនៅក្នុងវេទិកាពហុភាគី និងតាមរយៈបក្សសម្ព័ន្ធនិងក្រុមផ្សេងទៀតដែលនាំមកនូវទម្ងន់ផ្នែកយុទ្ធសាស្ត្រ។ កិច្ចសន្ទនាសន្តិសុខចតុភាគី (Quad) បានបញ្ចូលអូស្ត្រាលីជាមួយជប៉ុន ឥណ្ឌា និងសហរដ្ឋអាម៉េរិកគឺជាឧទាហរណ៍មួយ។ ចំណុចរសើបដែលចៀសមិនផុតដែលនៅជុំវិញតួនាទីនិងគោលបំណងនៃកិច្ចសន្ទនាសន្តិសុខចតុភាគី (Quad) ក៏នៅតែមាន។ ទោះបីយ៉ាងណាកិច្ចខំប្រឹងប្រែងថ្មីៗនេះ រួមមានកិច្ចព្រមព្រៀងដោយមេដឹកនាំទាំងបួន ដើម្បីបង្កើតភាពជាដៃគូវ៉ាក់សាំងដែលមានតម្លៃ១០០លានដុល្លារ អាចជាតឹកតាងនៃលក្ខណៈស្ថាបនា ហើយប្រសិនផ្លាស់ប្តូរទៅជាលទ្ធផលជាក់ស្តែងទៀតនោះ អាចធ្វើឱ្យប្រសើរឡើងនៃភាពទាក់ទាញក្នុងតំបន់របស់កិច្ចសន្ទនាសន្តិសុខចតុភាគី (Quad) ទាន់ពេលវេលា។[9]

បរិយាកាសក្រោយជំងឺកូវីដ-១៩ ទាមទារការកែសម្រួលឡើងវិញនូវកិច្ចខំប្រឹងប្រែងផ្នែកការទូតឆ្ពោះទៅរកអភិបាលកិច្ចសុខាភិបាល

8. Frances Adamson, Leaders on Asia Address, Asia Society, Melbourne, April 21 2021

9. Greg Jennett, “Australia joins US, India and Japan in ‘unprecedented’ deal for coronavirus vaccines after historic Quad meeting,” ABC News, March 13, 2021.




នាយករដ្ឋមន្ត្រីអូស្ត្រាលី លោក Scott Morrison យល់ឃើញថា៖ «គោលនយោបាយការបរទេសដែលមានលក្ខណៈស្ថាបនា” របស់ប្រទេសរបស់គាត់ ត្រូវប្រឈមដោយកត្តាជាច្រើនដែលក្នុងនោះមានជម្លោះជាមួយប្រទេសចិន ព្រមទាំងជំងឺកូវីដ-១៩។ នៅក្នុងរូបភាព លោកនាយករដ្ឋមន្ត្រី Scott Morrison តម្រង់ម៉ាស់របស់គាត់ក្នុងដំណើរទស្សនកិច្ចទៅកាន់ទីក្រុងប៉ារីស កាលពីខែមិថុនា ឆ្នាំ២០២១




អូស្ត្រាលីកំពុងកំណត់ការវិនិយោគធំៗ នៅអាស៊ីអាគ្នេយ៍និងកោះប៉ាស៊ីហ្វិកដើម្បីចូលរួមជាមួយស្ថាប័នតំបន់សំខាន់ៗរួមមានកិច្ចប្រជុំអាស៊ីបូព៌ា (EAS) និងវេទិកាកោះប៉ាស៊ីហ្វិក (PIF) ។

សេដ្ឋកិច្ច បរិស្ថាន និងបច្ចេកវិទ្យាឱ្យមានភាពប្រសើរឡើង។ ការសង្កត់ធ្ងន់សំខាន់ គឺឆ្ពោះទៅរកការកសាងភាពធន់នៅក្នុងការប្រឈមមុខជាមួយសម្ពាធនិងបញ្ហាប្រឈមពីខាងក្រៅជាច្រើនតាំងពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិតរហូតដល់បម្រែបម្រួលអាកាសធាតុ។ ជាមួយនឹងការវិនិយោគសំខាន់ៗ ដែលបានរៀបចំទុកសម្រាប់អាស៊ីអាគ្នេយ៍និងតំបន់កោះប៉ាស៊ីហ្វិក អូស្ត្រាលីនឹងស្វែងរកការចូលរួមពាក់ព័ន្ធតាមរយៈស្ថាប័នតំបន់សំខាន់ៗ ដូចជាជំនួបកំពូលអាស៊ីបូព៌ា (EAS) និងវេទិកាកោះប៉ាស៊ីហ្វិក (PIF) និងជាមួយដៃគូផ្សេងៗទៀត ដើម្បីធ្វើឱ្យជឿនលឿននូវរបៀបវារៈមិនមែនប្រពៃណីទាំងនេះ។[10] ជាផលត្រឡប់វិញ ប្រទេសនានាក្នុងតំបន់នឹងសម្លឹងមើលអូស្ត្រាលីដើម្បីបង្ហាញពីការយល់ដឹងពិតប្រាកដនិងការចូលរួមជាមួយតម្រូវការនិងផលប្រយោជន៍តំបន់។

ជំងឺកូវីដ-១៩ បានធ្វើឱ្យឃើញច្បាស់ពីតម្រូវការសម្រាប់ការចូលរួមផ្នែកការទូតបែបស្ថាបនាកាន់តែខ្លាំង។ ប៉ុន្តែវាក៏បាននាំមកនូវសម្ពាធថ្មីនិងបានផ្លាស់ប្តូរអាទិភាពនានាផងដែរ។ នៅក្នុងក្របខណ្ឌផ្ទៃក្នុងប្រទេស ទស្សនទាននេះនៅតែរងឥទ្ធិពលដោយការចង់បានការនិយាយពីអំណាចរឹង។[11]

អស់រយៈពេលជាងមួយទសវត្សរ៍មកនេះ រដ្ឋាភិបាលអភិរក្សនិយមរបស់អូស្ត្រាលីបានពង្រីកនិងបង្កើនការការពារជាតិនិងផ្នែកសន្តិសុខដែលប៉ះពាល់គោលនយោបាយការបរទេស។ ដោយឆ្លុះបញ្ចាំងពីការខ្វាយខ្វល់កាន់តែខ្លាំងរបស់សាធារណជនអូស្ត្រាលីអំពីពិភពលោក វាក៏ជាវិធីសាស្ត្រមួយផងដែរដែលអាចប្រែទៅការគាំទ្រការបោះឆ្នោត។

តថភាពនៃការផ្លាស់ប្តូរសកលលោក បានបង្ហាញឱ្យឃើញយ៉ាងពិតប្រាកដថា កម្រិតនិងវិសាលភាពនៃឯកសារសគោលនយោបាយការបរទេសឆ្នាំ២០១៧ គ្មានអ្វីជាផលសោះឡើយ។ មហិច្ឆតានៃ «មហាអំណាចតំបន់ដោយគិតពីផលប្រយោជន៍សកលលោក» ដែលប្រកាសដោយខ្លួនឯងនោះ ត្រូវការកែសម្រួលឡើងវិញ។ ទន្ទឹមនឹងនោះ «ការទូតបែបស្ថាបនា» ប្រសិនមានការគាំទ្រដោយការវិនិយោគលើជំនាញ ពេលវេលា និងធនធាននានា ការទូតបែបនេះផ្តល់នូវក្របខណ្ឌដ៏មានប្រយោជន៍មួយដើម្បីទ្រទ្រង់ការចូលរួមរបស់អូស្ត្រាលីនៅក្នុងតំបន់ឆ្លងកាត់ទសវត្សរ៍បន្ទាប់នៃភាពមិនប្រាកដប្រជា៕

10. Ibid.

11. Josh Butler, “Beating the ‘drums of war’: Pezullo and Dutton strike ominous note for Australia,” The New Daily, May 2, 2021.


© REUTERS/Charly Triballeau/Pool

កិច្ចសន្ទនាចតុភាគី (Quad) ដើរតួនាទីកាន់តែសំខាន់ខ្លាំងឡើងក្នុងនយោបាយការបរទេសឥណ្ឌា។ នៅក្នុងរូបភាព  រដ្ឋមន្ត្រីការបរទេសឥណ្ឌា លោក  Jaishankar រដ្ឋមន្ត្រីការបរទេសជប៉ុន លោក Motegi រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាម៉េរិក លោក Mike Pompeo និងរដ្ឋមន្ត្រីការបរទេសអូស្ត្រាលី លោក Payne ជួបប្រជុំគ្នាកាលពីខែតុលា ឆ្នាំ២០២០។

# ៦. ជវភាពលេចត្រដែតឡើងនៅក្នុង ឥណ្ឌូប៉ាស៊ីហ្វិក : ទស្សនវិស័យឥណ្ឌា




## បណ្ឌិត  Vijay Sakuja

បណ្ឌិត Vijay Sakhuja គឺជាអតីតនាយកមូលនិធិសមុទ្រជាតិ នៅទីក្រុងញូវដេលី ប្រទេសឥណ្ឌា ហើយបច្ចុប្បន្នគឺជាអ្នកស្រាវជ្រាវជាន់ខ្ពស់នៃវិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា។

ឥណ្ឌូប៉ាស៊ីហ្វិកគឺជាការបង្កើតភូមិសាស្ត្រថ្មីមួយដែលបញ្ចូលដែនទឹកដ៏ធំពីរគឺមហាសមុទ្រឥណ្ឌានិងមហាសមុទ្រប៉ាស៊ីហ្វិក។ តំបន់ប្រតិបត្តិការសមុទ្រដ៏ធំនេះលេចឡើងជាមួយការបង្កប់នៃទំនាក់ទំនងអរិយធម៌ពីបុរាណក្នុងចំណោមជនជាតិអារ៉ាប់ ចិន ឥណ្ឌា និងរាជាណាចក្រនានានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលបានធ្វើពាណិជ្ជកម្មឆ្លងសមុទ្រនិងមហាសមុទ្រ ហើយរដ្ឋសម័យបច្ចុប្បន្ននៃសតវត្សរ៍ទី២១ដែលកំពុងទទួលផលប្រយោជន៍ពីសមាហរណកម្មសេដ្ឋកិច្ចតាមរយៈសកលភាវូបនីយកម្ម ដែលនាំឱ្យមានតំបន់នីយមថ្មីមួយនៅក្នុងឥណ្ឌូប៉ាស៊ីហ្វិក។

តំបន់ប្រតិបត្តិការសមុទ្រឥណ្ឌូប៉ាស៊ីហ្វិកក៏បង្ហាញផងដែរពី «ភាពស្មុគស្មាញនៃសន្តិសុខតំបន់» ដែលកត់សម្គាល់ដោយជវភាពសន្តិសុខដែលមានការផ្លាស់ប្ដូរ។ ខណៈការគំរាមកំហែងនិងបញ្ហាប្រឈមមិនមែនប្រពៃណីផ្ដល់នូវកាលានុវត្តភាពជាច្រើនសម្រាប់ជម្រើសសន្តិសុខដែលសហការទៅរកគោលដៅរួម ឯការគំរាមកំហែងនិងបញ្ហាប្រឈមបែបប្រពៃណីមានលក្ខណៈជាទំនាស់ជាប់ពីធម្មជាតិ។ អន្តរប្រតិកម្មនៃបញ្ហាប្រឈមផ្នែកសន្តិសុខមិនមែនប្រពៃណីនិងបែបប្រពៃណី បាននាំឱ្យមានការអំពាវនាវឱ្យមានសណ្ដាប់ធ្នាប់ផ្អែកលើច្បាប់នៅក្នុងតំបន់ដែលបង្ហាញពីការប្រកួតប្រជែងរបស់មហាអំណាចនិងជម្លោះដែនសមុទ្រដែលកាន់តែកើតមានខ្លាំងឡើងៗ។ ទោះបីយ៉ាងណា ប្រទេសនានាក្នុងតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិកមានការប្ដេជ្ញាចិត្តក្នុងការរក្សាសន្តិភាពនិងស្ថិរភាពនៅក្នុងតំបន់ដោយធ្វើឱ្យតំបន់នេះសេរី បើកចំហ ស្ថិរភាព សន្តិសុខ បរិយាបន្ន ធន់ និងមានវិបុលភាព។

ពាក្យ ឥណ្ឌូប៉ាស៊ីហ្វិក បានលាន់ឮនៅក្នុងប្រទេសឥណ្ឌាអស់រយៈពេលជិតមួយទសវត្សរ៍ហើយ ហើយរដ្ឋាភិបាលទីក្រុងញូវដេលីបានបញ្ចូលឥណ្ឌូប៉ាស៊ីហ្វិកជាលក្ខណៈផ្ទៃក្នុងថា ជាការបង្កើតថ្មីសម្រាប់ការចូលរួមផ្នែកនយោបាយ-ការទូត-សេដ្ឋកិច្ច-យុទ្ធសាស្ត្ររបស់ខ្លួន។ សុន្ទរកថាគន្លឹះរបស់នាយករដ្ឋមន្ត្រី Narenda Modi នៅឯកិច្ចសន្ទនាសាំងហ្គ្រីឡា ក្នុងខែមិថុនា ឆ្នាំ២០១៨ ប្រហែលជាការបញ្ជាក់យ៉ាងច្បាស់លាស់បំផុតរបស់ឥណ្ឌាស្ដីពីតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។




នាយករដ្ឋមន្ត្រីឥណ្ឌា លោក Narenda Modi ថ្លែងសុន្ទរកថាគន្លឹះនៅឯកិច្ចសន្ទនាសាំងហ្គ្រីឡា IISS។

លោកនាយករដ្ឋមន្ត្រីបានគូសបង្ហាញពីចក្ខុវិស័យមួយដែលក្ដោបទិដ្ឋភាពទាំងមូលនៃឥណ្ឌូប៉ាស៊ីហ្វិកនិងបានអះអាងថា តំបន់នេះគួរតែ «សេរី បរិយាបន្ន និងបើកចំហ មានស្ថិរភាព សន្តិភាព និងវិបុលភាព»។[1] លើសពីនេះទៀតរដ្ឋាភិបាលទីក្រុងញូវដេលីមើលឃើញឥណ្ឌូប៉ាស៊ីហ្វិកថាមិនមែនជា «យុទ្ធសាស្ត្រ» ឬជា «ក្រុមផ្ដាច់មុខ» នោះទេ ហើយលោកនិយាយថា តំបន់នេះមិនត្រូវបាន «ដឹកនាំប្រឆាំងប្រទេសណាមួយទេ»។[2] នៅក្នុងបរិបទនេះ ឥណ្ឌូប៉ាស៊ីហ្វិកគឺជា □ផ្នែកបន្ថែមមួយនៃទស្សនវិជ្ជាបុរាណសម័យរបស់ឥណ្ឌាហៅថា Vasudhaiva Kutumbakam ដែល

1. “Indo-Pacific Region Not a Club of Limited Members: Modi” https://thewire.in/diplomacy/indo-pacific-modi-asean (accessed 30 March 2021).
2. Vijay Sakhuja, “India and the Indo-Pacific”, https://www.swp-berlin.org/fileadmin/contents/products/projekt_papiere/Sakhuja_BCAS_2018_Indo-Pacific_5.pdf (accessed 30 March 2021).

ចាត់ទុកពិភពលោកជាគ្រួសារតែមួយ» ហើយឥណ្ឌានៅតែប្តេជ្ញាចិត្ត «ធ្វើការជាមួយគ្នាកាន់តែជិតស្និទ្ធជាងមុន ដើម្បីជំរុញគុណតម្លៃរបស់យើង និងលើកកម្ពស់តំបន់ឥណ្ឌូប៉ាស៊ីហ្វិកប្រកបដោយសន្តិសុខ ស្ថិរភាព និងវិបុលភាព»។[3]

ឥណ្ឌាបានធ្វើសកម្មភាពរួចទៅហើយលើទស្សនទានឥណ្ឌូប៉ាស៊ីហ្វិកនៅក្នុងគំនិតផ្តួចផ្តើមនានា ដូចជាគំនិតផ្តួចផ្តើមមហាសមុទ្រឥណ្ឌូប៉ាស៊ីហ្វិក (IPOI) ដែលជាគំនិតផ្តួចផ្តើមជាសកលមួយដែលមិនផ្អែកលើសន្ធិសញ្ញា ប្រកបដោយបរិយាបន្ននិងបើកចំហ សម្រាប់ការកាត់បន្ថយបញ្ហាប្រឈមនានា ជាពិសេសនៅក្នុងដែនសមុទ្រ។[4] គំនិតផ្តួចផ្តើមមហាសមុទ្រឥណ្ឌូប៉ាស៊ីហ្វិក កសាងឡើងលើសន្តិសុខនិងកំណើនសម្រាប់អ្នករាល់គ្នានៅក្នុងគំនិតផ្តួចផ្តើមតំបន់[5] ដែលលើកទឹកចិត្តរដ្ឋនានាអភិរក្សនិងប្រើប្រាស់ដែនសមុទ្រប្រកបដោយចីរភាព និងធ្វើឱ្យកិច្ចខំប្រឹងប្រែងប្រកបដោយអត្ថន័យដើម្បីបង្កើតដែនសមុទ្រមួយដែលមានសុវត្ថិភាព សន្តិសុខ និងស្ថិរភាព។ គំនិតផ្តួចផ្តើមនេះអាចនាំឱ្យមានរបៀបវារៈកិច្ចសហប្រតិបត្តិ ដ៏មានសក្តានុពលជាច្រើនទៀតក្នុងកម្រិតទ្វេភាគីនិងពហុភាគី។


© Shutterstock

សសរស្តម្ភទាំងប្រាំពីរនៃគំនិតផ្តួចផ្តើមមហាសមុទ្រឥណ្ឌូប៉ាស៊ីហ្វិក (IPOI) ផ្តោតលើកិច្ចសហប្រតិបត្តិការជាក់ស្តែងក្នុង «សន្តិសុខ-អភិវឌ្ឍន៍-ការកសាងសមត្ថភាព» នៅក្នុងវិស័យផ្សេងៗ ដូចជា សន្តិសុខ សុវត្ថិភាព ការអភិវឌ្ឍធនធាន វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធរឹងមាំ និងបរិស្ថាន-អេកូឡូស៊ីសមុទ្រ។ កិច្ចសហប្រតិបត្តិការនេះអាចសម្រេចទៅបានដោយការបង្កើតភាពជាដៃគូ/ភាពជាដៃគូពាក់ព័ន្ធ ក្នុងចំណោមរដ្ឋនានាដែលមានចិត្តដូចគ្នាពីតំបន់ឆ្នេរសមុទ្ររបស់ទ្វីបអាហ្វ្រិកខាងកើតទៅដល់តំបន់ឆ្នេរសមុទ្រខាងលិចនៃមហាសមុទ្រប៉ាស៊ីហ្វិក។ ឥណ្ឌាកំពុងលើកទឹកចិត្តប្រទេសផ្សេងៗមិនត្រឹមតែឱ្យចូលរួមគំនិតផ្តួចផ្តើមមហាសមុទ្រឥណ្ឌូប៉ាស៊ីហ្វិកប៉ុណ្ណោះទេ ប៉ុន្តែដើម្បីដឹកនាំតំបន់ប្រតិបត្តិការជាក់លាក់ស្ថិតនៅក្រោមគំនិតផ្តួចផ្តើមនេះ។ ជាឧទាហរណ៍ អូស្ត្រាលីបានយល់ព្រមដឹកនាំសសរស្តម្ភរបស់គំនិតផ្តួចផ្តើមមហាសមុទ្រឥណ្ឌូប៉ាស៊ីហ្វិកលើវិស័យអេកូឡូស៊ីសមុទ្រ ជប៉ុនបានជ្រើសរើសវិស័យការតភ្ជាប់ និងប្រទេសអាស៊ានមួយចំនួនបានសម្តែងចំណាប់អារម្មណ៍នៅក្នុងការដឹកនាំសសរស្តម្ភនានាផងដែរ។[6]

---

3. "Prime Minister's opening remarks at the first Quadrilateral Leaders' Virtual Summit", https://pib.gov.in/PressReleaseIframePage.aspx?PRID=1704473 (accessed 30 March 2021).

4. "Indo-Pacific division Brief" https://mea.gov.in/Portal/ForeignRelation/Indo_Feb_07_2020.pdf (accessed 30 March 2021).

5. "Prime Minister Modi's remarks at International Fleet Review in Vishakhapatnam", https://www.narendramodi.in/pm-modi-at-the-international-fleet-review-2016-in-visakhapatnam-andhra-pradesh-413019 (accessed 30 March 2021).

6. "EAM's remarks at CII Partnership Summit 2020", https://mea.gov.in/Speeches-Statements.htm?dtl/33309/EAMs_remarks_at_CII_Partnership_Summit_2020 (accessed 30 March 2021).

ឥណ្ឌាក៏មើលឃើញផងដែរនូវភាពប្រសព្វគ្នារវាងគំនិតផ្តួចផ្តើមមហាសមុទ្រឥណ្ឌូប៉ាស៊ីហ្វិក (IPOI) និងចក្ខុវិស័យអាស៊ានស្តីពីឥណ្ឌូប៉ាស៊ីហ្វិក (AOIP) ដែលលើកកម្ពស់ «សន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាព សម្រាប់ប្រជាជនគ្រប់ជាតិសាសន៍ទាំងក្នុងតំបន់អាស៊ីអាគ្នេយ៍ ព្រមទាំងតំបន់អាស៊ីប៉ាស៊ីហ្វិកនិងមហាសមុទ្រឥណ្ឌាដ៏ធំទូលាយឬឥណ្ឌូប៉ាស៊ីហ្វិក»[7] និងប្រសព្វគ្នាជាមួយនឹងយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកសេរីនិងបើកចំហរបស់ជប៉ុន ដែលព្យាយាមលើកកម្ពស់សណ្តាប់ធ្នាប់សមុទ្រសេរីនិងបើកចំហនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក និងត្រូវបានកសាងឡើងផ្អែកលើសសរស្តម្ភចំនួនបី រួមមានការលើកកម្ពស់និងការបង្កើតនីតិរដ្ឋ សេរីភាពនាវាចរណ៍ និងពាណិជ្ជកម្មសេរី។[8]

ប្រទេសចិនមានការសង្ស័យពីការបង្កើតតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ហើយចិនយល់ថា កិច្ចសន្ទនាសន្តិសុខចតុភាគីក្នុងចំណោមអូស្ត្រាលី ឥណ្ឌា ជប៉ុន និងសហរដ្ឋអាម៉េរិក ជាសម្ព័ន្ធមិត្តមួយប្រឆាំងនឹងចិន។ ចិនថែមទាំងបានលាបពណ៌ក្រុមនេះថា ជា «ណាតូអាស៊ី» ទៀតផង។ [9]



ទស្សនទានរបស់តំបន់ឥណ្ឌូប៉ាស៊ីហ្វិកគឺស្ថិតក្នុងពេលមានការប្រកួតប្រជែងយ៉ាងខ្លាំង និងអាចបង្កើតប្លុកដែលដឹកនាំដោយចិន ប្លុកដែលគាំទ្រដោយរុស្ស៊ី និងប្លុកដែលគាំទ្រដោយសហរដ្ឋអាម៉េរិក។ ប្លុកនយោបាយទាំងនេះ នឹងធ្វើឱ្យរង្គោះរង្គើដល់ជវភាពភូមិសាស្ត្រនយោបាយនៃតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ហើយមាគ៌ានៃតំបន់នេះដែលនឹងកំណត់អនាគតនៃសន្តិសុខរបស់អាស៊ីលេចចេញជារូបរាងឡើង។ រដ្ឋជាសមាជិកអាស៊ាននានានឹងស្ថិតនៅក្រោមសម្ពាធដ៏ធ្ងន់ធ្ងរឱ្យប្រកាន់យកជម្រើសដែលអាចបន្ថែមកាន់តែខ្លាំងទៅលើអសន្តិសុខដែលកំពុងវិវត្តយ៉ាងលឿននៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកនោះ។

7. “ASEAN Outlook on the Indo-Pacific” https://asean.org/storage/2019/06/ASEAN-Outlook-on-the-Indo-Pacific_FINAL_22062019.pdf (accessed 30 March 2021).

8. “A New Foreign Policy Strategy: “Free and Open Indo-Pacific Strategy”", https://www.asean.emb-japan.go.jp/files/000352880.pdf (accessed 30 March 2021).

9. “Washington’s attempt to exploit QUAD to contain China will not succeed”, https://www.globaltimes.cn/page/202102/1215232.shtml (accessed 04 June 2021).

ជាមួយនឹងទីតាំងកណ្តាលនៅក្នុងមហាសមុទ្រឥណ្ឌា ឧបទ្វីបឥណ្ឌាស្ថិតនៅលើផ្លូវពាណិជ្ជកម្មផ្លូវទឹកមួយក្នុងចំណោមផ្លូវទឹកដ៏មមាញឹកជាងគេបំផុតនៅលើពិភពលោក។ ឧទាហរណ៍ជាក់ស្តែង ៦៤% នៃជំនួញប្រេងរបស់ពិភពលោក ត្រូវបានដឹកជញ្ជូនតាមមហាសមុទ្រឥណ្ឌា។



© European Union 2019 – Source: EP

បើប្រៀបធៀបជាមួយរដ្ឋជាសមាជិករបស់ខ្លួនមួយចំនួន សហភាពអឺរ៉ុបមានភាពយឺតយ៉ាវនៅក្នុងការបង្ហាញពីយុទ្ធសាស្ត្ររបស់ខ្លួនស្តីពីឥណ្ឌូប៉ាស៊ីហ្វិក។ នៅក្នុងរូបភាព ប្រធានគណៈកម្មាធិការអឺរ៉ុប លោកស្រី Ursula von der Leyen។

# ៧. ទំនោររបស់អឺរ៉ុបចំពោះឥណ្ឌូប៉ាស៊ីហ្វិក




## Isabel Weininger

Isabel Weininger គឺជាតំណាងប្រចាំប្រទេសនៃមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ (KAS) ប្រចាំប្រទេសកម្ពុជា។ កន្លងមក លោកស្រីធ្លាប់ជាប្រធានគ្រប់គ្រងការិយាល័យសម្រាប់អាស៊ីអាគ្នេយ៍នៅក្នុងនាយកដ្ឋានអាស៊ីនិងប៉ាស៊ីហ្វិកនៅឯទីស្នាក់ការកណ្តាលនៃមូលនិធិខុនរ៉ាដអាដិណៅអ៊ែរក្នុងទីក្រុងប៊ែកឡាំង និងអនុប្រធានមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ ដែលមានការិយាល័យនៅក្នុងទីក្រុងកៀវ ប្រទេសអ៊ុយក្រែន។ មុនចូលបម្រើការនៅមូលនិធិខុនរ៉ាដអាដិណៅអ៊ែរ លោកស្រីបានបម្រើការឱ្យសន្និសីទសន្តិសុខទីក្រុងមូនីក។ លោកស្រី Isabel បានសិក្សាវិទ្យាសាស្ត្រនយោបាយនិងទំនាក់ទំនងអន្តរជាតិនៅក្នុងទីក្រុងមូនីក ទីក្រុងប៉ារីស និងជ្រេសដិន។

មានសុភាសិតមួយនិយាយថា ត្បាល់ធំកិនយឺត។ នេះជារឿងពិតជាក់ស្ដែងសម្រាប់សហភាពអឺរ៉ុប (EU) និងចំពោះទំនោរប្រកបដោយការប្រយ័ត្នប្រយែងរបស់ខ្លួនចំពោះឥណ្ឌូប៉ាស៊ីហ្វិក។ ដោយដឹងថាដៃគូនានានៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកកំពុងរំពឹងការចូលរួមកាន់តែខ្លាំងពីអឺរ៉ុបនោះ ក្រុមប្រឹក្សារបស់សហភាពអឺរ៉ុបបានអនុម័តយុទ្ធសាស្ត្រសហភាពអឺរ៉ុបមួយសម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ មាតិកានៃយុទ្ធសាស្ត្រនេះ គឺមានលក្ខណៈជាក់ស្ដែងនិយម ប៉ុន្តែមានភាពទាក់ទាញ។

ឥណ្ឌូប៉ាស៊ីហ្វិកគឺជាជម្រកនៃមហាអំណាចសេដ្ឋកិច្ចចំនួនបីក្នុងចំណោមមហាអំណាចសេដ្ឋកិច្ចទាំងបួននៅខាងក្រៅទ្វីបអឺរ៉ុប៖ ចិន ឥណ្ឌា និងជប៉ុន។ ឥណ្ឌូប៉ាស៊ីហ្វិកផលិតស្ទើរតែ៦០%នៃផលិតផលក្នុងស្រុកសរុបរបស់សកលលោក ដែលរួមចំណែកពីរភាគបីនៃកំណើនសកលលោក ដែលនឹងទំនងជាកើនឡើងនាពេលអនាគតទៅទៀត។ ការប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុនឹងត្រូវចាញ់ឬឈ្នះនៅក្នុងទ្វីបអាស៊ី ដែលជាតំបន់មួយជាជម្រកនៃប្រទេសដែលបំពុលខ្លាំងជាងគេ និងជារឿងមិនសមហេតុផលដែរនោះ គឺមានក្រុមហ៊ុនចីរភាពដែលឈានមុខគេ។

សហភាពអឺរ៉ុបគឺជាដៃគូចម្បងចំពោះឥណ្ឌូប៉ាស៊ីហ្វិកក្នុងនាមជា «វិនិយោគិនធំជាងគេ អ្នកផ្ដល់ជំនួយអភិវឌ្ឍន៍ច្រើនជាងគេ និងដៃគូពាណិជ្ជកម្មដ៏ធំមួយនៅក្នុងតំបន់»។»[1] សហភាពអឺរ៉ុបបានក្លាយជាដៃគូពាណិជ្ជកម្មធំជាងគេបំផុតទីពីររបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) បន្ទាប់ពីចិន ហើយអាស៊ានគឺជាដៃគូពាណិជ្ជកម្មធំជាងគេបំផុតទីបីរបស់សហភាពអឺរ៉ុបនៅខាងក្រៅតំបន់អឺរ៉ុបបន្ទាប់ពីសហរដ្ឋអាម៉េរិកនិងចិន។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ក្រុមប្រឹក្សាសហភាពអឺរ៉ុបបានអនុម័តសេចក្ដីសម្រេចស្ដីពី «យុទ្ធសាស្ត្រសហភាពអឺរ៉ុបសម្រាប់កិច្ចសហប្រតិបត្តិការក្នុងឥណ្ឌូប៉ាស៊ីហ្វិក» ដែលអនុលោមតាមការផ្លាស់ប្ដូរខាងភូមិសាស្ត្រនយោបាយនៅក្នុងពិភពលោក ឆ្ពោះទៅរកឥណ្ឌូប៉ាស៊ីហ្វិក។[2] អឺរ៉ុបធ្លាប់រំពឹងឥណ្ឌូប៉ាស៊ីហ្វិកក្នុងការរក្សាស្ថិរភាពនិងសន្តិសុខសម្រាប់រយៈពេលប៉ុន្មានទសវត្សរ៍មកនេះ ទោះបីជាខ្លួនមិនបានទទួលស្គាល់ពីសារៈសំខាន់យុទ្ធភូមិសាស្ត្ររបស់តំបន់ ហើយក៏មិនបានផ្ដល់ជំនួយច្រើនដើម្បីរក្សាស្ថិរភាពតំបន់នេះក៏ដោយ។ ខណៈសហភាពអឺរ៉ុបមានភាពយឺតយ៉ាវនៅក្នុងល្បែងជាមួយយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិករបស់ខ្លួន (ជាឧទាហរណ៍) បើប្រៀបធៀបទៅនឹងសហរដ្ឋអាម៉េរិកឬរដ្ឋសមាជិកសហភាពអឺរ៉ុបផ្សេងទៀត ដូចជា បារាំង  យុទ្ធសាស្ត្ររបស់សហភាពអឺរ៉ុបឆ្លុះបញ្ចាំងពីគោលបំណងរបស់សហភាពអឺរ៉ុបក្នុងការទទួលខុសត្រូវបន្ថែមក្នុងនាមជាតួអង្គគោលនយោបាយ ការបរទេសក្នុងពេលមានការប្រកួតប្រជែងកាន់តែខ្លាំងរវាងសហរដ្ឋអាម៉េរិកនិងចិន។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាអាចជាសារនយោបាយដ៏រឹងមាំមួយទៅដល់ដៃគូរបស់សហភាពអឺរ៉ុបនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក ប្រសិនរបៀបវារៈដែលមានលក្ខណៈប្រតិបត្តិជាក់ស្ដែងត្រូវបានអនុវត្តដោយភាពក្លាហាននោះ។ សំណួរពេលនេះគឺថា តើអ្វីដែលថ្មីនៅក្នុងរបៀបវារៈនេះ ហើយហេតុអ្វីបានជាវាពាក់ព័ន្ធសម្រាប់តំបន់។

1. European External Action Service, “EU Strategy for Cooperation in the Indo-Pacific,” EEAS 2021, April 2021, https://eeas.europa.eu/sites/default/files/eu-indo-pacific_factsheet_2021-04_v.5.pdf.

2. General Secretariat of the Council, “Council conclusions on an EU Strategy for cooperation in the Indo-Pacific,” Council of the European Union, April 16, 2021, https://data.consilium.europa.eu/doc/document/ST-7914-2021-INIT/en/pdf.




© Flickr/Ministerie van Buitenlandse Zaken

រដ្ឋមន្ត្រីការបរទេសមកពីសហភាពអឺរ៉ុបនិងបណ្ដាប្រទេសអាស៊ានចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុប លើកទី២១ ដែលប្រទេសថៃធ្វើជាម្ចាស់ផ្ទះនៅខែតុលា ឆ្នាំ២០១៦ ក្រោមបាវចនា «ឆ្ពោះទៅរកភាពជាដៃគូយុទ្ធសាស្ត្រ» ភាគីទាំងពីរបានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើបញ្ហាជាច្រើន ទាក់ទងនឹងនយោបាយ សេដ្ឋកិច្ច និងសន្តិសុខ។




តំបន់ភូមិសាស្ត្រដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្ររបស់សហភាពអឺរ៉ុបលាតសន្ធឹងពីឆ្នេរខាងកើតនៃទ្វីបអាហ្វ្រិករហូតដល់រដ្ឋកោះប៉ាស៊ីហ្វិក។ លើសពីនេះ វាគូសបញ្ជាក់ពីខ្សែទំនាក់ទំនងសមុទ្រនិងលំហសមុទ្រនៃមហាសមុទ្រឥណ្ឌានិងប៉ាស៊ីហ្វិក។

## វិសាលភាពនិងខ្លឹមសារ

ជាជំហានដំបូង សហភាពអឺរ៉ុបបានបោះពុម្ពផ្សាយសេចក្តីសម្រេចដោយក្រុមប្រឹក្សាជាទម្រង់គំនិតមួយមានកម្រាស់១០ទំព័រ។ ជំហានបន្ទាប់គឺសម្រាប់តំណាងជាន់ខ្ពស់ លោក Josep Borrell និងគណៈកម្មការធិការសហភាពអឺរ៉ុប ក្នុងការបរិយាយល្អិតល្អន់នូវយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយស្តីពីតំបន់ឥណ្ឌូប៉ាស៊ីហ្វិក នៅខែកញ្ញាឆ្នាំ២០២១។ តំបន់ភូមិសាស្ត្រដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រសហភាពអឺរ៉ុបលាតសន្ធឹងពីឆ្នេរខាងកើតរបស់ទ្វីបអាហ្វ្រិកទៅដល់បណ្តារដ្ឋដែនកោះប៉ាស៊ីហ្វិក។ លើសពីនេះទៀតយុទ្ធសាស្ត្រនេះបង្ហាញពីបណ្តាញទំនាក់ទំនងដែនសមុទ្រនៃមហាសមុទ្រឥណ្ឌានិងមហាសមុទ្រប៉ាស៊ីហ្វិក។ បើសម្លឹងមើលចំណងជើងទាំង៦ក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ការផ្តោតគឺទៅលើដៃគូនានា ពហុភាគីនិយមនិងពិពិធកម្ម។

ក្រុមប្រឹក្សាបានជ្រើសរើសវិស័យគោលនយោបាយជាយុទ្ធសាស្ត្រដើម្បីរឹតចំណងទំនាក់ទំនងរវាងអឺរ៉ុបនិងឥណ្ឌូប៉ាស៊ីហ្វិក។ វិស័យទាំងនេះ រួមមាន សន្តិសុខនិងការពារជាតិ ការតភ្ជាប់ ការស្រាវជ្រាវ និងនវានុវត្តន៍។ នៅក្នុងសង្វៀនសន្តិសុខ បណ្តាប្រទេសនៅឥណ្ឌូប៉ាស៊ីហ្វិករំពឹងថា សហភាពអឺរ៉ុបនឹងចូលរួមចំណែកដល់សន្តិសុខសមុទ្រនិងលើកកម្ពស់សេរីភាពនាវា-ចរណ៍។ លើសពីនេះទៀត កិច្ចសហប្រតិបត្តិការក្នុងការប្រឆាំងចំពោះការគំរាមកំហែងដល់វិស័យសន្តិសុខឆ្លងប្រទេស ដូចជាភេរវកម្ម ព័ត៌មានក្លែងក្លាយ និងការវាយប្រហារតាមអ៊ីនធឺណិតក៏ត្រូវបានដាក់បញ្ចូលផងដែរ។ ផលប៉ះពាល់ជាវិជ្ជមានបំផុត អាចសម្រេចបានដោយកិច្ចសហប្រតិបត្តិការដែលកាន់តែស៊ីជម្រៅពាក់ព័ន្ធនឹងការអភិវឌ្ឍឆ្ពោះទៅអនាគត ដូចជា ការតភ្ជាប់ដែលមានគុណភាពខ្ពស់( គម្រោងឌីជីថល ការដឹកជញ្ជូនថាមពលនិងហេដ្ឋារចនាសម្ព័ន្ធ ) ការស្រាវជ្រាវ នវានុវត្តន៍ និងឌីជីថល-នីយកម្ម។ ជាឧទាហរណ៍ការផ្លាស់ប្តូរការស្រាវជ្រាវថែមទៀត គម្រោងហេដ្ឋារចនាសម្ព័ន្ធរួមគ្នា និងការតភ្ជាប់ច្រើនឡើងដោយលក្ខណៈចីរភាព បៃតង និងឌីជីថល គឺមានប្រយោជន៍ទៅវិញទៅមកសម្រាប់តំបន់ទាំងពីរ។

## ភាពជាដៃគូ និងពហុភាគីនិយម

ទិដ្ឋភាពចម្បងនៃឯកសារទៅហួសពីទំនាក់ទំនងរបស់សហភាពអឺរ៉ុបជាមួយចិន។ ឯកសារនេះគិតពិចារណាពីតួអង្គជាច្រើនក្រៅពីប្រទេសជាដៃគូនានា ក៏មានអង្គការក្នុងតំបន់ឬទម្រង់ផ្លាស់ប្តូរមិនផ្លូវការនានាផងដែរ។ ក្រុមប្រឹក្សាបានរំលេចពីសារៈសំខាន់នៃភាពជាដៃគូក្នុងតំបន់ដែលបាននិយាយពីមុននៅក្នុងកថាខណ្ឌទីមួយនៃឯកសារនោះ។ ដៃគូទាំងនេះរាប់បញ្ចូលប្រទេសដែលមានចិត្តដូចគ្នាដែលបានប្រកាសពីវិធីសាស្ត្ររបស់ពួកគេរៀងៗខ្លួនរួចហើយស្តីពីឥណ្ឌូប៉ាស៊ីហ្វិក និងបានបង្កើតទស្សនទានថ្មីស្តីពីឥណ្ឌូប៉ាស៊ីហ្វិក ជាឧទាហរណ៍មាន សហរដ្ឋអាមេរិក ជប៉ុន អូស្ត្រាលី និងឥណ្ឌា ជាដើម។ ជាងនេះទៅទៀត តួអង្គសំខាន់ៗក្នុងតំបន់ដូចជា អាស៊ាន និងទម្រង់ដូចជាកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) ត្រូវបានរៀបរាប់ឈ្មោះយ៉ាងច្បាស់លាស់ថាជាដៃគូនិងជាវេទិកាសំខាន់។

ទាក់ទិននឹងទំនាក់ទំនងរវាងសហភាពអឺរ៉ុប-ចិនវិញ ក្រុមប្រឹក្សាអះអាងសាជាថ្មីពីតួនាទីរបស់ចិនជាដៃគូសហប្រតិបត្តិការមួយ ប៉ុន្តែក៏ជាគូប្រឆាំងជាប្រព័ន្ធផងដែរ ដូចដែលបានលើកឡើងពីដំបូងនៅក្នុងចក្ខុវិស័យយុទ្ធសាស្ត្រសហភាពអឺរ៉ុប-ចិនឆ្នាំ២០១៩។[3] ចាប់តាំងពីឆ្នាំ១៩៧៥ នៅពេលទំនាក់ទំនងការទូតចិន-សហភាព

3. European Commission and HR/VP contribution to the European Council, "EU-China – A strategic outlook," European Commission, March 12, 2019, p.4, https://ec.europa.eu/info/sites/default/files/communication-eu-china-a-strategic-outlook.pdf.

អឺរ៉ុប បានបង្កើតឡើងនោះ គោលនយោបាយការបរទេសអឺរ៉ុបចំពោះអាស៊ីភាគច្រើនបានផ្តោតលើចិននិងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។ ទោះបីយ៉ាងណា នៅពេលដែលទស្សនៈចំពោះចិន បានចាប់ផ្តើមធ្វើឱ្យមានលក្ខណៈខុសពីមុន នោះការផ្តោតនៃគោលនយោបាយចំពោះអាស៊ីរបស់សហភាពអឺរ៉ុបក៏បានផ្លាស់ប្តូរដែរ។ យុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាចុងក្រោយបំផុតមានការលើកពីចិនតែម្តងគត់ ដោយបញ្ជាក់យ៉ាងច្បាស់លាស់ពីគោលបំណងដើម្បី «បោះជំហានទៅមុខទៀតឆ្ពោះទៅរកកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការវិនិយោគជាមួយចិន»[4] បើទោះបីជាមិនមានអ្នកជំនាញទាំងអស់រំពឹងទុកថា សហភាពអឺរ៉ុបនឹងចាប់យកជំហានទាំងនេះទេក៏ដោយ។ នៅក្នុងកថាខណ្ឌផ្សេងទៀត មានការលើកឡើងមិនច្បាស់លាស់ទេអំពីការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងចិននិងសហរដ្ឋអាមេរិក ប៉ុន្តែការពិពណ៌នាអំពីការប្រកួតប្រជែងខាងភូមិសាស្ត្រនយោបាយនិងភាពតានតឹងខ្លាំងលើច្រវាក់ផ្គត់ផ្គង់និងពាណិជ្ជកម្មសកលលោក។ ចិនត្រូវបានដាក់បញ្ចូលនៅក្នុងយុទ្ធសាស្ត្រដែលជាផ្នែកមួយនៃបញ្ហា និងជាផ្នែកមួយនៃដំណោះស្រាយដែលអាចមាន។[5]

ចំពោះពហុភាគីនិយមវិញ សហភាពអឺរ៉ុបគាំទ្ររបៀបវារៈសកលលោករបស់អង្គការសហប្រជាជាតិ ជាឧទាហរណ៍ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) និងផ្តោតលើសិទ្ធិមនុស្ស ការផ្តល់អំណាចឱ្យស្ត្រី និងការចូលរួមសង្គមស៊ីវិល។

សម្ព័ន្ធភាពអន្តរជាតិនិងក្រមប្រតិបត្តិត្រូវបានលើកកម្ពស់ ដូចជាកិច្ចព្រមព្រៀងក្រុងប៉ារីសស្តីពីបម្រែបម្រួលអាកាសធាតុសន្និសីទស្តីពីជីវៈចម្រុះ និងកិច្ចព្រមព្រៀងបៃតងរបស់សហភាពអឺរ៉ុបផ្ទាល់។ ប្រធានបទផ្សេងទៀត រួមមាន អភិបាលកិច្ចមហាសមុទ្រ និងការកាត់បន្ថយហានិភ័យពីគ្រោះមហន្តរាយ ក៏ដូចជាកិច្ចសហប្រតិបត្តិការផ្នែកសុខាភិបាលជាមួយនឹងកិច្ចសហប្រតិបត្តិការកូវីដ-១៩ និង COVAX ត្រូវបានលើកឡើងជាឧបករណ៍ដើម្បីគាំទ្រដៃគូឥណ្ឌូប៉ាស៊ីហ្វិក។ សហភាពអឺរ៉ុបបានបង្ហាញពីសាមគ្គីភាពរបស់ខ្លួនជាមួយប្រទេសនានានៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកនៅចុងខែមេសា ឆ្នាំ២០២១ នៅពេលរោគរាតត្បាតនៅក្នុងប្រទេសឥណ្ឌាដល់កម្រិតប្រកាសអាសន្នខ្លាំងនោះ រដ្ឋជាសមាជិកសហភាពអឺរ៉ុបក៏បានផ្តល់ការគាំទ្រ ដូចជា ប្រដាប់ជំនួយដង្ហើមនិងអុកស៊ីសែន។ កិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗទៀតដែលមានផលចំពោះប្រជាជនដោយផ្ទាល់បំផុត ដូចជា ចីរភាពបរិស្ថាននិងសុខាភិបាល គឺមានគុណតម្លៃខ្ពស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់តំបន់។ ជាសង្ខេប យុទ្ធសាស្ត្រនេះគឺមានលក្ខណៈបរិយាបន្ននិងផ្តោតទៅលើដៃគូ និងជ្រើសរើសរបៀបវារៈនៃកិច្ចព្រមព្រៀងពហុភាគីដែលមានស្រាប់ ដូចជាកិច្ចព្រមព្រៀងបៃតង ដែលសហភាពអឺរ៉ុបផ្ទាល់មានរបៀបវារៈនេះដ៏រឹងមាំនោះ។

## គុណតម្លៃនិងការអះអាង

ជារឿងគួរឱ្យកត់សម្គាល់ យុទ្ធសាស្ត្រនោះបានលើកកម្ពស់ពីតួនាទីរបស់សហភាពអឺរ៉ុបជាដៃគូមួយផ្អែកលើគុណតម្លៃសម្រាប់ប្រទេសនានានៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ ក្រុមប្រឹក្សាអឺរ៉ុបផ្តោតលើការការពារនិងការធ្វើពិពិធកម្មនៃច្រវាក់ផ្គត់ផ្គង់ ព្រមទាំងលើការពង្រឹងចំណងសេដ្ឋកិច្ចជាមួយប្រទេសនានាក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលមានស្រាប់ជាមួយជប៉ុន កូរ៉េ សិង្ហបុរី និងវៀតណាម គួរត្រូវធ្វើវិសោធនកម្មយោងតាមយុទ្ធសាស្ត្រជាមួយកិច្ចព្រមព្រៀងថ្មីៗ ជាមួយអូស្ត្រាលី ឥណ្ឌូណេស៊ី និងណូវែលសេឡង់ ព្រមជាមួយនឹងអ្នកមានសក្តានុពលខ្លាំងផងដែរ ដូចជា អាស៊ាននិងឥណ្ឌា បន្ថែមទៅលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយលើការវិនិយោគជាមួយចិន។

**4.** General Secretariat of the Council, 2021, p.7

**5.** Eva Pejsova. “The EU’s Indo-Pacific Strategy in 10 Points,” The Diplomat, April 20 2021), https://thediplomat.com/2021/04/the-eus-indo-pacific-strategy-in-10-points/.




ប្រធានក្រុមប្រឹក្សាសហភាពអឺរ៉ុប Donald Tusk (C) បានអញ្ជើញមកដល់សម្រាប់ការថតរូបជាគ្រួសារជាមួយមេដឹកនាំផ្សេងទៀត អំឡុងកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប នៅខាងក្រៅ ទីក្រុង Ulaanbaatar ប្រទេសម៉ុងហ្គោលី កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៦។




កប៉ាល់បានបោះយុថ្កានៅពីមុខរោងចក្រចម្រាញ់ប្រេងមួយនៅលើកោះ Bukom ប្រទេសសិង្ហបុរី កាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៤។ ប្រហែលមួយភាគបួននៃពាណិជ្ជកម្មប្រេងតាមផ្លូវសមុទ្រឆ្លងកាត់ច្រកសមុទ្រម៉ាឡាកា ជាច្រករបៀងយុទ្ធសាស្ត្រមួយនៅលើផ្លូវទឹករវាងមជ្ឈិមបូព៌ានិងប្រទេសសេដ្ឋកិច្ចដែលស្រេកឃ្លានថាមពលរបស់សមុទ្រខាងកើត។ រូបភាពនេះបានថតនៅថ្ងៃទី៦ ខែកក្កដា។

ចំណងទំនាក់ទំនងលើវិស័យសេដ្ឋកិច្ចកាន់តែរឹងមាំ ដូចជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) គឺដើរទន្ទឹមគ្នាជាមួយការដាក់លក្ខខណ្ឌអនុគ្រោះដោយសហភាពអឺរ៉ុប ដើម្បីលើកកម្ពស់គុណតម្លៃសហភាពអឺរ៉ុប។ គោលបំណងនៃលក្ខខណ្ឌអនុគ្រោះពាណិជ្ជកម្មទាំងនោះ គឺដើម្បី «លុបបំបាត់ភាពក្រីក្រ ជំរុញកំណើន និងការងារ លើកកម្ពស់ការគោរពសិទ្ធិមនុស្សនិងសិទ្ធិពលកម្ម និងរួមបញ្ចូលកត្តាទាំងនេះទៅក្នុងច្រវាក់គុណតម្លៃសកល»។[6] ដោយសហភាពអឺរ៉ុបប្រកាន់ជំហរច្បាស់លាស់មួយ ដើម្បីផ្តល់បដិភាពនិងឱកាសស្មើភាពនៅក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ទើបយុទ្ធសាស្ត្រនេះពិតជាមានប្រយោជន៍ជាពិសេសដល់ប្រទេសនានានៅក្នុងតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិកផងដែរ។ ការផ្តោតលើគោលការណ៍ជំនួសឱ្យការស្តីបន្ទោសនិងការប្រមាថតួអង្គផ្សេងទៀតនោះ ក៏ផ្តល់នូវភាពធន់និងប្រកបដោយចីរភាព និងបង្ហាញថា សហភាពអឺរ៉ុបកំពុងវិនិយោគនៅក្នុងយុទ្ធសាស្ត្ររយៈពេលវែងមួយជំនួសឱ្យគោលនយោបាយផ្តោតលើផលប្រយោជន៍រយៈពេលខ្លីសម្រាប់តំបន់។[7]

## ភាពជាតួអង្គរបស់សហភាពអឺរ៉ុបនៅក្នុងគោលនយោបាយការបរទេស

ទិដ្ឋភាពគួរឱ្យកត់សម្គាល់មួយទៀតនៃវិធីសាស្ត្រគោលនយោបាយការបរទេសថ្មីរបស់សហភាពអឺរ៉ុប គឺ វិធីសាស្ត្រផ្តោតលើលទ្ធផលនៃគោលនយោបាយដែលអាចស្វែងរកបានយ៉ាងឆាប់រហ័សនូវការឯកភាពជាឯកច្ឆន្ទជាបឋមរវាងរដ្ឋសមាជិកទាំង២៧។ ការតស៊ូមតិដ៏សំខាន់ស្តីពីទំនោររបស់សហភាពអឺរ៉ុបចំពោះឥណ្ឌូប៉ាស៊ីហ្វិកទើបបានបន្តរយៈពេល២ឆ្នាំនិងត្រូវបានជំរុញ អំឡុងពេលការធ្វើជាគណៈប្រធានក្រុមប្រឹក្សាសហភាពអឺរ៉ុបរបស់អាល្លឺម៉ង់ក្នុងឆ្នាំ២០២០នេះប៉ុណ្ណោះ។ មានតែបារាំងនិងអតីតរដ្ឋសមាជិកសហភាពអឺរ៉ុបមួយទៀត គឺចក្រភពអង់គ្លេសទេ ដែលតែងតែសកម្មនៅក្នុងតំបន់អស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ជាមួយដែនដីក្រៅប្រទេសរបស់ពួកគេនិងក្នុងនាមជាមហាអំណាចសន្តិសុខសមុទ្រដែលបានបង្កើតឡើងនោះ។ ចំពោះមុខប្រវត្តិការណ៍នេះ ក្រសួងការពារជាតិបារាំងបានបោះពុម្ពផ្សាយឯកសារយុទ្ធសាស្ត្រសន្តិសុខមួយស្តីពីឥណ្ឌូប៉ាស៊ីហ្វិកក្នុងឆ្នាំ២០១៩ និងការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រមួយក្នុងឆ្នាំ២០២១។[8] បន្ទាប់មក គោលការណ៍ណែនាំស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិករបស់អាល្លឺម៉ង់ត្រូវបានរៀបចំឡើងនៅខែកញ្ញា ឆ្នាំ២០២០ ខណៈប្រទេសហូឡង់បានបោះពុម្ពផ្សាយកំណត់ហេតុគោលនយោបាយពីរខែក្រោយមកទៀត។ ដើម្បីប្រៀបធៀបដោយសង្ខេបពីវិធីសាស្ត្រផ្សេងគ្នារបស់រដ្ឋសមាជិកសហភាពអឺរ៉ុបទាំងបីនោះ អាល្លឺម៉ង់និងហូឡង់ផ្តោតជាសំខាន់លើការសម្លឹងផលប្រយោជន៍សេដ្ឋកិច្ចរបស់ពួកគេនៅក្នុងតំបន់ ពួកគេអាចធ្វើបែបនេះដោយការធ្វើពិពិធកម្មដៃគូពាណិជ្ជកម្មរបស់ពួកគេ ការកាត់បន្ថយភាពពឹងផ្អែកលើចិន និងការពង្រឹងទំនាក់ទំនងជាមួយប្រទេសនានាផ្អែកលើគុណតម្លៃរួម។ ក្រសួងការពារជាតិបារាំងបានប្រកាសដាក់ឱ្យដំណើរការទស្សនទានរបស់បារាំង និងផ្តោតលើសន្តិសុខនិងការការពារដែនដីក្រៅប្រទេសរបស់ពួកគេ។ មានការមើលឃើញថា កម្មវិធីរបស់ហូឡង់និងអាល្លឺម៉ង់មានភាពធំទូលាយជាងយុទ្ធសាស្ត្រការពារ និងសន្តិសុខរបស់បារាំង ដោយសារកម្មវិធីទាំងនោះគ្របដណ្តប់លើវិស័យនានា ដូចជា សិទ្ធិមនុស្ស នីតិរដ្ឋ ការតភ្ជាប់ បម្រែបម្រួលអាកាសធាតុ ការទូតវប្បធម៌ និងពហុភាគីនិយម។

6. Council 2021, p.7.

7. Pejsova 2021.

8. Further information on the French approach in the article by Laurent Triophy.

ការបញ្ចូលវិធីសាស្ត្រផ្សេងគ្នាទាំងនេះក្នុងយុទ្ធសាស្ត្រសហភាពអឺរ៉ុប ហាក់បីដូចជាមិនអាចទៅរួច ឬយ៉ាងហោចណាស់អាចនៅប៉ុន្មានឆ្នាំទៀត។ ទោះបីយ៉ាងណា សហភាពអឺរ៉ុបអាចត្រឹមតែអះអាងខ្លួនឯងថា ជាតួអង្គមួយអាចទុកចិត្តបាននៅក្នុងគោលនយោបាយការបរទេស ដោយការបញ្ចូលនូវសមត្ថភាពនិងធនធានរបស់ខ្លួន និងការប្តេជ្ញាចិត្តឡើងវិញចំពោះគុណតម្លៃរួម។[9] ការបង្រួបបង្រួមកម្មវិធីឥណ្ឌូប៉ាស៊ីហ្វិកផ្សេងៗរបស់អាល្លឺម៉ង់ បារាំង និងហូឡង់ ដើម្បីបង្កើតវិធីសាស្ត្រសហភាពអឺរ៉ុបតែមួយគត់នោះ បង្កើតនូវសង្គតិភាពយ៉ាងខ្លាំងទៅក្នុងសកម្មភាពរបស់សហភាពអឺរ៉ុបទូទាំងតំបន់ និងអាចចាប់យកជាការបញ្ឆេះម៉ាស៊ីនរបស់អាល្លឺម៉ង់-បារាំងឡើងវិញ ដើម្បីសម្រេច «ភាពជាតួអង្គ» សហភាពអឺរ៉ុបនៅក្នុងគោលនយោបាយការបរទេសនិងសន្តិសុខ។ ការបង្កាត់ពូជជាពាក្យមួយដែលឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំប្រទេសកម្ពុជា បានបង្កើតឡើងនៅក្នុងព្រឹត្តិបត្រច្បាប់នេះ ហើយនៅពេលប្រើពាក្យនេះនៅក្នុងកម្រិតសហភាពអឺរ៉ុប វានឹងមានប្រយោជន៍ចំពោះទាំងអស់គ្នា ជាពិសេសនៅក្នុងវិស័យគោលនយោបាយការបរទេស និងសន្តិសុខ ដែលប្រទេសមួយតែឯងមិនមានទម្ងន់នោះទេ។ ការអភិវឌ្ឍផ្សេងទៀតកាលពីឆ្នាំមុន បង្ហាញពីឯកភាពខ្ពស់ឡើងក្នុងចំណោមបណ្តាប្រទេសអឺរ៉ុបជាមួយនឹងមហិច្ឆតាខាងយុទ្ធសាស្ត្រ។ ជាឧទាហរណ៍ ជំហររួមមួយនៃប្រទេសដែលគេហៅថា E3 (អាល្លឺម៉ង់ បារាំង និងចក្រភពអង់គ្លេស) ពាក់ព័ន្ធនឹងការប្រកាសអធិបតេយ្យដែនសមុទ្ររបស់ប្រទេសចិននៅសមុទ្រចិនខាងត្បូង កាលពីខែកញ្ញា ឆ្នាំ២០២០[10] ឬភាពជាដៃគូយុទ្ធសាស្ត្រថ្មី ដែលសហភាពអឺរ៉ុបបានប្រកាសដាក់ឱ្យដំណើរការជាមួយអាស៊ាន នៅខែធ្នូ ឆ្នាំ២០២០។[11] សហភាពអឺរ៉ុបកំពុងដំណើរការឆ្ពោះទៅអនុម័តនូវត្រីវិស័យជាយុទ្ធសាស្ត្រមួយនៅដើមឆ្នាំ២០២២ ដើម្បីស្វែងរកបន្ថែមទៀតពីតួនាទីរបស់ខ្លួនជាតួអង្គផ្នែកសន្តិសុខ និងការពារជាតិ។[12] ឧទាហរណ៍ទាំងនេះស្របគ្នានឹងគោលបំណងខាងយុទ្ធសាស្ត្ររបស់យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិក : ដើម្បីបង្ហាញថា សហភាពអឺរ៉ុបអាចក្លាយជាតួអង្គស្វយ័តតាមបែបយុទ្ធសាស្ត្រដ៏គួរឱ្យទុកចិត្តមួយរូប។

## ពិពិធភាព ជាក់ស្តែងនិយម ពហុភាគី និងបត់បែន

ជាសេចក្តីសង្ខេប យុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិកដែលនឹងលេចចេញជារូបរាងពេលខាងមុខ កត់សម្គាល់នូវសម័យកាលថ្មីមួយសម្រាប់សហភាពអឺរ៉ុបនៅក្នុងវិធីសាស្ត្ររបស់ខ្លួនចំពោះអាស៊ី ប៉ុន្តែយុទ្ធ-សាស្ត្រនេះមិនទាន់ត្រូវបានដាក់ចូលអនុវត្តជាសកម្មភាពនៅឡើយទេ។ ទីមួយ យុទ្ធសាស្ត្រនេះធ្វើពិពិធកម្មលើទំនាក់ទំនងសហភាពអឺរ៉ុបជាមួយអាស៊ី។ ទីពីរ យុទ្ធសាស្ត្រនេះធ្វើឡើងផ្អែកលើភាពជាដៃគូនិងកិច្ចព្រមព្រៀងពហុភាគី ខណៈការលើកកម្ពស់គុណតម្លៃប្រជាធិបតេយ្យនិងសិទ្ធិមនុស្សរបស់សហភាពអឺរ៉ុប និងការផ្តល់នូវការអះអាងជាថ្មី នៅពេលនិយាយដល់ការការពារផលប្រយោជន៍ (សេដ្ឋកិច្ច) របស់សហភាពអឺរ៉ុប។

សហភាពអឺរ៉ុបមិនបង្ខំដៃគូឱ្យជ្រើសរើសរវាងមហាអំណាចកំពុងរះឡើង និងមហាអំណាចចាស់នោះទេ បើទោះបីជាអ្នកជំនាញមួយចំនួនព្រមានថា សម័យកាលមិនប្រាកដប្រជាបានកន្លងផុតទៅហើយ ហើយយុទ្ធសាស្ត្រសហភាពអឺរ៉ុបត្រូវផ្តល់ជម្រើសពិតប្រាកដព្រមទាំងការរួមចំណែកជាក់ស្តែងចំពោះសន្តិសុខលំហសមុទ្រនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។[13] ការរួមចំណែកជាក់ស្តែងពាក់ព័ន្ធនឹងវត្តមានយោធាអឺរ៉ុបនៅក្នុងដែនទឹករបស់ឥណ្ឌូប៉ាស៊ីហ្វិក ដូចជានាវាចម្បាំងអាល្លឺម៉ង់ដែលនឹងត្រូវបញ្ជូនទៅកាន់តំបន់នេះនៅខែសីហា ជាដើម។ ភាពបត់បែននៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគឺជាអត្ថប្រយោជន៍មួយក្នុងការរំកិលចេញពីការប្រឈមមុខគ្នាលក្ខណៈទ្វេប៉ូល។ យុទ្ធសាស្ត្រនេះលើកកម្ពស់ពិភពលោកពហុប៉ូលដោយផ្អែកលើពហុភាគីនិយមនិងភាពជាដៃគូ បដិភាព និងគុណតម្លៃរួម ព្រមទាំងទម្រង់ប្រកបដោយភាពបត់បែន រួមមានកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងពហុតួអង្គ។ សហភាពអឺរ៉ុបត្រូវតែអនុវត្តយុទ្ធសាស្ត្ររបស់ខ្លួនប្រកបដោយសកម្មភាពក្លាហានដើម្បីបង្ហាញដល់ដៃគូរបស់ខ្លួននៅក្នុងតំបន់ថា ខ្លួនជាតួអង្គផ្អែកលើគុណតម្លៃនិងរយៈពេលវែងមួយ។ ការព្រាងនូវយុទ្ធសាស្ត្រថ្មីមួយសម្រាប់តំបន់ ដែលអនាគតនៃសណ្តាប់ធ្នាប់អន្តរជាតិនឹងត្រូវកំណត់នោះ គឺជាជំហានដំបូងប៉ុណ្ណោះ ដៃគូនានានៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកនឹងត្រួតពិនិត្យយ៉ាងដិតដល់ថា តើសហភាពអឺរ៉ុបសម្រេចបាននូវស្តង់ដាគោលជាក់លាក់និងលទ្ធផលជាក់ស្តែងដែរឬយ៉ាងណា៕

9. Peter Hefele and Isabel Weininger, “Seitenwahl? Strategische Optionen Europas im asiatischen Jahrhundert,“ Konrad Adenauer Stiftung, October 13 2020, https://www.kas.de/de/web/auslandsinformationen/artikel/detail/-/content/seitenwahl.

10. United Nations, Note Verbale by the United Kingdom No.162/20. (New York: September 16, 2020), https://www.un.org/Depts/los/clcs_new/submissions_files/mys_12_12_2019/2020_09_16_GBR_NV_UN_001.pdf.

11. European External Action Service, “EU-ASEAN, Strategic Partnership,” EEAS, December 1, 2020, https://eeas.europa.eu/headquarters/headquarters-homepage/89626/eu-asean-strategic-partnership_en.

12. European External Action Service, “Towards a Strategic Compass,” EEAS, February 19, 2021. https://eeas.europa.eu/sites/default/files/towards-a-strategic-compass-2021-february.pdf

13. Frédéric Grare, “The EU’s Indo-Pacific strategy: A chance for a clear message to China and Europe’s allies,” European Council on Foreign Relations, April 22, 2021, https://ecfr.eu/article/the-eus-indo-pacific-strategy-a-chance-for-a-clear-message-to-china-and-europes-allies/.


© REUTERS/Pascal Rossignol

នៅឆ្នាំ២០១៨ ប្រធានាធិបតីបារាំង លោក Emmanuel Macron បានចាប់ផ្តើមយុទ្ធសាស្ត្រនៃប្រទេសរបស់គាត់សម្រាប់ឥណ្ឌូប៉ាស៊ីហ្វិកនៅក្នុងសុន្ទរកថារបស់គាត់នៅ Garden Island នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី។ នៅក្នុងរូបភាព លោក ម៉ាក្រុង ជួបនាយករដ្ឋមន្ត្រីអូស្ត្រាលី លោក Scott Morrison នៅទីក្រុងប៉ារីស នៅខែមិថុនា ឆ្នាំ២០២១។

# ៨. តំបន់ឥណ្ឌូប៉ាស៊ីហ្វិក : អាទិភាពសម្រាប់បារាំង




## Laurent Triponey

Laurent Triponey ជាអនុប្រធានបេសកកម្មនៃស្ថានទូតបារាំង នៅក្នុងទីក្រុងភ្នំពេញ ចាប់តាំងពីឆ្នាំ២០១៧មក។ ពីមុន គាត់បានបម្រើការជាប្រធានរដ្ឋបាលនិងហិរញ្ញវត្ថុនៃស្ថានទូតបារាំងនៅទីក្រុងញូវដេលី ប្រទេសឥណ្ឌា និងជាអនុអគ្គកុងស៊ុលនៃស្ថានអគ្គកុងស៊ុលបារាំងប្រចាំទីក្រុងសៀងហៃ ប្រទេសចិន។

ដោយបានប្រកាសដាក់ឱ្យដំណើរការដោយប្រធានាធិបតីសាធារណរដ្ឋបារាំងអំឡុងពេលថ្លែងសុន្ទរកថារបស់លោកនៅ Garden Island នាទីក្រុងស៊ីដនី កាលពីខែឧសភា ឆ្នាំ២០១៨ យុទ្ធសាស្រ្តរបស់បារាំងសម្រាប់ឥណ្ឌូប៉ាស៊ីហ្វិក បានក្លាយជាអាទិភាពគោលនយោបាយការបរទេសមួយក្នុងចំណោមអាទិភាពគោលនយោបាយការបរទេសនានារបស់បារាំង។ រយៈពេលបីឆ្នាំមកនេះ ការអនុវត្តយុទ្ធសាស្រ្តនេះកំពុងផលិតបានលទ្ធផលជាក់ស្តែងនិងវឌ្ឍនភាពសំខាន់ឆ្ពោះទៅរកការប្តេជ្ញាចិត្តរបស់បារាំងនៅក្នុងតំបន់។

សម្រាប់បារាំង ឥណ្ឌូប៉ាស៊ីហ្វិកគឺជាតថភាពនៃភូមិសាស្រ្តមួយ។ បារាំងមានវត្តមានក្នុងតំបន់តាមរយៈតំបន់ត្រួតត្រានៅក្រៅប្រទេសរបស់ខ្លួន ហើយ៩៣%នៃតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន (EFZ) គឺមានទីតាំងនៅក្នុងមហាសមុទ្រឥណ្ឌានិងមហាសមុទ្រប៉ាស៊ីហ្វិក។ តំបន់នេះគឺជាជម្រកសម្រាប់ជនជាតិបារាំងចំនួន ១,៥លាននាក់ ហើយទាហានចំនួន ៨,០០០នាក់ បានបោះទីតាំងនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក( សូមមើលផែនទី )។ ដោយសារតំបន់ឥណ្ឌូប៉ាស៊ីហ្វិក បានក្លាយជាមជ្ឈមណ្ឌលយុទ្ធសាស្រ្តនៃភូមិសាស្រ្តនយោបាយ ហើយកំពុងជួបប្រទះភាពតានតឹងដោយសារការបែងចែកប៉ូលនោះ បារាំងកំពុងការពារគោលការណ៍សេរីភាព ភាពបើកចំហ និងភាពបរិយាបន្ន និងវិធីសាស្រ្តមួយគឺកិច្ចសហប្រតិបត្តិការពហុភាគី នៅក្នុងបរិបទមួយផ្អែកលើនីតិរដ្ឋនិងគោលការណ៍ប្រជាធិបតេយ្យ។

យុទ្ធសាស្រ្តរបស់បារាំងសម្រាប់តំបន់ឥណ្ឌូប៉ាស៊ីហ្វិកមួយប្រកបដោយបរិយាបន្ននោះ គឺត្រូវដើរតួជាមហាអំណាចចរចារក្សាស្ថិរភាពនិងប្រកបដោយបរិយាបន្នមួយ។ យុទ្ធសាស្រ្តនេះផ្តោតលើសសរស្តម្ភចំនួនបួន៖

**១**

ការចូលរួមយ៉ាងខ្លាំងក្លានៅក្នុងការដោះស្រាយវិបត្តិក្នុងតំបន់ ការធានាសុវត្ថិភាពនៃផ្លូវដឹកជញ្ជូនតាមកប៉ាល់សំខាន់ៗ និងការទប់ទល់ប្រឆាំងភេរវកម្ម មូលវិវឌ្ឍកម្ម និងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំងដទៃទៀត។

**ទីមួយ**

**២**

ការពង្រឹងចំណងដែលចងប្រទេសនានានៅក្នុងតំបន់ផ្អែកលើចក្ខុវិស័យប្រសព្វគ្នានិងផលប្រយោជន៍រួមគ្នាដែលរួមមាន អូស្រ្តាលី ឥណ្ឌា ឥណ្ឌូណេស៊ី ជប៉ុន ម៉ាឡេស៊ី ណូវែលសេឡង់ សិង្ហបុរី កូរ៉េខាងត្បូង និងវៀតណាម ទន្ទឹមការធ្វើឱ្យទំនាក់ទំនងរបស់យើងជាមួយចិនកាន់តែស៊ីជម្រៅស្ថិតក្នុងក្របខណ្ឌយុទ្ធសាស្រ្តរបស់សហភាពអឺរ៉ុប។

**ទីពីរ**

**៣**

ការចល័តកាន់តែខ្លាំងនៃស្ថាប័នក្នុងតំបន់ ដោយចាប់ផ្តើមជាមួយអាស៊ាន ដែលមានបំណងនៅធ្វើជាផ្នែកដ៏សំខាន់មួយនៃអាស៊ីពហុប៉ូលព្រមទាំងសមាគមព័ទ្ធជុំវិញមហាសមុទ្រឥណ្ឌា សហគមន៍សមុទ្រឥណ្ឌា សហគមន៍ប៉ាស៊ីហ្វិក និងវេទិកាកោះប៉ាស៊ីហ្វិក។

**ទីបី**

**៤**

លើកកម្ពស់ធនធានរួមជាសកល ដូចជា អាកាសធាតុ បរិស្ថាន និងជីវៈចម្រុះ ប៉ុន្តែក៏រាប់បញ្ចូលវិស័យសុខាភិបាល ការអប់រំបច្ចេកវិទ្យាឌីជីថលនិងហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាព ដោយអាស្រ័យលើការចូលរួមកាន់តែខ្លាំងឡើងរបស់សហភាពអឺរ៉ុប( EU )។ គម្រោងនានារបស់បារាំងក៏ផ្តោតផងដែរលើសុវត្ថិភាពសមុទ្រ បរិស្ថាន អភិបាលកិច្ចនៃមហាសមុទ្រ និងការការពារធនធានសមុទ្រ កិច្ចសហប្រតិបត្តិការស្រាវជ្រាវវិទ្យាសាស្រ្ត និងការតភ្ជាប់កាន់តែកើនឡើង។

**ទីបួន**

## ភាពជាដៃគូជាមួយអាស៊ាន

ដោយគិតពីតួនាទីជាសារវន្តរបស់អាស៊ាននៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ការពង្រឹងទំនាក់ទំនងកាន់តែខ្លាំងឡើងជាមួយសហភាពសេដ្ឋកិច្ចនិងសមាជិករបស់សហភាព គឺជាអាទិភាពមួយនៃយុទ្ធសាស្រ្តឥណ្ឌូប៉ាស៊ីហ្វិករបស់បារាំង។ ដោយសារមានប្រវត្តិសាស្រ្តរួមគ្នា បារាំងបានមានចំណងទំនាក់ទំនងពិសេសរួចទៅហើយជាមួយរដ្ឋជាសមាជិកអាស៊ាន ដូចជាកម្ពុជាជាដើម។ ជាមួយឋានៈជាដៃគូអភិវឌ្ឍថ្មីរបស់អាស៊ាន បារាំងមានការប្តេជ្ញាចិត្តចំពោះការធ្វើឱ្យទំនាក់ទំនងជាមួយអាស៊ានកាន់តែស៊ី ជម្រៅ។ ដោយបានប្រកាសដាក់ឱ្យចាប់ផ្តើមដំណើរការជាផ្លូវការនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ភាពជាដៃគូនេះនឹងគ្របដណ្តប់វិស័យមួយចំនួន រួមមាន ទំនិញសាធារណៈជាសកល ដូចជា ផ្នែកសុខាភិបាល និងបរិស្ថាន។ ក្របខណ្ឌថ្មីនេះនឹងបង្ហាញពីតួនាទីដែលដំណើរការដោយវិទ្យាស្ថាននិងទីភ្នាក់ងារស្រាវជ្រាវរបស់បារាំងនៅអាស៊ីអាគ្នេយ៍ ហើយជាពិសេស គឺទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (Agence Française de Développement) (AFD)។ ពីឆ្នាំ២០១៥-២០២០ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) បានអនុវត្តគម្រោងចំនួន ១៧០គម្រោងនៅក្នុងតំបន់ ដែលមានតម្លៃសរុប ៣,៧ប៊ីលានអឺរ៉ូ។ បារាំងបានសម្រេចចិត្តជំរុញធនធាននានាដែលខ្លួនផ្តល់និងវត្តមានរបស់ខ្លួននៅក្នុងស្ថាប័នដោយការបញ្ជូនអ្នកជំនាញបច្ចេកទេសអន្តរជាតិទៅកាន់លេខាធិការដ្ឋានអាស៊ាន។ បន្ថែមទៅលើវិស័យនានាដែលបានពិពណ៌នារួចមកហើយ គម្រោងនិងសកម្មភាពដែលបានធ្វើនៅក្នុងតំបន់ រួមមាន សេដ្ឋកិច្ចពណ៌ខៀវ ជីវៈចម្រុះ ការស្រាវជ្រាវវ៉ាក់សាំង ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ សេដ្ឋកិច្ចបៃតងនិងសេដ្ឋកិច្ចវិលជុំ ការតភ្ជាប់និងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព ការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម សន្តិសុខ (រួមមានសន្តិសុខតាមអ៊ីនធឺណិត និងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ) ការឆ្លើយតបគ្រោះមហន្តរាយ សិទ្ធិមនុស្ស ទេសចរណ៍ និងវប្បធម៌។

លើសពីកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយប្រទេសអាស៊ាននីមួយៗ ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ក៏ផ្តល់ហិរញ្ញប្រទានដល់គម្រោងក្នុងតំបន់ផងដែរ។ គម្រោងមួយមានបំណងការពារតំបន់ដែលគំរាមកំហែងដល់ជីវៈចម្រុះនៅក្នុងប្រទេសកម្ពុជានិងឡាវ ខណៈគម្រោងមួយទៀតពាក់ព័ន្ធនឹងការអង្កេតមេរោគរាតត្បាតទាក់ទិននឹងបម្រែបម្រួលអាកាសធាតុជាមួយនឹងវិសាលភាពពង្រីកបន្ថែមថ្មីៗ ដើម្បីគាំទ្រការឆ្លើយតបទៅនឹងរោគរាតត្បាតកូវីដ-១៩។ ឧទាហរណ៍ផ្សេងៗទៀត រួមមាន កិច្ចសហប្រតិបត្តិការជាមួយគណៈកម្មាធិការទន្លេមេគង្គ កម្មវិធីភាពជាដៃគូនៃការផ្លាស់ប្តូរថាមពល ដែលបានប្រកាសដាក់ដំណើរការអំឡុងកិច្ចប្រជុំកំពូលភពតែមួយ (One Planet Summit) ឆ្នាំ២០១៧ និងគ្រឹះស្ថានហិរញ្ញវត្ថុបៃតងកាតាលីកររបស់អាស៊ាន(ACGF)។

## យុទ្ធសាស្ត្រសហភាពអឺរ៉ុបសម្រាប់ឥណ្ឌូប៉ាស៊ីហ្វិក

សហភាពអឺរ៉ុបមានភាពសកម្មណាស់នៅក្នុងតំបន់ ជាពិសេសនៅពេលខ្លួនពាក់ព័ន្ធនឹងពាណិជ្ជកម្មនិងការវិនិយោគ ការអភិវឌ្ឍជំនួយមនុស្សធម៌ និងការលើកកម្ពស់បទដ្ឋាននានា។ នៅពេលមានការជំរុញរបស់បារាំងនិងរដ្ឋជាសមាជិកផ្សេងៗទៀតនោះ សហភាពអឺរ៉ុបកំពុងខិតខំធ្វើឱ្យយុទ្ធសាស្ត្ររបស់អឺរ៉ុបប្រកបដោយមហិច្ឆតាមួយសម្រាប់ឥណ្ឌូប៉ាស៊ីហ្វិក ដែលកៀរគររាល់បរិធានរបស់អឺរ៉ុបទាំងអស់ ដូច្នេះយុទ្ធសាស្ត្រនេះគួរតែត្រូវបានអនុម័តនៅចុងឆ្នាំនេះ។ តំបន់ឥណ្ឌូប៉ាស៊ីហ្វិកក៏នឹងក្លាយជាអាទិភាពមួយផងដែររបស់បារាំងដែលនឹងក្លាយជាប្រធានក្រុមប្រឹក្សាសហភាពអឺរ៉ុបនៅត្រីមាសទីមួយនៃឆ្នាំ២០២២៕


© asean.org




ដោយទទួលស្គាល់ថាអាស៊ានជាអង្គការតំបន់ដ៏សំខាន់ បារាំងស្វែងព្យាយាមពង្រឹងទំនាក់ទំនងរបស់ខ្លួនជាមួយអាស៊ាន។
នៅក្នុងរូបភាព ឯកអគ្គរដ្ឋទូតបារាំងប្រចាំនៅអាស៊ាន លោក Berthonnet បានសម្ដែងការគួរសមនិងប្រគល់សារតាំងជូនអគ្គលេខាធិការអាស៊ាន លោក មីញ នៅឆ្នាំ២០១៧។




# ៩. ឯករាជ្យភាវូបនីយកម្មនិងប្រភពដើមនៃឥណ្ឌូប៉ាស៊ីហ្វិក




## Maurizio Paciello

លោក Maurizio Paciello ជានាយកកម្មវិធីសម្រាប់កិច្ចការអន្តរជាតិនិងសន្តិសុខនៃមូលនិធិខុនរ៉ាដ អាដិណោអ៊ែរកម្ពុជា តាំងពីឆ្នាំ២០២០។ កន្លងមក លោកធ្លាប់បម្រើការនៅមូលនិធិខុនរ៉ាដ អាដិណោអ៊ែរ នៅអ៊ូសបេគីស្ថាន ឥណ្ឌា និងអាល្លឺម៉ង់។ លោកមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកប្រវត្តិសាស្ត្រដោយផ្តោតលើចក្រពត្តិនិយមចក្រភពអង់គ្លេស នៅក្នុងសតវត្សរ៍ទី២០ ពីសកលវិទ្យាល័យ Humboldt Berlin ជាមួយការចំណាយពេលស្រាវជ្រាវនៅក្នុងទីក្រុង Christchurch ប្រទេសណូវែលសេឡង់ និងទីក្រុងប៉ារីស ប្រទេសបារាំង។

## សេចក្តីផ្តើម : ពិភពលោកក្នុងឆ្នាំ១៩៤៥

ប្រសិនអ្នកត្រូវសម្លឹងមើលផែនទីឥណ្ឌូប៉ាស៊ីហ្វិកក្នុងឆ្នាំ១៩៤៥ អ្នកនឹងប្រហែលជារកឃើញថា ផែនទីនេះមិនសូវជាមានពណ៌ «ស្រស់ឆើតឆាយ» ដូចផែនទីសម័យទំនើបទេ ដោយតំបន់ភាគច្រើនផាត់ពណ៌ស៊ីជម្ពូរបស់ចក្រពត្តិអង់គ្លេស ពណ៌ទឹកក្រូចរបស់ហូឡង់ ឬពណ៌លាំៗ នៃពណ៌ខៀវរបស់បារាំងលាយជាមួយស្នាមប្រឡាក់របស់ព័រទុយហ្គាល់និងសហរដ្ឋអាម៉េរិកនៅចន្លោះកណ្តាល។

មកដល់ត្រឹម ឆ្នាំ១៩៤៥ ចក្រភពអឺរ៉ុប និង «ចក្រភពនៃសេរីភាព» គឺសហរដ្ឋអាម៉េរិក បានត្រួតត្រា សមុទ្រនិងដីគោក ប្រជាជន កិច្ចការយោធា និងសេដ្ឋកិច្ចអស់រយៈពេលច្រើនជាងមួយសតវត្សរ៍មកហើយ ដោយបានផ្លាស់ប្តូរតំបន់ដ៏ធំសម្បើមទៅគ្រាន់តែជាផ្នែកបន្ថែមមួយរបស់ប្រទេសលោកខាងលិច។ ជាកន្លែងដែលសម្បូរទៅដោយធនធានធម្មជាតិនិងប្រជាជននៃតំបន់នេះ បានបង្កើតឱ្យមានទ្រព្យសម្បត្តិមិនអាចគណនាបានសម្រាប់អ្នកស្រុកនៃតំបន់នេះអស់រយៈពេលជាច្រើនសហស្សវត្សរ៍ ហើយទ្រព្យសម្បត្តិនេះកំពុងត្រូវបានបូមចេញទៅកាន់កន្លែងឆ្ងាយៗ ដើម្បីជួយបង្កើនសេដ្ឋកិច្ចរបស់ប្រទេសនានា ដូចជា បារាំងនិងព័រទុយហ្គាល់។

ប៉ុន្តែ រឿងនោះបានផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ នៅក្នុងចន្លោះពេលខ្លីគិតតាមស្តង់ដារប្រវត្តិសាស្ត្រពីឆ្នាំ១៩៤៥ ដល់១៩៧០ ចក្រភពអឺរ៉ុបដែលធ្លាប់បានកាន់កាប់តំបន់ជាច្រើនសតវត្សរ៍មកហើយជាក់ស្តែងបានរលាយបាត់ដោយឆាប់រហ័ស និងជំនួសដោយរដ្ឋអធិបតេយ្យដែលទើបចាប់កំណើតជាមួយនឹងមហិច្ឆតាក្នុងតំបន់និងសកលលោកដ៏សម្បូរបែបជាងមុន។

សព្វថ្ងៃ ឥទ្ធិពលនៃសង្គ្រាមត្រជាក់ត្រូវបានចាត់ទុកជាកម្លាំងជំរុញនៃប្រវត្តិសាស្ត្រដែលបានបង្កើតតំបន់ឥណ្ឌូប៉ាស៊ីហ្វិកជាតំបន់ភូមិសាស្ត្រនយោបាយមួយ។ ប៉ុន្តែ សង្គ្រាមត្រជាក់មិនបានធ្វើអ្វីសោះដើម្បីផ្លាស់ប្តូរតួអង្គដំបូងៗទាំងនោះទេ គឺគ្រាន់តែប្តូរតំណែងពួកគេតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ឯករាជ្យភាវូបនីយកម្មគឺជាបដិវត្តន៍ដែលផ្ទុះឡើងជាបន្តបន្ទាប់ ហើយបានគ្របដណ្តប់លើជីវិតដែលជាញឹកញាប់ សារៈសំខាន់របស់វាត្រូវបានគេមើលរំលង ជាពិសេស ដោយមហាអំណាចលោកខាងលិច។ បដិវត្តន៍នេះបានបន្លំខ្លួនផ្សេងគ្នានៅទីកន្លែងផ្សេងគ្នា ហើយមិនមែនជាដំណើរការដែលមានគោលបំណងនិងក្នុងលក្ខណៈតែមួយដែលចំណុចនេះនឹងត្រូវពិពណ៌នានៅពេលក្រោយមកទៀតនៅក្នុងសៀវភៅសិក្សាតាមសាលារៀនបស្ចិមប្រទេស។

នៅក្នុងអត្ថបទនេះ យើងនឹងសម្លឹងមើលពីដំណើរការនៃឯករាជ្យភាវូបនីយកម្មនៅអាស៊ី[1] និងសេចក្តីសន្និដ្ឋានដែលអាចទាញពីដំណើរការនេះសម្រាប់សណ្តាប់ធ្នាប់ភូមិសាស្ត្រនយោបាយនៃឥណ្ឌូប៉ាស៊ីហ្វិក។ សម្រាប់គោលបំណងនៃការស្វែងរកសេចក្តីសន្និដ្ឋានទាំងនេះ យើងមើលលើចំណុចគួរឱ្យចាប់អារម្មណ៍ចំនួនបី៖

ទីមួយ ព្យាករណ៍អំណាចរបស់មហាអំណាចចក្រពត្តិ។ យើងនឹងមើលពីមូលហេតុដែលព្យាករណ៍ទាំងនេះជាផ្នែកសំខាន់ចំពោះការរក្សាសណ្តាប់ធ្នាប់អាណានិគម ហើយថាតើព្យាករណ៍ទាំងនោះមានការប្រឈមដូចម្តេចដែរ។

ទីពីរ យើងពិនិត្យពីការលេចឡើងនៃទម្រង់ជាតិនិយមផ្សេងៗគ្នានិងរបៀបដែលទ្រឹស្តីនយោបាយត្រូវបានតាក់តែងឡើងដើម្បីបង្កើតជម្រើសអាចទទួលយកបានមួយចំពោះសណ្តាប់ធ្នាប់តំបន់ ដែលមនុស្សរស់នៅក្នុងសម័យកាលនោះបានចាត់ទុកថាគ្មានជម្រើសផ្សេង។

ចំណុចសំខាន់មួយទៀត គឺបញ្ហានៃមហាអំណាចថ្មីដែលកំពុងរះឡើងនៅក្នុងតំបន់ ហើយតើការត្រួត ត្រាអំណាចរបស់ពួកគេមានន័យដូចម្តេចដែរសម្រាប់មហាអំណាចចាស់។

ចុងក្រោយ យើងនឹងមើលថាតើសេចក្តីសន្និដ្ឋានទាំងនេះអាចមានន័យយ៉ាងដូចម្តេចសម្រាប់តំបន់ឥណ្ឌូប៉ាស៊ីហ្វិកសព្វថ្ងៃ។

## ព្យាករណ៍អំណាច

នៅពេលសង្គ្រាមបានផ្ទុះឡើងនៅឆ្នាំ១៩៣៩ វាមិនមែនជាសេចក្តីសន្និដ្ឋានទុកជាមុនដែលថាផ្នែកទាំងអស់របស់ចក្រភពអង់គ្លេសនឹងអនុវត្តតាមការសម្រេចចិត្តរបស់ទីក្រុងឡុងនោះទេ។ ការត្រួតត្រារបស់ចក្រភពអង់គ្លេសលើរដ្ឋចំណុះដែលជាអ្នកស្រុកជនជាតិស្បែកសនៃប្រទេសអូស្ត្រាលី ណូវែលសេឡង់ និងអាហ្វ្រិកខាងត្បូង បានអស់សុពលភាពខ្លះទៅហើយនៅចន្លោះសង្គ្រាមលោកទាំងពីរលើក។ ប៉ុន្តែខណៈសហភាពអាហ្វ្រិកខាងត្បូងនៅតែរារែកនោះ រដ្ឋចំណុះអាណានិគមរបស់ចក្រភពអង់គ្លេសបានចូលរួមក្នុងកិច្ចប្រឹង-ប្រែងធ្វើសង្គ្រាម។ រដ្ឋចំណុះមិនមែនជាជនជាតិស្បែកសមានជម្រើសតិចតួចជាង។ ថ្វីបើមានការតវ៉ាប្រឆាំងក្នុងការចូលប្រឡូកក្នុង  សង្គ្រាមក៏ដោយ ក៏ឧបរាជ្យនៃចក្រភពអង់គ្លេស (British Viceroy) នៅក្នុងប្រទេសឥណ្ឌាបានប្រកាសសង្គ្រាមជាមួយអាល្លឺម៉ង់ជាឯកតោភាគីដោយគ្មានបានប្រឹក្សាជាមួយសភាអាណានិគម។

ប៉ុន្តែហេតុអ្វីបានជារដ្ឋនានា ដូចជា អូស្ត្រាលីដែលបានឯករាជ្យរួចទៅហើយ ប៉ុន្តែមិនទាន់ប្រកាសទទួល ស្គាល់ជាផ្លូវការ បានទៅចូលរួមជាមួយប្រទេសមួយដែលនៅឆ្ងាយ ដើម្បីធ្វើសង្គ្រាមដែលពួកគេបានទទួលផលតិចតួច ប៉ុន្តែខាតបង់ច្រើនទៅវិញនោះ?

វាជាការព្យាករអំណាចរបស់រដ្ឋាភិបាលទីក្រុងឡុងនៅក្នុងតំបន់ដែលបានរក្សាឋានានុក្រមអាណានិគម ឱ្យនៅដដែល។ កងទ័ពជើងទឹកនៅតែត្រូវបានគេយល់ថា ជាកម្លាំងតែមួយគត់ដែលមានសមត្ថ-ភាពការពាររដ្ឋចំណុះនៅអាស៊ីនិងមហាសមុទ្រ ព្រមទាំងពាណិជ្ជ-កម្មរបស់ពួកគេផងដែរ។

កងទ័ពជើងទឹកនេះក៏បានដើរតួជារនាំងដ៏រឹងមាំមួយប្រឆាំងនឹងការបះបោរដែលប្រឆាំងនឹងច្បាប់អាណានិគមនៅក្នុងរដ្ឋចំណុះមិនមែនជនជាតិស្បែកសរបស់ចក្រភពអង់គ្លេស។ ស្រដៀងគ្នាផងដែរ ជនជាតិហូឡង់និងបារាំងមានលទ្ធភាពក្តោបជាប់រដ្ឋចំណុះរបស់ពួកគេដោយសារការព្យាករអំណាចរបស់ពួកគេដ៏គួរឱ្យទុកចិត្ត ខណៈពេលកងទ័ពរបស់ពួកគេមួយចំនួននៅលើគោកនិងកប៉ាល់នៅឯកំពង់ផែ

1. នៅក្នុងអត្ថបទនេះ ពាក្យ «ឥណ្ឌូប៉ាស៊ីហ្វិក» ត្រូវបានយល់ថា ជាតំបន់ដែលលាតសន្ធឹងពីឆ្នេរខាងកើតរបស់ទ្វីបអាហ្វ្រិកទៅដល់ឆ្នេរខាងលិចរបស់ទ្វីបអាម៉េរិកទាំងពីរ។




បន្ទាប់ពីឈ្នះសង្គ្រាមដណ្តើមសិង្ហបុរីនៅដើមឆ្នាំ១៩៤២ ជនជាតិជប៉ុនអាចចូលវាយលុកប្រជុំកោះឥណ្ឌូណេស៊ីនៅក្នុងរយៈពេលតែប៉ុន្មានសប្តាហ៍ ដែលសរុបសេចក្តីបានបង្ហាញពីសារៈសំខាន់របស់សិង្ហបុរីជាមជ្ឈមណ្ឌលរបស់តំបន់។ ក្នុងរូបភាព  វិថីទទេនៃរដ្ឋចំណុះសិង្ហបុរីជាមួយនឹងផ្សែងហុយពីកន្លែងស្តុកប្រេងដែលកំពុងឆេះនៅផ្ទៃខាងក្រោយរូប។

ដែលភាគច្រើនបំផុត គឺមិនមានចំនួនគ្រប់គ្រាន់ដែលពិតជាអាចទប់ទល់កិច្ចខំប្រឹងប្រែងធ្វើរួមគ្នាបាននោះទេ។

របត់ផ្លាស់ប្តូរសម្រាប់ចក្រភពអង់គ្លេស និងហូឡង់ នៅអាស៊ី បានកើតឡើងក្រោយការដួលរលំរបស់សិង្ហបុរី នៅខែកុម្ភៈ ឆ្នាំ១៩៤២ ដែលជាការបរាជ័យមួយដ៏អាក្រក់បំផុតក្នុងចំណោមការបរាជ័យដ៏អាក្រក់បំផុតផ្សេងទៀតរបស់ចក្រភពអង់គ្លេសនៅក្នុងប្រវត្តិសាស្រ្តទាំងមូលរបស់ពួកគេ។ ចក្រភពអង់គ្លេសនិងសម្ព័ន្ធមិត្តអាណានិគមរបស់ពួកគេមានអ្នកចម្បាំងច្រើនជាងជនជាតិជប៉ុន និងបានការពារទីតាំងបន្ទាយដ៏រឹងមាំមួយដែលគេហៅថា «ហ្គីប្រាលតាបូព៌ា (Gibraltar of the East)» ដោយ លោក Churchill ខ្លួនគាត់ផ្ទាល់។ ទោះបីជាយ៉ាងណាក៏ដោយ  ក៏ពួកគេនៅតែចាញ់ដោយសារកំហុសខាងយុទ្ធសាស្រ្ត ព្រឹត្តិការណ៍មិនអាចព្យាករបាន និងការគណនាខុស។

អសមត្ថភាពរបស់ចក្រភពអង់គ្លេសដើម្បីការពារសិង្ហបុរី ដែលប្រហែលជាច្រកឆ្លងកាត់ជាយុទ្ធសាស្រ្តដ៏សំខាន់បំផុតនាសម័យនោះនៃតំបន់ឥណ្ឌូប៉ាស៊ីហ្វិក បានធ្វើឱ្យរង្គោះរង្គើភាពល្បីរន្ទឺរបស់អាណានិគមនិងការព្យាករអំណាច។ ដោយគ្មានសមត្ថភាពការពារពាណិជ្ជកម្មពីអាស៊ីបូព៌ា អូសេអានី និងអាស៊ីអាគ្នេយ៍ដែលត្រូវឆ្លងកាត់ច្រកសមុទ្ររបស់សិង្ហបុរីនិងម៉ាឡាកានោះ ការត្រួតត្រារបស់អាណានិគមអង់គ្លេសលើកន្លែងទាំងនេះគឺមិនអាចទៅរួច។

នៅពេលសិង្ហបុរីត្រូវបានប្រគល់ទៅឱ្យចក្រភពអង់គ្លេសវិញនៅឆ្នាំ១៩៤៥ វាបង្ហាញច្បាស់លាស់ណាស់ថា សង្គ្រាមនៅប៉ាស៊ីហ្វិកមិនបានទទួលជ័យជម្នះដោយចក្រភពអង់គ្លេសទេ។ សិង្ហបុរីមិនត្រូវបានវាយដណ្តើមយកទៅវិញនៅក្នុងសង្គ្រាមទេ ប៉ុន្តែត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលអាណានិគមវិញជាផ្នែកនៃការចុះចាញ់ជាទូទៅរបស់ចក្រភពជប៉ុនបន្ទាប់ពីហ៊ីរ៉ូស៊ីម៉ានិងណាហ្គាសាគី។ ចាប់តាំងពីពេលនោះមក វាមានភាពច្បាស់លាស់សម្រាប់អ្នករាល់គ្នាមើលឃើញថា ចក្រភពអង់គ្លេសមិនមានសមត្ថភាពធានាសន្តិសុខរបស់រដ្ឋចំណុះរបស់ពួកគេ ឬវាយខ្ចប់ការបះបោរនៅទីនោះបានទេ។

សម្រាប់អូស្រ្តាលីនិងណូវែលសេឡង់ រឿងនេះមានន័យថា ជាការផ្លាស់ប្តូរដោយស្ងៀមស្ងាត់ឆ្ពោះទៅរកសហរដ្ឋអាម៉េរិកជាអ្នកធានាសន្តិសុខតំបន់របស់ពួកគេ ដោយសារចក្រភពអង់គ្លេសមិនបានគាំពាររហូតដល់ទីបញ្ចប់នៃកិច្ចព្រមព្រៀងអាណានិគមរបស់ពួកគេតទៅទៀតទេ។ ខណៈពាណិជ្ជកម្មព្រមទាំងការដោះដូរដោយផ្ទាល់ជាមួយប្រទេសជាមេអាណានិគមនៅតែមានសារៈសំខាន់នៅក្នុងអតីតរដ្ឋចំណុះទាំងពីរនេះរហូតដល់ទស វត្សរ៍ឆ្នាំ១៩៨០ ហើយក្នុងលក្ខណៈខ្លះក៏នៅតែមានសារៈសំខាន់រហូតដល់សព្វថ្ងៃ ប៉ុន្តែទាក់ទិនទៅនឹងលក្ខណៈយោធាវិញ ចក្រភពអង់គ្លេសដើរតួនាទីតិចតួចប៉ុណ្ណោះនៅក្នុងតំបន់នេះសព្វថ្ងៃ។

សម្រាប់តំបន់ផ្សេងៗទៀតរបស់ចក្រភព ការផ្លាស់ប្តូរនឹងមិនកើតឡើងដោយរលូននិងដោយស្ងៀមស្ងាត់នោះទេ។ ដោយចក្រភពអង់គ្លេសមិនមានលទ្ធភាពការពារសិង្ហបុរីដោយខ្លួនឯងផ្ទាល់ វាជារឿងច្បាស់លាស់ដែលចក្រភពនេះមិនអាចរក្សាការត្រួតត្រារបស់ឧបទ្វីបឥណ្ឌាបាន ទោះបីការយល់ខុសបានកើតមានមួយរយៈពេលជាពិសេសក្នុងចំណោមអ្នកគិតបែបអភិរក្សនិយមជុំវិញរឿងនាយក

រដ្ឋមន្ត្រី Churchill នោះ។ នៅពេលផ្នែកដ៏ធំនៃកងទ័ពជើងទឹកឥណ្ឌាបានបះបោរនៅក្នុងឆ្នាំ១៩៤៦ សេចក្ដីភន្តច្រឡំលែងមានទៀតហើយ ដោយចក្រភពអង់គ្លេសនឹងត្រូវដកថយពីឧបទ្វីប ឬវាជារឿងចាំបាច់ត្រូវប្រើអំពើហិង្សាដ៏អាក្រក់ហួសថ្លៃងនិងចំនួនលុយយ៉ាងក្រាស់ក្រែលដើម្បីរក្សាការត្រួតត្រានោះ។ ការដកថយរបស់ចក្រភពអង់គ្លេសគ្រាន់តែជួយបន្ថយការព្យាករអំណាចបន្ថែមទៀតនៅក្នុងតំបន់ប៉ុណ្ណោះ។ ក្នុងរយៈពេលដ៏ខ្លីក្រោយមកទៀត ឧបទ្វីបម៉ាឡេ និងសិង្ហបុរី បានធ្វើការប្ដឹងផ្ដល់តុលាការដោយទទួលបានឯករាជ្យរបស់ពួកគេពីចក្រភពអង់គ្លេស។

នៅក្នុងឧបទ្វីបម៉ាឡេរបស់ហូឡង់ ដោយសារការដួលរលំរបស់សិង្ហបុរីដែលបង្កឱ្យបញ្ចប់យ៉ាងឆាប់រហ័សចំពោះការត្រួតត្រាអាណានិគមអស់រយៈពេលជាច្រើនសតវត្សរ៍ តែក្នុងរយៈពេលជាងបីខែបន្តិចប៉ុណ្ណោះ។ ជាក់ស្ដែងជប៉ុនបានកាន់កាប់តំបន់លាតសន្ធឹងនៃកោះដ៏ធំសម្បើមនេះតែក្នុងមួយពព្រិចភ្នែក។

ស្រដៀងទៅនឹងសមភាគីរបស់ពួកគេដែរនោះ បារាំងក៏ត្រូវបានបណ្ដេញចេញពីឥណ្ឌូចិនក្នុងរយៈពេលដ៏ឆាប់រហ័ស[2] និងបានបង្ហាញថាគ្មានលទ្ធភាពត្រឡប់ទៅកាន់ទីនោះវិញដោយខ្លួនឯងផ្ទាល់នោះទេ។ រឿងនេះបានផ្ដល់ជាកម្លាំងរុញច្រានទៅរកការបះបោរមួយដែលបានកញ្ជ្រោលខ្លាំងយ៉ាងលឿនទៅជាសង្គ្រាមឥណ្ឌូចិនទីមួយ ដោយសារបារាំងដែលមិនដូចចក្រភពអង់គ្លេសនោះមានឆន្ទៈចង់វាយប្រហារ។ សង្គ្រាមបានធ្វើឡើងជាមួយភាពសាហាវឃោរឃៅយ៉ាងខ្លាំងនិងបង្កវិនាសហិនហោចយ៉ាងធំសម្បើម ប៉ុន្តែសង្គ្រាមនេះគ្មានបង្ហាញកន្លែងណាមួយសោះដែលកៀកល្មមអាចរក្សាការត្រួតត្រាអាណានិគមបាន។

2. អ្នកគ្រប់គ្រងរដ្ឋបាលបារាំងក្នុងឥណ្ឌូចិនបានសម្រេចចិត្តធ្វើសម្ព័ន្ធមិត្តកៀកជាមួយរបបអភិរក្សនិយមវិស្ស៊ីនិងគាំទ្រក្រុមអាក់ស៊ីស (the Pro-Axis Vichy Regime) ជាងបារាំងសេរីរបស់លោក Charles de Gaulle នៅពេលប្រទេសចំណុះអាណានិគមបារាំងមួយចំនួនបានធ្វើ។ នេះមានន័យថា ចាប់តាំងពីឆ្នាំ១៩៤១ មក បារាំងដែលកាន់តែខ្សោយរួចហើយនៅក្នុងតំបន់ ដែលត្រូវទទួលយកកងទ័ពជប៉ុននៅក្នុងដែនដីរបស់ពួកគេ។ នៅពេលរបបវិស្ស៊ី (Vichy-regime) បានដួលរលំក្នុងឆ្នាំ១៩៤៤-១៩៤៥ កងទ័ពជប៉ុនបានបណ្ដេញរដ្ឋបាលបារាំងនិងបានជំរុញយ៉ាងលឿនឱ្យមានការទទួលបានឯករាជ្យពីអាណានិគមដើម្បីការពារឥណ្ឌូចិនពីការធ្លាក់ចូលដៃសម្ព័ន្ធមិត្ត។

ដូចដែលយើងបានឃើញថា ការព្យាករអំណាចនៅក្នុងតំបន់ហាក់ដូចជាអាចបង្កឱ្យមានចំណាប់អារម្មណ៍ច្រើនជាងរឿងពិតហួតដល់តែវាមានការជជែកវែកញែក។ ជាពិសេស វាជារឿងគួរឱ្យចាប់អារម្មណ៍នៅច្រកឆ្លងកាត់ជាយុទ្ធសាស្ត្រនិងសេដ្ឋកិច្ច ដូចជាសិង្ហបុរី និងច្រកសមុទ្រម៉ាឡាកា ឬសព្វថ្ងៃនៅសមុទ្រចិនខាងត្បូងដែលមានការព្យាករអំណាច។ ប៉ុន្តែវាក៏នៅច្រកឆ្លងកាត់ជាយុទ្ធសាស្ត្រទាំងនេះហើយដែលព្យាករណ៍អំណាច អាចត្រូវបានជជែកវែកញែកចំពោះឥទ្ធិពលដ៏ធំផេង។

## ជាតិនិយមនិងសង្គមនិយម

ការវិវឌ្ឍលើកទីពីរដែលបង្កឱ្យបញ្ចប់ការត្រួតត្រាតំបន់របស់អឺរ៉ុបនោះគឺជាតិនិយមនៃអាណានិគមដែលបានលេចឡើងនិងការរីកសាយភាយនៃគំនិតសង្គមនិយម។

តាមប្រវត្តិសាស្ត្រ មហាអំណាចអាណានិគមមានសមត្ថភាពដើម្បីបង្ក្រាបប្រជាជននិងតំបន់ភូមិសាស្ត្រនានាដែលមានឧត្តមភាពខាងចំនួនប្រជាជននិងទំហំផ្ទៃដីធំជាងខ្លួន ដោយគ្រាន់តែប្រឹងប្រែងតិចតួចប៉ុណ្ណោះ ដែលបទពិសោធន៍របស់អាណានិគមនៅតែបង្ហាញថា វាសមតម្លៃនិងជាទីគាប់ចិត្តផ្នែកសេដ្ឋកិច្ចចំពោះសាធារណជន




អ្នកនយោបាយនៃប្រទេសអាណានិគម ដូចជា លោក ស៊ូកាណូ នៅក្នុងតំបន់ឧបទ្វីបម៉ាឡេខាងកើតរបស់ហូឡង់(រូបភាពថតនៅពេលប្រកាសឯករាជ្យក្នុងឆ្នាំ១៩៤៥) និង លោក ហូ ជីមិញ នៅក្នុងតំបន់ឥណ្ឌូចិនរបស់បារាំង បានចាប់យកគំនិតផ្ដួចផ្ដើមយ៉ាងឆាប់រហ័ស និងបានប្រើចន្លោះពេលគ្មានអ្នកកាន់អំណាចរវាងការធ្លាក់ចុះនៃការកាន់កាប់របស់ជប៉ុន និងការត្រឡប់មកវិញនៃមហាអំណាចអាណានិគម ដើម្បីបន្តចក្ខុវិស័យជាតិនិយមនិងសង្គមនិយមរបស់ពួកគេផ្ទាល់។

អឺរ៉ុប។ គន្លឹះដើម្បីធ្វើឱ្យការត្រួតត្រាអាណានិគមដំណើរការនោះ គឺបំបែកបំបាក់និងត្រួតត្រា។

តើឥណ្ឌានិងឥណ្ឌូណេស៊ីនឹងក្លាយជាអ្វី បើមិនអាចជាអង្គភាពរួប-រួមគ្នាមុនពេលមានការជួបទាក់ទងដំបូងជាមួយជនជាតិអឺរ៉ុបនោះ ? ទិដ្ឋភាពនយោបាយតំបន់ដែលបែកខ្ញែក បានអនុញ្ញាតឱ្យមហាអំណាចអឺរ៉ុបដែលមានគុណសម្បត្តិផ្នែកយោធាតិចតួចប៉ុណ្ណោះ ប្រសិនជាមាន ដើម្បីមកពង្រីកឥទ្ធិពលរបស់ពួកគេដោយបានផ្លាស់ប្តូរពាណិជ្ជករនានាក្លាយជាស្តេចត្រាញ់សង្គ្រាម នៅក្នុងដំណើរការនោះ។

ការបានសម្រេចនូវជំហររបស់ពួកគេដោយគ្រាន់តែត្រូវដោះស្រាយជាមួយពហុភាពនៃបច្ចាមិត្តមួយចំនួនតូច មហាអំណាចអាណា-និគមមិនដែលភ្លេចរក្សាលក្ខខណ្ឌប្រកួតប្រជែងបែបនេះទេ។ វាជាការចង់បញ្ជាក់ប្រាប់ថា ចក្រភពអង់គ្លេសមិនបានគោរពតាមការអំពាវនាវឱ្យមានវិមជ្ឈការនយោបាយប្រកបដោយអត្ថន័យយូរណាស់មកហើយ ដែលខ្លួនឯងផ្ទាល់បានព្យាយាមបង្កើតប្រព័ន្ធនយោបាយសហព័ន្ធនៅសឹងគ្រប់រដ្ឋចំណុះរបស់ខ្លួននោះ។

ស្រដៀងគ្នាផងដែរនោះ ហូឡង់មានលទ្ធភាពបង្ក្រាបដែនដីដ៏ធំទូលាយ ដែលឥឡូវគឺប្រទេសឥណ្ឌូណេស៊ី យ៉ាងហោចណាស់ គឺមានតែនៅលើផែនទីនៃតំបន់ប៉ុណ្ណោះ ខណៈការត្រួតត្រាជាក់-ស្តែងលើតំបន់ជាយខាងក្រៅនេះភាគច្រើនគឺតិចតួចទេ។ មុនការឈ្លានពានរបស់ជប៉ុនបន្តិច ក្នុងខែធ្នូ ឆ្នាំ១៩៤១ កងទ័ពតំបន់ឧបទ្វីបម៉ាឡេខាងកើតរបស់ព្រះរាជាណាចក្រហូឡង់ (Koninklijk Nederlandsch-Indisch Leger) មានមន្ត្រីចំនួន ១,000នាក់ និងទាហានចំនួន ៣៤,000នាក់ ដើម្បីត្រួតត្រាប្រជាជនចំនួនប្រហែល ៦០លាននាក់។

ប៉ុន្តែក្នុងករណីទាំងពីរ កងកម្លាំងជាតិនិយម ដែលមានលក្ខណៈបែបអឺរ៉ុប ប៉ុន្តែត្រូវបានទាញយកប្រើយ៉ាងសកម្មដោយរដ្ឋបុរសអាស៊ីនិងអាហ្វ្រិកនោះ មិនអាចត្រូវបានបង្ក្រាបដោយការបំបែកបំបាក់និងត្រួតត្រាទេ។ ជាតិនិយមបានបង្រួបបង្រួមប្រទេសក្រោមអាណា-និគមផ្សេងៗ គ្នាជាច្រើនយ៉ាងឆាប់រហ័ស ដែលជារឿយៗមានលក្ខណៈរួមទៅវិញទៅមកយ៉ាងតិចតួច ឬទាំងមិនដែលមានរដ្ឋាភិបាលរួមគ្នាមួយផងនៅក្នុងសម័យកាលមុនអាណានិគម។

នៅក្នុងប្រទេសឥណ្ឌារបស់ចក្រភពអង់គ្លេសវិញ ដំណើរការនេះត្រូវបានជំរុញយ៉ាងទាន់ហន់ដោយអ្នកយុទ្ធសាស្ត្រ (អ្នកគិត) និងអ្នកច្បាប់ដែលទទួលការអប់រំនៅចក្រភពអង់គ្លេសជាច្រើនរូប ដែលជារឿយៗបានចំណាយពេលច្រើនគួរសមនៅក្នុងចក្រភពអង់គ្លេស ឬមកពីរដ្ឋចំណុះផ្សេងទៀតរបស់ចក្រភពអង់គ្លេស ដូចជា ក្នុងករណីលោក មហាត្មៈ គន្ធី ជាដើម។ ពួកគេបានច្របាច់ចូលគ្នានៅក្នុងសភាជាតិឥណ្ឌា ដែលបានបង្កើតឡើងដោយជនជាតិឥណ្ឌានិងជនជាតិអង់គ្លេសដែលមានចរិតលក្ខណៈដូចគ្នា។

នៅក្នុងសភា គំនិតស្តីអំពីអត្តសញ្ញាណឥណ្ឌារួមគ្នាមួយ បានទទួលការទាក់ទាញជាលើកដំបូង។ របបអាណានិគមបានព្យាយាមដោយមិនសូវបានការ ដើម្បីបញ្ឈប់ការវិវឌ្ឍនេះដោយការត្រឡប់ទៅរកការបំបែកបំបាក់និងត្រួតត្រា ដែលបង្ហាញថាមានប្រសិទ្ធភាពពីមុននោះ ដោយពេលនេះបានរៀបចំឱ្យមានជម្លោះប្រឆាំងគ្នាទៅវិញទៅមករវាងជនជាតិឥណ្ឌាប្រកាន់សាសនាផ្សេងៗគ្នា។ ខណៈការធ្វើបែបនេះបានបរាជ័យនៅទីបញ្ចប់នោះ ឥទ្ធិពលដ៏មហន្តរាយនៃសកម្មភាពនេះដែលរហូតមកដល់សព្វថ្ងៃនៅតែត្រួតត្រានយោបាយរបស់អាស៊ីបូព៌ានៅក្នុងទំនាក់ទំនងដ៏ស្មុគស្មាញរវាងឥណ្ឌា ប៉ាគីស្ថាន និងបង់ក្លាដែស។

នៅក្នុងឥណ្ឌូចិននិងឥណ្ឌូណេស៊ី លោក ស៊ូកាណូ និងលោក ហូ ជីមិញ ដែលមានការជ្រួតជ្រាបយ៉ាងខ្លាំងនូវការគិតផ្អែកលើចំណេះដឹងបែបបស្ចិមប្រទេស ដែលផ្តើមចេញពីបញ្ញត្តិទាំងនេះ ដូចជា «ប្រជាជាតិ» ឬ «សង្គមនិយម»។ ការគ្រប់គ្រងរបស់ជប៉ុនបានដើរតួនាទីជាកាតាលីករមួយនៅក្នុងការអភិវឌ្ឍនៃចលនាជាតិនិយមដែលបង្កើតឡើងដោយខ្លួនឯងក្នុងគោលបំណងដើម្បីធ្វើធម្មានុរូបកម្មនៃការកាន់អំណាចរបស់ពួកគេ ជាជម្រើសតាមបែបធម្មជាតិមួយចំពោះការប្រើអំណាចត្រួតត្រាជ្រុលរបស់អាណានិគមអឺរ៉ុប។ វាកាន់តែច្បាស់លាស់ យ៉ាងឆាប់រហ័សថា ជប៉ុនគ្រាន់តែកំពុងលេងល្បែងនយោបាយនិងគ្មានចំណាប់អារម្មណ៍នៅក្នុងការធ្វើសកម្ម ភាពផ្សេងណាមួយប្លែកពីអ្នកត្រួតត្រាជាជនជាតិអឺរ៉ុបពីមុនរបស់ពួកគេនោះទេ។ ប៉ុន្តែចលនាជាតិនិយមដែលពួកគេបានរៀបចំនោះបានសម្រេចនូវគោលបំណងរបស់ពួកគេនៅទីបញ្ចប់ បើទោះបីជាចក្រភពជប៉ុនបានដួលរលំរួចទៅហើយមុនពេលនោះក៏ដោយ។

បន្ទាប់ពីសហភាពសូវៀតត្រូវបានបំបរបង់ចោលដោយមហាអំណាចពិភពលោក បន្ទាប់ពីការកកើតរបស់ខ្លួននោះ វាបានបង្វែរសំដៅទៅមហាអំណាចទាំងនោះដែលខ្លួនគេផ្ទាល់មិនធ្លាប់បានឮនៅលើឆាកអន្តរជាតិ។ គំនិតបែបសង្គមនិយមបានប្រែក្លាយជាមានភាពទាក់-ទាញចំពោះពួកជាតិនិយមរបស់ប្រទេសអាណានិគមដែលមានចំណាប់អារម្មណ៍នៅក្នុងការប្រែក្រឡាស់ការកាន់អំណាចបែបមូលធននិយមបរទេសនិងបានពន្យុះឱ្យមានបដិវត្តន៍នៅក្នុងប្រទេសរបស់ពួកគេ។

ឧស្សាហូបនីយកម្មដ៏ឆាប់រហ័សប៉ុន្តែដោយហិង្សា ដែលសហភាពសូវៀតបានជួបប្រទះក្រោមការដឹកនាំរបស់លោកស្តាលីន ហើយដែលប្រទេសចិននឹងជួបប្រទះភ្លាមៗក្រោមការដឹកនាំរបស់លោកម៉ៅដែលសន្យាថាយកជាគំរូនោះ សម្រាប់រដ្ឋចំណុះនានាដែលត្រូវបានបដិសេធជាយូរមកហើយនូវមធ្យោបាយដើម្បីប្រែក្រឡាស់ខ្លួនពួកគេទៅជាមហាអំណាចឧស្សាហកម្មសម័យទំនើប។ ឥណ្ឌាបានសម្លឹងគំរូសេដ្ឋកិច្ចរបស់សូវៀតជាគោលការណ៍ ប៉ុន្តែនៅរក្សាកម្រិតពហុ-និយមខាងនយោបាយ ខណៈតំបន់នានារបស់ឥណ្ឌូចិននឹងក្លាយជាប្រទេសកុម្មុយនីស្តទាំងស្រុង។

តំបន់ឥណ្ឌូចិនរបស់បារាំងគឺមានលក្ខណៈពិសេសនៅក្នុងការតស៊ូរបស់ខ្លួនចំពោះការច្របាច់ចូលគ្នាទៅក្នុងប្រភេទណាមួយនៃសហ-ព័ន្ធឬអង្គភាពពហុជនជាតិ បើទោះបីជាលោក ហូ ជីមិញ និងមិត្តរបស់គាត់ត្រូវបាន ដាក់សម្ពាធដោយសមមិត្តសូវៀត ដើម្បីពង្រីកការត្រួតត្រាបែបកុម្មុយនីស្តលើតំបន់ឥណ្ឌូចិនទាំងមូលជាមួយនឹងការមើលឃើញពីការផ្លាស់ប្តូរប្រទេសថៃនៅទីបញ្ចប់នោះ។ ការប្រកួតប្រជែងក្នុងតំបន់ក្នុងប្រវត្តិសាស្ត្រគឺមានភាពខ្លាំងក្លាណាស់ដែលពួកគេថែមបានធ្វើលើសពីអមិត្តភាពជារួមទៅលើរបបអាណា-និគមបារាំងទៀតផង។ តាមការណ៍ពិត ចំពោះករណីប្រទេស




ខណៈដែលលោក ណេរូ នាយកដ្ឋមន្ត្រីឥណ្ឌា បានអនុវត្តតាមគំរូសេដ្ឋកិច្ចសង្គមនិយមយ៉ាងទូលំទូលាយ នៅក្នុងប្រទេសឥណ្ឌាដែលទើបទទួលបានឯករាជ្យថ្មីៗ មេដឹកនាំវៀតណាម លោក ហូ ជីមិញ បានដឹកនាំប្រទេសវៀតណាមចូលទៅក្នុងអនាគតបែបកុម្មុយនីស្ត។ នៅក្នុងរូបភាព លោក ណេរូ និងលោក ហូ ជីមិញ បានជួបគ្នាក្នុងឆ្នាំ១៩៥៤។

កម្ពុជាវិញ បារាំងទទួលបានការអនុញ្ញាតធ្វើជាខ្នងការពារប្រឆាំងបច្ចាមិត្តក្នុងតំបន់។

ទស្សនទានថ្មីៗ ស្តីអំពីជាតិនិយមនិងសង្គមនិយម បានផ្តល់នូវជម្រើសមួយចំពោះការត្រួតត្រាបែបអាណានិគម ដែលនៅសម័យនោះបានធ្វើដោយគ្មានជម្រើស។ ទ្រឹស្តីនយោបាយគឺខុសឆ្ងាយពីវិសាលភាពរបស់អ្នកគិតគូរ។ អ្វីដែលជាទ្រឹស្តីនៅថ្ងៃនេះ អាចជាសណ្តាប់ធ្នាប់តំបន់ថ្មីសម្រាប់រឿងផ្សេងៗនៅថ្ងៃអនាគត។

## មហាអំណាចចាស់និងថ្មី

ការលេចឡើងនូវតួអង្គថ្មីៗ គឺជាការវិវឌ្ឍចុងក្រោយដែលបានផ្លាស់ប្តូរទិដ្ឋភាពភូមិសាស្ត្រនយោបាយនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកក្នុងឆ្នាំ១៩៤៥។

វាមិនមែនជនជាតិជប៉ុនតែម្នាក់ឯងទេដែលបានចាប់ផ្តើមក្លាយជាតួអង្គថ្មី នៅលើឆាកនយោបាយតំបន់នេះ។ នៅចុងសង្គ្រាមលោកលើកទីពីរ ជប៉ុនបានចុះចាញ់ ហើយជប៉ុនត្រូវការចំណាយពេលប៉ុន្មានទសវត្សរ៍ទៀតដើម្បីក្លាយជាតួអង្គខ្លាំងមួយសាជាថ្មីនៅក្នុងតំបន់។ ជនជាតិជប៉ុនត្រូវបានរុញច្រានចេញពីទ្រនំដោយសហរដ្ឋ-អាម៉េរិកដែលជាតួអង្គមួយទៅហើយនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកដោយសារការវាយដណ្តើមយកហ្វីលីពីននិងកោះតូចៗតំបន់ប៉ាស៊ីហ្វិក។ ទោះបីយ៉ាងណាក៏ដោយ ក៏នៅទីបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ បានបន្សល់ទុកនូវ «ចក្រភពនៃសេរីភាព» ជាមហាអំណាចដ៏អស្ចារ្យរបស់លោកខាងលិចនៅក្នុងតំបន់។

ចក្ខុវិស័យរបស់អាម៉េរិកស្តីពីអាណានិគមនិយមដែលបានបណ្តុះដោយប្រវត្តិសាស្ត្ររបស់ខ្លួនផ្ទាល់ដែលជាអតីតរដ្ឋចំណុះ មានភាពខុសប្លែកគួរឱ្យកត់សម្គាល់ពីដៃគូអឺរ៉ុបរបស់ពួកគេ។ ការប្រឆាំងចំពោះអាណានិគមនិយមបានបង្ហាញឱ្យឃើញដោយខ្លួនឯងតាំងពីសតវត្សរ៍ទី១៩ នៅពេលសហរដ្ឋអាម៉េរិកបានចូលរួមយ៉ាងសកម្មនៅក្នុងការបណ្តេញមហាអំណាចអឺរ៉ុបចេញពីតំបន់ភាគច្រើននៃទ្វីបអាម៉េរិកកណ្តាលនិងអាម៉េរិកខាងត្បូង។

អំឡុងសង្គ្រាមលោកលើកទីមួយ សហរដ្ឋអាម៉េរិកបានលើកកម្ពស់សណ្តាប់ធ្នាប់សកលលោកយ៉ាងខ្លាំងដោយផ្អែកលើសិទ្ធិស្វ័យសម្រេចរបស់រដ្ឋនានា ដែលវាជាការមិនពេញចិត្តសម្រាប់អឺរ៉ុប។ ខណៈមានមនុស្សមួយចំនួននៅសហរដ្ឋអាម៉េរិកដែលបានអំពាវនាវឱ្យមានចក្រពត្តិនិយមអាម៉េរិក ប៉ុន្តែរដ្ឋាភិបាលទីក្រុងវ៉ាស៊ីនតោនជាទូទៅបានស្វែងរកប្រភេទនៃការត្រួតត្រាបែបផ្សេងមួយវិញ។ ដូចជាសហភាពសូវៀតដែរ សហរដ្ឋអាម៉េរិកមិនពឹងផ្អែកលើរដ្ឋចំណុះនៅបរទេសទេ ដោយសារសហរដ្ឋអាម៉េរិកកាន់កាប់ដី និងផលិតកម្មចម្បងដោយខ្លួនឯងគ្រប់គ្រាន់។ ផ្ទុយទៅវិញ សហរដ្ឋ-អាម៉េរិកត្រូវការទីផ្សារសម្រាប់ទំនិញរបស់ខ្លួនវិញ។

លទ្ធិគាំពារនិយមរបស់អាណានិគមដោយមហាអំណាចផ្សេងៗ មានន័យថា ទីផ្សារបរទេសដ៏ធំធេង មិនអាចចូលទៅដល់សហរដ្ឋ-អាម៉េរិកទេ ដែលធ្វើឱ្យសហរដ្ឋអាម៉េរិកទទួលបាននូវប្រយោជន៍សេដ្ឋកិច្ចយ៉ាងរឹងមាំនៅក្នុងឯករាជ្យភាពរូបនីយកម្ម ឬយ៉ាងហោចណាស់នៅក្នុងការដាក់សម្ពាធជនជាតិអឺរ៉ុបនៅក្នុងពាណិជ្ជកម្មសេរីរបស់អាណានិគមដែរ។ អំឡុងដើមសង្គ្រាមលោកលើកទីពីរ សហ-

រដ្ឋអាម៉េរិកនិងចក្រភពអង់គ្លេសបានចុះហត្ថលេខាលើកតិកាសញ្ញាអាត្លង់ទិកដែលធានានូវសិទ្ធិស្វ័យសម្រេចរបស់ជាតិ បើទោះបីជារដ្ឋាភិបាលចក្រភពអង់គ្លេសបានប្រញាប់ប្រញាល់បញ្ជាក់ថាកតិកាសញ្ញានេះមិនបានពង្រីកទៅដល់ទ្រព្យសម្បត្តិរបស់អាណានិគមក៏ដោយ។

រហូតដល់ឆ្នាំ១៩៤៥ សហរដ្ឋអាម៉េរិកបានខ្វះអានុភាពចាំបាច់ប្រឆាំងនឹងដៃគូអឺរ៉ុបរបស់ពួកគេ ដើម្បីពង្រឹងសណ្ដាប់ធ្នាប់សកលដែលពួកគេបានរំពឹងទុក។ នៅពេលសង្គ្រាមលោកលើកទីពីរបានបញ្ចប់ក្នុងឆ្នាំ១៩៤៥ វាបានបន្សល់ទុកឱ្យអឺរ៉ុបនូវសេដ្ឋកិច្ចដែលវិនាសហិនហោចនិងពឹងផ្អែកទាំងស្រុងលើការវិនិយោគរបស់សហរដ្ឋអាម៉េរិក ដែលបានធ្វើឡើងដោយមានលក្ខខណ្ឌ។

ការវិលត្រឡប់របស់ហូឡង់ទៅកាន់ឥណ្ឌូណេស៊ី គឺអាចកើតឡើងបានតែតាមរយៈកម្ចីរបស់សហរដ្ឋអាម៉េរិកប៉ុណ្ណោះ ហើយនៅពេលសង្គ្រាមទាមទារឯករាជ្យឥណ្ឌូណេស៊ីបានអូសបន្លាយ គឺមានតែសហរដ្ឋអាម៉េរិកទេដែលបានបង្ខំហូឡង់ទៅរកតុចរចា និងចុងក្រោយព្រមទទួលយកឯករាជ្យរបស់ឥណ្ឌូណេស៊ី។ ស្រដៀងគ្នានោះដែរ ដំបូង សហរដ្ឋអាម៉េរិកបានគាំទ្រកិច្ចខំប្រឹងប្រែងរបស់បារាំងដើម្បីរក្សាឥណ្ឌូចិនក្រែងលោតំបន់នេះធ្លាក់ចូលទៅពួកកុម្មុយនីស្ត ប៉ុន្តែសហរដ្ឋអាម៉េរិកបានបោះបង់ចោលដៃគូរបស់ខ្លួននៅពេលជ័យជម្នះហាក់បីដូចជាកាន់តែមិនអាចទៅរួច។

នៅពេលដំណាលគ្នានោះដែរ សហភាពសូវៀតក្រោមការដឹកនាំរបស់លោក ស្តាលីន កំពុងឈោងទៅបង្កើតបដិវត្តន៍ពាសពេញតំបន់ក្នុងការប៉ុនប៉ងពង្រីកបញ្ជីសម្ព័ន្ធមិត្តរបស់ពួកគេក្រោយសង្គ្រាម។ ការនាំចេញនូវមនោគមវិជ្ជា សព្វាវុធ និងមូលនិធិ បានបង្ហាញថា ទទួលបានជោគជ័យយ៉ាងខ្លាំងមិនត្រឹមតែនៅក្នុងឥណ្ឌូចិនទេ ប៉ុន្តែថែមទាំងនៅតំបន់ផ្សេងៗ នៃទ្វីបអាហ្វ្រិក ឧបទ្វីបកូរ៉េ និងប្រហែលជាសំខាន់យ៉ាងខ្លាំងបំផុតនោះ គឺចិនផងដែរ។

ការលេចឡើងរបស់មហាអំណាចថ្មីៗមិនគ្រាន់តែគាប់ជួនជាមួយការរលាយបាត់នៃចក្រភពចាស់ប៉ុណ្ណោះ ទេ ប៉ុន្តែវាជាបុព្វហេតុចម្បងមួយនៃរឿងនេះ។ សណ្ដាប់ធ្នាប់ក្នុងតំបន់ចាស់គ្មានសល់ចន្លោះសម្រាប់អ្នកមកថ្មីៗទេ។ ដោយសារហេតុនេះ នៅពេលមហាអំណាចថ្មីបានមកដល់ក្នុងតំបន់ ពួកគេបានបង្កើតសណ្ដាប់ធ្នាប់ថ្មីមួយដើម្បីសម្របសម្រួលខ្លួនពួកគេផ្ទាល់។

## សេចក្តីសន្និដ្ឋាន

តើអ្វីដែលបានធ្វើឱ្យចក្រភពអឺរ៉ុបបានធ្លាក់ចុះនៅទីបញ្ចប់?

ជារឿងដែលសំខាន់បំផុតនោះ ការព្យាករអំណាចរបស់ពួកគេលែងទុកចិត្តបានតទៅទៀតហើយ។ ចក្រភពអង់គ្លេស បារាំង និងហូឡង់ហាក់បីដូចជាមិនចេះចាញ់ទេ ប៉ុន្តែ ភ្លាមៗនោះពួកគេមិនមែនថាមិនចេះចាញ់នោះទេ។ នៅពេលជប៉ុនបានបង្ហាញថា របបអាណានិគមអាចត្រូវបានផ្ដួលរំលំយ៉ាងឆាប់រហ័សដោយរបៀបណា របបទាំងនេះបានបាត់បង់នូវអំណាចរបស់ពួកគេ។ ដោយត្រូវបានបំផ្លាញទាំងផ្នែកសេដ្ឋកិច្ចនិងយោធាអឺរ៉ុបដែលធ្លាប់មានអំណាចមហិមាពីមុន ភ្លាមៗនោះត្រូវបានមើលឃើញជាអធិរាជទទេស្អាតដូចក្នុងសុភាសិតប៉ុណ្ណោះ។

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍មុន គ្រាប់ពូជជាតិនិយមបានរីកចម្រើនយឺតៗនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។ មុនពេលដែលសណ្ដាប់ធ្នាប់អាណានិគមហាក់បីដូចជាខ្លាំងល្មម ដើម្បីរក្សាដីធំល្វឹងល្វើយនិងចំនួនប្រជាជនដ៏ច្រើនសម្បើមស្ថិតនៅក្រោមការត្រួតត្រានោះ ឥឡូវនេះការកំណត់និយមន័យជាតិនិយមដោយខ្លួនឯងបានផ្ដល់នូវអនាគតជាជម្រើសមួយសម្រាប់ប្រជាជនដែលរួបរួមគ្នាដោយគ្មានការត្រួតត្រាពីបរទេស។ ការលើកទឹកចិត្តរបស់ជប៉ុននិងការគិតបែបសង្គមនិយមពីអឺរ៉ុប បានបង្កើតក្រុមអ្នកនយោបាយដែលអាចអះអាងដ៏គួរឱ្យទុកចិត្តដើម្បីផ្ដល់សណ្ដាប់ធ្នាប់មានជម្រើសនេះ។ ជាតិនិយមបានធ្វើឱ្យយុទ្ធសាស្ត្រគ្រប់គ្រងរបស់អាណានិគម គឺការបំបែកបំបាក់និងការវាយដណ្ដើមយកមិនអាចទៅរួច ដោយសារជាតិនិយមតាំងពីដំបូងបានបង្រួបបង្រួមប្រទេសក្រោមអាណានិគមប្រឆាំងនឹងការកាន់កាប់របស់បរទេស។

សហរដ្ឋអាម៉េរិកបានកំពុងអំពាវនាវឱ្យមានសិទ្ធិស្វ័យសម្រេចរបស់ប្រជាជាតិនានាអស់រយៈពេលជាច្រើនទសវត្សរ៍ ហើយល្មមអាចប្រើឥទ្ធិពលយោធានិងសេដ្ឋកិច្ចរបស់ពួកគេដើម្បីលួងលោមដៃគូអាត្លង់ទិករបស់ពួកគេទៅក្នុងឯករាជ្យភាវូបនីយកម្ម។ ដោយគិតពីរបៀបអឺរ៉ុបមានភាពអាស្រ័យខ្លាំងលើរដ្ឋាភិបាលវ៉ាស៊ីនតោន និងរបៀបដែលសហភាពសូវៀតមានឥទ្ធិពលលើដំណើរវិវត្តន៍នៃសង្គ្រាមនោះ ប្រទេសក្រោមអាណានិគមអាចបែរទៅរកតួអង្គថ្មីពីរដែលបានសម្ដែងជំហរប្រឆាំងអាណានិគម និងបានផ្ដល់បញ្ញត្តិផ្សេងៗ គ្នាចំពោះអនាគតក្រោយអាណានិគម ដែលជាការផ្ដល់មូលដ្ឋានគ្រឹះសម្រាប់អ្វីដែលនឹងផ្លាស់ប្ដូរយ៉ាងឆាប់រហ័សទៅជាសង្គ្រាមត្រជាក់។

តើអ្វីដែលយើងអាចទាញចេញបានពីអ្វីដែលបានកើតឡើងក្នុងឆ្នាំ១៩៤៥ សម្រាប់ឥណ្ឌូចិនដូចវាមានសភាពសព្វថ្ងៃនេះ? ជាការណ៍ពិត ពិភពលោកបានផ្លាស់ប្ដូរបន្តិចដែរ។ ខណៈតំបន់ធំល្វឹងល្វើយ មានលក្ខណៈចម្រុះគ្នានិងស្មុគស្មាញ ដែលផ្ដល់នូវច្បាប់ដែលអាចអនុវត្តបានជាសកលច្រើនជ្រុលពេកនោះ ចំណុចមួយចំនួនក៏នៅមានសុពលភាពសព្វថ្ងៃដូចវាមានពីពេលមុនផងដែរ។

ទីមួយ ឥណ្ឌូប៉ាស៊ីហ្វិកត្រូវបានកំណត់ដោយពាណិជ្ជកម្មរបស់ខ្លួន។ ទ្រព្យសម្បត្តិរបស់ប្រទេសនានានៅក្នុងតំបន់មានន័យថាការគ្រប់គ្រងផ្លូវពាណិជ្ជកម្មក្នុងតំបន់ផ្ដល់នូវការរុករកធនធានធម្មជាតិដ៏ច្រើនមហិមា។ បន្ទាប់មករឿងនេះ មានន័យថា ពាណិជ្ជកម្មនៅក្នុងតំបន់ចាំបាច់នៅតែបើកចំហចំពោះប្រទេសទាំងអស់ ប្រសិនទ្រព្យសម្បត្តិរបស់ខ្លួនមិនត្រូវបានទាញយកប្រយោជន៍ដោយមហាអំណាចមួយឬពីរទៅបីតែឯង។ ដោយបានឃើញនៅក្នុងព្រឹត្តិការណ៍ដែលជំរុញឱ្យមានហេតុការណ៍ជាបន្តបន្ទាប់  បានកើតឡើងក្រោយពីការដួលរលំរបស់សិង្ហបុរី ច្រកឆ្លងកាត់ជាយុទ្ធសាស្ត្រក្នុងតំបន់ជាពិសេសច្រកសមុទ្ររបស់ម៉ាឡាកា គឺតែងតែមានហានិភ័យចំពោះសណ្ដាប់ធ្នាប់តំបន់ពហុភាគី។ ការល្បាតផ្លូវដឹកជញ្ជូនពាណិជ្ជកម្មដែលឆ្លងកាត់តំបន់ទាំងនេះនិងការរក្សាឱ្យវានៅបើកចំហចំពោះតួអង្គទាំងអស់ ត្រូវតែរក្សាជាអាទិភាពមួយក្នុងតំបន់ជានិច្ច។



© Public Domain

ធម្មនុញ្ញអាត្លង់ទិកបានប្រែក្លាយជាជំហានដ៏សំខាន់មួយក្នុងការធ្វើឱ្យតំបន់អាស៊ីនិងអាហ្វ្រិកប្រកាសឯករាជ្យ ទោះបីនេះមិនមែនជាបំណងរបស់ប្រទេសហត្ថលេខីអង់គ្លេសក៏ដោយ។ នៅក្នុងរូបភាព ប្រធានាធិបតីអាម៉េរិក លោក Roosevelt និងនាយករដ្ឋមន្ត្រីអង់គ្លេស លោក Winston Churchill បានអង្គុយនៅផ្នែកវេទិកាខាងក្រោយនាវា HMS Prince of Wales ក្នុងអំឡុងសន្និសីទអាត្លង់ទិកក្នុងខែសីហា ឆ្នាំ១៩៤១

ទីពីរ ប្រជាជាតិនានាងាយនឹងរងគ្រោះពីការត្រួតត្រារបស់បរទេស នៅពេលពួកគេមានភាពទន់ខ្សោយនិងបានបែកខ្ញែក កត្តានេះបានបើកផ្លូវសម្រាប់ឥទ្ធិពលបរទេសដែលបង្កគ្រោះថ្នាក់យ៉ាងខ្លាំង។ តួអង្គក្នុងតំបន់ដែលមានលទ្ធភាពប្រសើរជាង ដើម្បីព្យាករអំណាចនៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកជាងមហាអំណាចបរទេស ដោយសារពួកគេអាចសុំប្រើប្រាស់ធនធាននានាភ្លាមៗពីតំបន់ដាច់ស្រយាលក្នុងប្រទេស។ តុល្យភាពលើធន ធានក្នុងតំបន់គួរត្រូវរក្សា ដោយសារអតុល្យភាពផ្តល់ជាផ្លូវដែលអាចសម្រេចបានទៅរកការត្រួតត្រាផ្នែកយោធានិងសេដ្ឋកិច្ចម្តងទៀត។

ជាទីបញ្ចប់ ព្យាករណ៍អំណាចអាចមានលក្ខណៈបោកបញ្ឆោត។ ខណៈតួអង្គសព្វថ្ងៃអាចមើលទៅថាមិនអាចប្រជែងឈ្នះបាន ចក្រភពកាលពីអតីតកាលបង្ហាញថា វាអាចជាកំហុសដែលបង្កគ្រោះថ្នាក់ខ្លាំងនិងជាការសម្រេចចិត្តដោយប្រថុយប្រថានមួយចំនួនដើម្បីផ្លាស់ប្តូរសណ្តាប់ធ្នាប់តំបន់ក្នុងមួយពព្រិចភ្នែក។

សណ្តាប់ធ្នាប់របស់ចក្រពត្តិនៅទីបញ្ចប់ គឺមិនអាចជៀសផុតហើយក៏គ្មានចីរភាពដែរ។ ឥណ្ឌូប៉ាស៊ីហ្វិក គឺជាតំបន់មួយមានទ្រព្យសម្បត្តិ និងពិពិធភាពដ៏គួរឱ្យចាប់អារម្មណ៍ខ្លាំង។ សក្តានុពលដ៏ធំសម្បើមនៃពិពិធភាពនេះ អាចសម្រេចបានល្អបំផុតនៅពេលតួអង្គទាំងអស់ដែលពាក់ព័ន្ធក្នុងតំបន់រក្សាសំឡេងដែលមានលក្ខណៈពិសេសរបស់ពួកគេ ហើយសណ្តាប់ធ្នាប់ក្នុងតំបន់ត្រូវផ្អែកលើកិច្ចសហប្រតិបត្តិការ ព្រមទាំងគុណតម្លៃនិងគោលការណ៍ជារួម៕

# V. សេចក្តីសង្ខេប

ជំងឺរាតត្បាតកូវីដ-១៩បានផ្លាស់ប្តូររបៀបរស់នៅរបស់យើង និងបានបង្កការគំរាមកំហែងដល់សុខុមាលភាពរបស់ប្រជាជន។ នៅពេលយើងកំពុងនិពន្ធ ប្រទេសកម្ពុជាកំពុងធ្វើការប្រយុទ្ធយ៉ាងខ្លាំងក្លាបំផុតប្រឆាំងនឹងវីរុសខណៈដែលប្រទេសប្រយុទ្ធនឹងការផ្ទុះក្នុងសហគមន៍ជាលើកទីបី។ ការបិទខ្ទប់ទូទាំងប្រទេសជាលើកដំបូងដែលមិនធ្លាប់បានធ្វើពីមុនមក បានបង្កផលប៉ះពាល់ផ្សេងៗសម្រាប់ក្រុមមនុស្សផ្សេងៗគ្នា។ ជាចំណុចវិជ្ជមានគឺថា ប្រទេសកម្ពុជាមានអត្រាចាក់វ៉ាក់សាំងខ្ពស់ជាងគេបំផុតទីពីរក្នុងតំបន់អាស៊ាន ដោយបានចាក់វ៉ាក់សាំងប្រហែល ១២,៤% នៃចំនួនប្រជាជនសរុបរបស់ខ្លួន។[1]

ការបោះពុម្ពលើកនេះ ពិនិត្យមើលការប្រកួតប្រជែងជាយុទ្ធសាស្រ្ត ដោយផ្តោតជុំវិញទម្រង់ផ្សេងៗគ្នានៃទស្សនទានឥណ្ឌូប៉ាស៊ីហ្វិក។ ទស្សនទាននីមួយៗត្រូវបានគូសបញ្ជាក់ដោយអ្នកចូលរួមនានាដែលបង្ហាញពីកម្មវត្ថុ គោលបំណង កាលានុវត្តភាព បញ្ហាប្រឈមនិងមាគ៌ាឆ្ពោះទៅមុខ។ ទស្សនទានស្តីពី «ឥណ្ឌូប៉ាស៊ីហ្វិក»មានភាពរួមគ្នាជាច្រើន ប៉ុន្តែមានប្រលយពាក្យទាក់ទងនឹងការត្រៀមបម្រុងនិងការអះអាងរបស់ខ្លួនគេផ្ទាល់ឆ្ពោះទៅរកបរិបទជាក់លាក់នៅក្នុងវិសាលភាពសន្តិសុខក្នុងតំបន់ដ៏ធំទូលាយនិងក្រៅតំបន់ផងដែរ។ មានការពិភាក្សាពីបញ្ហាបង្កប់និងភាពតានតឹងជាច្រើនទៀតជាពិសេស ដោយអ្នកជំនាញនិងអ្នកប្រាជ្ញនានា ដែលបានត្រួតពិនិត្យដែនប្រកបដោយជវភាពនៃកិច្ចការក្នុងតំបន់។ ទោះបីយ៉ាងណាក៏ដោយ ក្រៅពីក្តីបារម្ភពីសន្តិសុខនិងការប្រកួតប្រជែងខាងយុទ្ធសាស្រ្ត  យើងក៏គួរតែពិចារណាពីកិច្ចសហប្រតិបត្តិការជាក់-ស្តែងច្រើនជាងនៅក្នុងបរិបទនៃការតភ្ជាប់ឌីជីថលនិងដែនសេដ្ឋកិច្ចដែលគួរត្រូវបានពិនិត្យឱ្យបានពេញលេញនៅក្នុងការចេញផ្សាយបន្ទាប់របស់យើង។

យើងខ្ញុំសូមសម្តែងអំណរគុណអស់ពីចិត្តចំពោះអ្នកចូលរួមចំណែកទាំងឡាយ ដែលបានធ្វើឱ្យការបោះពុម្ពផ្សាយនេះទៅជាបណ្តុំទស្សនវិស័យដ៏រស់រវើកស្តីពីប្រធានបទសន្តិសុខដ៏លំបាក ជាពិសេសការប្រកួតប្រជែងខាងយុទ្ធសាស្រ្តនិងការប្រកួតប្រជែងរបស់មហាអំណាច។ ការបោះពុម្ពបន្ទាប់ស្តីពីប្រធានបទការទូតសេដ្ឋកិច្ចនិងការចូលរួមបែបស្ថាបនា នឹងចេញផ្សាយនៅចុងឆ្នាំ២០២១។ ប្រសិនលោកអ្នកមានចំណាប់អារម្មណ៍ចង់ចែករំលែកទស្សនវិស័យរបស់លោកអ្នកលើប្រធានបទនេះ សូមផ្ញើមូលន័យសង្ខេបរបស់លោកអ្នកតាមអ៊ីមែលមកកាន់យើងខ្ញុំ។

សូមអរគុណចំពោះប្រិយមិត្តអ្នកអានទាំងអស់របស់យើងខ្ញុំ។ យើងខ្ញុំសង្ឃឹមថា ទស្សនាវដ្តីបច្ចុប្បន្នភាពការទូតរបស់យើងនឹងប្រភពឯកសារមានសារប្រយោជន៍សម្រាប់លោកអ្នក។

សូមតាមដានបន្តសម្រាប់ការចេញផ្សាយលេខទីបួន!



© REUTERS/Cindy Liu

1. The Star, "Cambodia ranks second in Asean for Covid-19 vaccinations," April 30, 2021, https://www.thestar.com.my/aseanplus/aseanplus-news/2021/04/30/cambodia-ranks-second-in-asean-for-covid-19-vaccinations.



សមាជិកកងទ័ពកម្ពុជាបានស្លៀកពាក់គ្រឿងបរិក្ខារការពារខ្លួននៅពេលប្រជាជនមកទទួលការចាក់វ៉ាក់សាំងក្នុងពេលផ្ទុះថ្មីៗនៃមេរោគកូរ៉ូណា (កូវីដ-១៩) ក្នុងទីក្រុងភ្នំពេញ កាលពីខែឧសភា ឆ្នាំ២០២១។

# បច្ចុប្បន្នភាពការទូត : ទសវត្សរ៍ថ្មី បញ្ហាប្រឈមចាស់ ?

ត្រួតពិនិត្យដោយ

**Pich Charadine, Robert Hör**

ពិភពលោកកំពុងចាប់ផ្តើមក្នុងទសវត្សរ៍ថ្មី ប៉ុន្តែទិដ្ឋភាពនៃបញ្ហាប្រឈមចម្បងៗនៅដដែល ដែលជាការណ៍ពិត វាប្រហែលដល់សញ្ញាអាសន្នដល់យើងឱ្យរកដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតប្រសើរជាងមុន។ នៅក្នុងទស្សនាវដ្តីបច្ចុប្បន្នភាពការទូតលេខទី១នេះ អ្នកជំនាញនិងអ្នកការទូត ចែករំលែកទស្សនៈរបស់ពួកគេអំពីទសវត្សរ៍ខាងមុខនិងរបៀបដែលយើងអាចដោះស្រាយបញ្ហាប្រឈមទាំងនេះ។ តើយើងត្រូវធ្វើដូចម្តេចដើម្បីធ្វើឱ្យពិភពលោកកាន់តែមានភាពសុខដុមរមនា ? តើនិន្នាការបែបណាដែលនឹងកំណត់អនាគត ? សូមអានបន្ថែមនៅភាគទីមួយ។

## សូមចុចនៅទីនេះ ឬរូបភាពខាងក្រោម ដើម្បីចូលអាន



# បច្ចុប្បន្នភាពការទូត : ទសវត្សរ៍ថ្មី បញ្ហាប្រឈមចាស់?

ត្រួតពិនិត្យដោយ

**Pich Charadine, Robert Hör**

នៅក្នុងទស្សនាវដ្តីបច្ចុប្បន្នភាពការទូតលេខ២ នេះ អ្នកជំនាញល្បីៗក្នុងវិស័យនានា សម្លឹងមើលថាតើអាស៊ានអាចត្រៀមខ្លួនសម្រាប់អនាគតឌីជីថលយ៉ាងដូចម្តេចនិងមាននិរន្តរភាពកម្រិតណា។ យើងសម្លឹងមើលទៅលើបញ្ហានានា ចាប់ពីបណ្តាញ 5G និងសន្តិសុខជាតិ រហូតដល់ច្បាប់បរិស្ថាននិងយេនឌ័រ។ យើងពិនិត្យមើលថាតើអាស៊ានអាចក្លាយជាមជ្ឈមណ្ឌលនៃទីក្រុងឆ្លាតយ៉ាងដូចម្តេច និងរបៀបដែលអាស៊ីអាគ្នេយ៍អាចរៀបចំខ្លួនសម្រាប់ការធ្វើឌីជីថលនីយកម្មយ៉ាងណា។
សូមអានបន្ថែមនៅក្នុងលេខទី២។

## សូមចុចនៅទីនេះ ឬរូបភាពខាងក្រោម ដើម្បីចូលអាន



# តើប្រជាជនកម្ពុជាគិតអ្វី ?

ដោយ

**Emily Southall, Channarak Nget, Isabel Weininger, Chanbormey Long, Maurizio Paciello**

ការស្ទង់មតិនេះមានគោលបំណងផ្តល់ការយល់ដឹងកាន់តែច្បាស់អំពីឥរិយាបថសង្គមនិងនយោបាយ ក៏ដូចជាគំនិតនិងទស្សនវិស័យនៅកម្ពុជា។ របកគំហើញនៃការស្ទង់មតិនេះត្រូវបានប្រមូលផ្តុំនៅជុំវិញប្រធានបទដូចខាងក្រោម៖
ជីវិតប្រចាំថ្ងៃ ការចូលរួមក្នុងនយោបាយ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ការចូលរួមរបស់ពលរដ្ឋ និងទំនាក់ទំនងអន្តរជាតិ។

## សូមចុចនៅទីនេះ ឬរូបភាពខាងក្រោម ដើម្បីចូលអាន



# អ្នកដឹកនាំនិងអ្នកមានឥទ្ធិពលវ័យក្មេងកម្ពុជា

ដោយ

**Dr. Deth Sok Udom, Seng Reasey, Kok Tha, Charadine Pich et. al.**

តាមរយៈកម្រងមេរៀនជាក់ស្តែង ខ្លីៗ ងាយយល់ និងផ្អែកលើសំណួរ ដែលទទួលបានតាមរយៈបទពិសោធន៍ជីវិតពិត សៀវភៅនេះប្រមូលផ្តុំនូវរឿងរ៉ាវប្រកបដោយការជំរុញទឹកចិត្តរបស់អ្នកដឹកនាំនិងអ្នកមានឥទ្ធិពលវ័យក្មេងកម្ពុជាចំនួន ២១ រូប ដែលជារឿងរ៉ាវរបស់ពួកគេបង្ហាញឱ្យឃើញនូវលក្ខណៈមិនធម្មតារបស់ពួកគេដើម្បីឱ្យបំណងប្រាថ្នារបស់ពួកគេបានទទួលជោគជ័យ ក៏ដូចជាភាពធន់និងសេចក្តីប្រាថ្នារបស់ពួកគេ បានធ្វើឱ្យការប្តេជ្ញាចិត្តដើម្បីជោគជ័យរបស់ពួកគេ យកឈ្នះនូវកាភ័យខ្លាចនិងរឿងរ៉ាវមិនធម្មតាផ្សេងទៀត។

## សូមចុចនៅទីនេះ ឬរូបភាពខាងក្រោម ដើម្បីចូលអាន



**International Relations Institute of Cambodia**
Russian Federation Blvd, Sangkat Kakab,
Khan Porsenchey, Phnom Penh, Cambodia
Telephone: +855 12 775 324
Email: iric@iric.gov.kh
Website: www.iric.gov.kh
Facebook: International Relations Institute of Cambodia

**Cambodian Institute for Cooperation and Peace**
No. 204, Street 1966, Phum Paung Peay, Sangkat Phnom Penh
Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
Telephone: +855 12 81 99 53
Email: cicp01@online.com.kh
Website: www.cicp.org.kh
Facebook: www.facebook.com/cicp.org.kh

**Konrad-Adenauer-Stiftung, Cambodia**
House No 4, Street 462, Khan Chamkar Mon,
P.O. box 944, Phnom Penh, Kingdom of Cambodia
Telephone: +855 23 966 176
E-mail: Office.PhnomPenh@kas.de
Website: www.kas.de/cambodia
Facebook: www.facebook.com/kaskambodscha
Instagram: www.instagram.com/kas_cambodia

ISBN 978-978-57109-4-6
9 789785 710946